

រាជរដ្ឋាភិបាលកម្ពុជា

ផែនការសកម្មភាពឆ្នាំ២០២១-២០២៥

នៃ

គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់

ឆ្នាំ២០១៧-២០៣០

បន្តលើកកម្ពស់សុខុមាលភាពរបស់មនុស្សវ័យចាស់កម្ពុជា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី.....ខែ.....ឆ្នាំ២០២៣

សម្គាល់៖ - ពណ៌ខ្មៅ ជាអត្ថបទដើមរបស់ក្រសួងសាមី - ពណ៌ក្រហម ជាអត្ថបទកែសម្រួលតាមស្មារតីប្រជុំជំនាញបច្ចេកទេស

- ពណ៌ខៀវ ជាអត្ថបទកែសម្រួលតាមស្មារតីប្រជុំអន្តរក្រសួង - ពណ៌បៃតង ជាអត្ថបទកែសម្រួលតាមស្មារតីប្រជុំត្រួតពិនិត្យចុងក្រោយ

បុព្វកថា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចាត់ទុកការលើកកម្ពស់សុខុមាលភាពមនុស្សវ័យចាស់ គឺជាកម្មវិធីអាទិភាពមួយដែលគ្រប់ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងវិស័យឯកជនត្រូវរួមគ្នាខិតខំប្រឹងប្រែងអនុវត្ត**គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០** ឱ្យមានលក្ខណៈកាន់តែល្អប្រសើរឡើង។

ដើម្បីសម្រេចបានគោលបំណងនេះ រាជរដ្ឋាភិបាលបាននិងកំពុងអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ ទី៣ និងទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាពិសេសការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ ដោយផ្អែកលើទស្សនាទានគន្លឹះបី៖ (ទី១)លុបបំបាត់ការរើសអើងដែលផ្អែកទៅលើអាយុ ដើម្បីឱ្យមនុស្សវ័យចាស់ទទួលបាននូវការធានាសិទ្ធិដូចគ្នានឹងមនុស្សវ័យក្មេង និងត្រូវបានគេប្រតិបត្តិស្មើគ្នាចំពោះពួកគាត់គ្រប់ករណីទាំងអស់។ (ទី២)ធានានូវសមភាពយេនឌ័រដោយផ្តោតបន្ថែមទៀតលើស្ត្រី ដែលមានចំនួនភាគច្រើនក្នុងចំណោមប្រជាជនវ័យចាស់ ហើយមានភាពងាយរងគ្រោះជាងបុរស និង(ទី៣)លើកកម្ពស់ទំនាក់ទំនងអន្តរជំនាន់ដើម្បីរក្សាបាននូវភាពរឹងមាំនៃចំណងគ្រួសារដែលជានិមិត្តរូបនៃវប្បធម៌ខ្មែរ។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ចតុកោណទី១ **"ការអភិវឌ្ឍធនធានមនុស្ស"** មុំទី៣ បានកំណត់អំពីការលើកកម្ពស់សុខភាពប្រជាជននិងអាហារូបត្ថម្ភ ដើម្បីគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្ស កំណើនសេដ្ឋកិច្ចនិងវឌ្ឍភាពសង្គមប្រកបដោយចីរភាព តាមរយៈយុទ្ធសាស្ត្រ៖ (ទី១)ការជំរុញវិសាលភាពគ្របដណ្តប់សុខភាពសកលនៅកម្ពុជា ដោយបង្កើនវិសាលភាពគ្របដណ្តប់នៃមូលនិធិសមធម៌សុខាភិបាល បន្តអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសាធារណៈដល់អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន និងរបបថែទាំសុខភាពសម្រាប់កម្មកររោងចក្រដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារ និងដោយរៀបចំរបបថែទាំសុខភាពសម្រាប់បុគ្គលស្វ័យនិយោជន៍ និង(ទី២)ការដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំនៃគ្រួសារក្រីក្រ ការរៀបចំកិច្ចអន្តរាគមន៍ផ្សេងៗ សំដៅលើកកម្ពស់អាហារូបត្ថម្ភនិងរៀបចំឱ្យមានយន្តការពហុវិស័យដោយមានការចូលរួមពីសហគមន៍និងរដ្ឋបាលថ្នាក់ក្រោមជាតិនៃតំបន់ដែលទទួលរងនូវកង្វះអាហារូបត្ថម្ភកម្រិតខ្ពស់។ មុំទី៤ បានកំណត់អំពីការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម ដើម្បីលើកស្ទួយស្ថានភាពសង្គម-សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច សង្គមជាតិ តាមរយៈយុទ្ធសាស្ត្រ៖ (ទី១)ការជំរុញអនុវត្ត "ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០១៦-២០២៥" ពិសេសដោយដាក់ឱ្យអនុវត្តនូវរបបហានិភ័យការងារមន្ត្រីសាធារណៈ និងរបបសោធនសម្រាប់កម្មកររោងចក្រដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ការកែទម្រង់របបសោធនសម្រាប់មន្ត្រីរាជការ ការធ្វើសមាហរណកម្មប្រតិបត្តិករប្រព័ន្ធសន្តិសុខសង្គមនិងក្របខ័ណ្ឌអភិបាលកិច្ចប្រព័ន្ធគាំពារសង្គម ទន្ទឹមនឹងការជំរុញការអនុវត្តគោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០ និងគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ និង(ទី២)ការរៀបចំក្របខ័ណ្ឌគតិយុត្ត និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដើម្បីដាក់ឱ្យដំណើរការកម្មវិធីជាតិជំនួយសង្គម

ថ្មីៗនិងពង្រីកកម្មវិធីដែលមានស្រាប់ សំដៅបង្កើនការគាំពារបន្ថែមដល់ជនក្រីក្រនិងជនងាយរងគ្រោះ និងជាក់ឱ្យដំណើរការរបបសន្តិសុខសង្គមថ្មី ព្រមទាំងពង្រីកវិសាលភាពលើរបបដែលមានស្រាប់ សំដៅបង្កើនការគាំពារដល់ប្រជាជនគ្រប់រូប។

ផែនការសកម្មភាពឆ្នាំ២០២១-២០២៥នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ គឺជាផែនការលើកទី២ដែលត្រូវបានអភិវឌ្ឍឡើងស្របតាមផែនការសកម្មភាពអន្តរជាតិទីក្រុងម៉ាឌ្រីដ ឆ្នាំ២០០២ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ គោលនយោបាយជាតិស្តីពីប្រជាជនឆ្នាំ២០១៦-២០៣០ និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ក្នុងនោះគោលដៅទី១ដែលចែងពី"**បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង**" និងគោលដៅទី១០ដែលចែងពី"**កាត់បន្ថយវិសមភាពនៅក្នុងប្រទេសនិងក្នុងចំណោមបណ្តាប្រទេសនានា**" ហើយផែនការនេះនឹងដើរតួនាទីជាផែនទីតម្រង់ទិសសម្រាប់ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល វិស័យឯកជន និងប្រព័ន្ធផ្សព្វផ្សាយក្នុងការអនុវត្តលើការងារលើកកម្ពស់សុខុមាលភាពមនុស្សវ័យចាស់ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិខ្ពស់ ឆ្លើយតបនឹងតម្រូវការរបស់មនុស្សវ័យចាស់។

ជាគោលការណ៍ ដើម្បីអនុវត្តផែនការសកម្មភាពនៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០នេះឱ្យទទួលបានជោគជ័យ តម្រូវឱ្យមានកិច្ចសហការ ការវិភាជធនធាន ការផ្តល់មធ្យោបាយ និងការប្តេជ្ញាចិត្តរួមពីគ្រប់ក្រសួងស្ថាប័ន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍ វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ រួមទាំងប្រជាពលរដ្ឋគ្រប់រូបផងដែរ ដើម្បីប្រែក្លាយផែនការសកម្មភាពនេះឱ្យទៅជាសកម្មភាពជាក់ស្តែងនៅតាមវិស័យនីមួយៗ។ ដូច្នេះ ខ្ញុំមានការជឿជាក់ថា ជាមួយនឹងការប្តេជ្ញាចិត្តខ្ពស់និងស្មារតីនៃភាពជាម្ចាស់ក្នុងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័ន ព្រមទាំងកិច្ចសហការជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធទាំងអស់ ត្រូវបំពេញការងារប្រកបដោយការទទួលខុសត្រូវខ្ពស់និងភាពជាដៃគូល្អ ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រនិងសកម្មភាពចម្បងៗទាំងឡាយដែលបានកំណត់ក្នុងផែនការសកម្មភាពនេះ។

រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តយ៉ាងមោះមុតក្នុងការធ្វើការជាមួយដៃគូទាំងអស់ក្នុងការអនុវត្ត**គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០** សំដៅដល់ការលើកស្ទួយសុខុមាលភាពនិងគុណភាពជីវិតរបស់មនុស្សវ័យចាស់នៅកម្ពុជា។ យើងជឿជាក់ថា **ផែនការសកម្មភាពឆ្នាំ២០២១-២០២៥នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០** គឺជាឯកសារគោលប្រកបដោយយុទ្ធសាស្ត្រនិងវិធីសាស្ត្រច្បាស់លាស់ក្នុងការជួយដោះស្រាយបញ្ហាគ្រប់ទម្រង់លើមនុស្សវ័យចាស់ ដើម្បីឱ្យមនុស្សវ័យចាស់ទទួលបាននូវការគោរពសិទ្ធិរស់នៅក្នុងសង្គមប្រកបដោយសុវត្ថិភាព ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចូលរួមយ៉ាងសកម្មនិងដោយស្មើភាពក្នុងដំណើរការអភិវឌ្ឍប្រទេសជាតិ ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០។

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គការជាតិនិងអន្តរជាតិ ដែលបានផ្តល់ការគាំទ្រទាំងថវិកានិងបច្ចេកទេសក្នុងការរៀបចំ**ផែនការសកម្មភាពឆ្នាំ២០២១-២០២៥នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០**នេះ និងសូមអំពាវនាវដល់គ្រប់ក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងសាធារណជនគ្រប់មជ្ឈដ្ឋានទាំងអស់សូមបន្តគាំទ្រនិងរួមចំណែកឱ្យបានខ្លាំងក្លាក្នុងការអនុវត្តផែនការសកម្មភាពជាតិនេះឱ្យទទួលបានជោគជ័យ ដើម្បីឱ្យប្រជាពលរដ្ឋកម្ពុជា ជាពិសេស មនុស្សវ័យចាស់រស់នៅប្រកបដោយភាពសុខដុមរមនានិងថ្លៃថ្នូរក្នុងជីវិត។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ការអនុវត្ត**ផែនការសកម្មភាពឆ្នាំ២០២១-២០២៥**នឹងរួមចំណែកលើកកម្ពស់តម្លៃសីលធម៌សង្គម តម្លៃមនុស្សវ័យចាស់ និងគ្រួសារខ្មែរ សំដៅលើកកម្ពស់សមធម៌ បរិយាបន្ន និងភាពសុខដុមរមនាក្នុងសង្គម ដែលប្រការនេះនឹងផ្តល់សុវត្ថិភាពនិងកាលានុវត្តភាពដល់មនុស្សវ័យចាស់អាចប្រើប្រាស់សក្តានុពលរបស់ខ្លួនជាអតិបរមា ដើម្បីចូលរួមចំណែកក្នុងកិច្ចអភិវឌ្ឍជាតិ។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

អារម្ភកថា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សានិងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ។ កូនៗមានករណីយកិច្ចចិញ្ចឹមនិងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ។ នៅក្នុងវប្បធម៌ប្រពៃណីខ្មែរ បានឱ្យតម្លៃខ្ពស់លើការគោរពនិងមើលថែទាំមនុស្សវ័យចាស់ ពីព្រោះមនុស្សវ័យចាស់មានតួនាទីសំខាន់ណាស់ក្នុងការកសាងគ្រួសារនិងសហគមន៍ ការអប់រំមនុស្សជំនាន់ក្រោយអំពីទំនៀមទម្លាប់ប្រពៃណីជាតិ សាសនា ការអភិវឌ្ឍភូមិ ឃុំជាដើម។ បន្ថែមពីនេះ មនុស្សវ័យចាស់ជួយសម្រួលការងារគ្រួសារនិងសហគមន៍ ដូចជា : ការអប់រំគ្រួសារ កូនចៅ ការបង្រៀនចំណេះដឹងទូទៅ ជំនាញវិជ្ជាជីវៈ ការព្យាបាលអ្នកជំងឺ ការផ្សះផ្សារវិវាទហិង្សាក្នុងគ្រួសារនិងសហគមន៍ផងដែរ។

យោងតាមជំរឿនទូទៅស្តីពីប្រជាជននៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ បានបង្ហាញឱ្យឃើញថា កត្តាប្រជាសាស្ត្រមានការប្រែប្រួលគួរឱ្យកត់សម្គាល់ ដោយសារតែអត្រាលទ្ធភាពបង្កើតកូនមានការថយចុះ (ថយចុះពី៥,៧ភាគរយនៅឆ្នាំ១៩៩០ មកនៅត្រឹមតែ២,៥ភាគរយនៅឆ្នាំ២០១៩) និងភាពប្រសើរឡើងនៃអាយុសង្ឃឹមរស់មានការកើនឡើង(ពី៥៤ឆ្នាំសម្រាប់បុរស និង៥៨ឆ្នាំសម្រាប់ស្ត្រីនៅឆ្នាំ១៩៩៨ ដល់៧៤,៣ ឆ្នាំសម្រាប់បុរស និង៧៦,៨ឆ្នាំសម្រាប់ស្ត្រីនៅឆ្នាំ២០១៩) ដែលជាហេតុនាំឱ្យកត្តាប្រជាជនវ័យចាស់មានការកើនឡើង។ ចំណែកឯចំនួនប្រជាជនវ័យចាស់មានរហូតដល់១ ៣៩៤ ១៤៦នាក់ ចំនួនស្ត្រីជាមនុស្សវ័យចាស់អាយុពី៦០ឆ្នាំ សរុប៨២៩ ២០៧នាក់ ស្មើនឹងប្រមាណ៨,៩ភាគរយនៃចំនួនប្រជាជនសរុប១៥ ៥៥២ ២១១ នាក់។

នៅក្នុងឆ្នាំ២០០២ រាជរដ្ឋាភិបាលបានគាំទ្រសេចក្តីប្រកាសនៃមហាសន្និបាតពិភពលោកលើកទីពីរស្តីពីមនុស្សវ័យចាស់នៅទីក្រុងម៉ាឌ្រីដ រួចក៏បានរៀបចំបង្កើតគោលនយោបាយសម្រាប់មនុស្សចាស់ ដែលត្រូវបានអនុម័តនៅឆ្នាំ២០០៣។ ចាប់ពីពេលនោះមក ស្ថានភាពប្រជាសាស្ត្រមានការផ្លាស់ប្តូរយ៉ាងច្រើន ជាពិសេសគឺការប្រែប្រួលពាក់ព័ន្ធនឹងប្រជាជនវ័យចាស់ សំដៅចំពោះប្រជាជនដែលមានអាយុ៦០ឆ្នាំឡើង។ ដោយពិនិត្យឃើញអំពីបញ្ហាប្រឈមនិងតម្រូវការរបស់មនុស្សវ័យចាស់ រាជរដ្ឋាភិបាលបានកែសម្រួលឡើងវិញនូវ**គោលនយោបាយសម្រាប់មនុស្សចាស់ឆ្នាំ២០០៣** ដោយបានប្តូរឈ្មោះទៅជា**គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០**។ គោលនយោបាយនេះបានអនុម័តនៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ហើយត្រូវបានប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នាថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅវិមានសន្តិភាព។

គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ គឺជាផែនទីបង្ហាញផ្លូវដ៏សំខាន់មួយដែលត្រូវបានរៀបចំឡើងដើម្បីដោះស្រាយបញ្ហាជាច្រើនដែលកំពុងកើតមានពីដំណើរឈានទៅរកវ័យចាស់នៅក្នុងក្របខ័ណ្ឌរួមនៃការអភិវឌ្ឍជាតិ រួមមាន : យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ និងគោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០។ គោលនយោបាយនេះបានកំណត់នូវវិស័យអាទិភាពប្រាំបួន : (១)ការធានាឱ្យបាននូវសន្តិសុខហិរញ្ញវត្ថុ។ (២)សុខភាពនិងសុខុមាលភាព។ (៣)របៀបរបបនៃការរស់នៅ។ (៤)បរិស្ថានអំណោយផល។ (៥)សមាគមមនុស្សចាស់និងវ័យចាស់សកម្ម។

(៦)ទំនាក់ទំនងអន្តរជំនាន់។(៧)ការរំលោភបំពាននិងអំពើហិង្សាលើមនុស្សចាស់។(៨)ស្ថានភាពមានអាសន្ន និង(៩)ការត្រៀមខ្លួនរបស់ប្រជាជនវ័យក្មេង។ **គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០** បានកំណត់អំពីទិសដៅនិងយុទ្ធសាស្ត្រសម្រាប់អាទិភាពនីមួយៗ។ ទិសដៅនិងយុទ្ធសាស្ត្រនៃគោលនយោបាយនេះ ត្រូវបានប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់ការរៀបចំ**ផែនការសកម្មភាពលើកទី២ដែលមានរយៈពេលប្រាំឆ្នាំ(ឆ្នាំ២០២១-២០២៥)**។ ក្រសួងស្ថាប័ននីមួយៗបានតម្រឹមតម្រង់កម្មវិធី អនុកម្មវិធី និងគម្រោងរបស់ខ្លួនស្របទៅតាមទិសដៅនិងយុទ្ធសាស្ត្រដែលបានកំណត់នៅក្នុង**គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០**។

ផែនការសកម្មភាពនៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ នឹងត្រូវអនុវត្តជាបីដំណាក់កាល គឺដំណាក់កាលទី១មានរយៈពេលបីឆ្នាំ(ឆ្នាំ២០១៨-២០២០) ដំណាក់កាលទី២មានរយៈពេលប្រាំឆ្នាំ(ឆ្នាំ២០២១-២០២៥) និងដំណាក់កាលទី៣មានរយៈពេលប្រាំឆ្នាំ(ឆ្នាំ២០២៦-២០៣០)។ ផែនការសកម្មភាពឆ្នាំ២០២១-២០២៥នេះ គឺជាលទ្ធផលនៃការពិគ្រោះយោបល់រវាងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ហើយត្រូវប្រើប្រាស់ជាឧបករណ៍ដ៏សំខាន់សម្រាប់ការពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។ កម្មវិធី អនុកម្មវិធី គម្រោង និងសកម្មភាពទាំងឡាយ ដែលត្រូវដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពដំណាក់កាលនីមួយៗ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌពេលវេលារបស់គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០។

គួរបញ្ជាក់ផងដែរថា ផែនការសកម្មភាពឆ្នាំ២០១៨-២០២០ ពុំទាន់មានលក្ខណៈឆ្លើយតបទៅនឹងតម្រូវការរបស់មនុស្សវ័យចាស់នៅឡើយទេ ដោយសារតែអំឡុងពេលអនុវត្តបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនជាពិសេស ចាប់តាំងពីចុងឆ្នាំ២០១៩មក ពិភពលោកបានប្រឈមនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាដែលស្ថិតក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវវិធានការសុខាភិបាលនិងរដ្ឋបាលដោយឈរលើគោលការណ៍ជាក់ស្តែងនិយមនិងទន់ភ្លន់ ប៉ុន្តែម៉ឺងម៉ាត់ ព្រមទាំងបត់បែនទាន់ពេលទៅតាមសភាពការណ៍តម្រូវ ដូចជាការអប់រំ ការធ្វើចត្តាឡីស័ក ការផ្អាកសកម្មភាពនានាដែលមានហានិភ័យ បើកយុទ្ធនាការចាក់វ៉ាក់សាំង និងការព្យាបាលអ្នកជំងឺ ធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាមានលទ្ធភាពបើកឱ្យដំណើរការសេដ្ឋកិច្ចនិងសង្គមទាំងស្រុងឡើងវិញ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះ គឺជាកម្មវិធីអន្តរាគមន៍មួយរបស់រាជរដ្ឋាភិបាល ក្នុងដំណាក់កាលរីករាលដាលនៃជំងឺកូវីដ-១៩ សម្រាប់គ្រួសារដែលមានបណ្ណសមធម៌ប្រភេទ១និង២ ដោយប្រើប្រាស់យន្តការដែលមានស្រាប់ តាមរយៈការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដែលដឹកនាំ គ្រប់គ្រង និងអនុវត្តដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមានកិច្ចសហការជាមួយនឹងក្រុមប្រឹក្សាជាតិគាំពារសង្គម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងផែនការ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះមនុស្សវ័យចាស់អាយុចាប់ពី៦០ឆ្នាំឡើងប្រមាណ៣៥៩ ៥៥៦នាក់ទទួលបានពីការឧបត្ថម្ភសាច់ប្រាក់(គិតត្រឹមថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២)។

ជាចុងក្រោយ ក្នុងនាមគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ និងក្នុងនាមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការយ៉ាងរឹងមាំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ជាពិសេសកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនិងអង្គការមនុស្សចាស់កម្ពុជាដែលបានផ្តល់ការគាំទ្រ បានដាក់បញ្ចូលកម្មវិធីអនុកម្មវិធី គម្រោង និងសកម្មភាពទាំងឡាយនៅក្នុងតារាងម៉ាទ្រិកសម្រាប់ត្រួតពិនិត្យតាមដានការអនុវត្ត។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានជំនឿយ៉ាងមុតមាំថា ក្នុងស្មារតីនៃការរួមចំណែកក្នុងការបន្តលើកកម្ពស់គុណភាពជីវិតនិងសុខុមាលភាពមនុស្សវ័យចាស់ ក្រសួង ស្ថាប័នជំនាញនានានិងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ នឹងសហការគ្នាក្នុងការជានាឱ្យមានយន្តការសម្របសម្រួលជាលក្ខណៈអន្តរវិស័យប្រកបដោយប្រសិទ្ធភាព និងការធ្វើហិរញ្ញប្បទានសមស្របនិងទាន់ពេលវេលា ដើម្បីសម្រេចបានជោគជ័យក្នុងការអនុវត្តផែនការសកម្មភាពនេះ។

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ នឹងសម្របសម្រួលការពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តផែនការសកម្មភាពនេះ នៅគ្រប់ដំណាក់កាលនីមួយៗ។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

រដ្ឋមន្ត្រី

មាតិកា

១- សារបាន ១
១.១- គោលនយោបាយ ១
១.១.១- ក្របខ័ណ្ឌជាតិ ១
១.១.២- ក្របខ័ណ្ឌអន្តរជាតិ ២
១.២- ស្ថានភាព ២
១.៣- បញ្ហាអាទិភាព ១៥
១.៤- ដំណោះស្រាយបញ្ហាប្រឈម ២០
២- ទិសដៅនិងយុទ្ធសាស្ត្រ ២៣
២.១- អាទិភាពទី១ : ការធានាឱ្យបាននូវសន្តិសុខហិរញ្ញវត្ថុ ២៣
២.២- អាទិភាពទី២ : សុខភាពនិងសុខុមាលភាព ២៤
២.៣- អាទិភាពទី៣ : របៀបរបបនៃការរស់នៅ ២៦
២.៤- អាទិភាពទី៤ : បរិស្ថានអំណោយផល ២៧
២.៥- អាទិភាពទី៥ : សមាគមមនុស្សចាស់និងវ័យចាស់សកម្ម ២៨
២.៦- អាទិភាពទី៦ : ទំនាក់ទំនងអន្តរជំនាន់ ២៨
២.៧- អាទិភាពទី៧ : ការរំលោភបំពាននិងអំពើហិង្សាលើមនុស្សចាស់ ២៩
២.៨- អាទិភាពទី៨ : ស្ថានភាពមានអាសន្ន ៣០
២.៩- អាទិភាពទី៩ : ការត្រៀមខ្លួនរបស់ប្រជាជនវ័យក្មេង ៣១
៣- ផែនការសកម្មភាព ៣២
៣.១- បរិយាយសង្ខេបអំពីវិសាលភាពផែនការ ៣២
៣.២- ដំណើរការអនុវត្តផែនការសកម្មភាព និងក្រសួង ស្ថាប័នទទួលខុសត្រូវ ៣៣
៣.៣- តារាងអនុវត្តការងារ ៣៥
៤- ការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ១១៤
៥- គម្រោងចំណាយ ១១៤
៦- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ ១១៦
៧- សេចក្តីសន្និដ្ឋាន ១១៧

១. សារធារណ

១.១. គោលនយោបាយ

១.១.១. ក្របខ័ណ្ឌជាតិ

មនុស្សវ័យចាស់មានតួនាទីយ៉ាងសំខាន់ក្នុងការកសាងគ្រួសារ សហគមន៍ អប់រំមនុស្សជំនាន់ក្រោយអំពីទំនៀមទម្លាប់ ប្រពៃណី សាសនា និងការអភិវឌ្ឍ។ ប្រជាជាតិយើងមានប្រពៃណី វប្បធម៌ផ្សារភ្ជាប់ទៅនឹងមនសិការទទួលខុសត្រូវចំពោះមនុស្សវ័យចាស់។ គ្រួសារខ្មែរយើងមានទម្លាប់រស់នៅជួបជុំគ្រួសារ កូនចៅមានកតញ្ញូតាធម៌ចំពោះមាតាបិតា អ្នកមានគុណដែលបានចិញ្ចឹមបីបាច់ថែរក្សា និងផ្តុងផ្តើមឱ្យពួកគេមានអនាគតល្អ។ ដើម្បីលើកកម្ពស់សុខុមាលភាពមនុស្សវ័យចាស់ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្ត និងដាក់ចេញនូវច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយជាច្រើន ដែលឯកសារទាំងនោះ រួមមាន៖

ក. **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** ផ្តោតសំខាន់លើតម្លៃគ្រួសារនិងសិទ្ធិរបស់ឪពុកម្តាយមានវ័យចាស់ ក្នុងការទទួលបាននូវការថែទាំពីកូនចៅពេញវ័យរបស់ពួកគាត់ទៅតាមវប្បធម៌ខ្មែរ ហើយក្នុងមាត្រា៤៧ចែងថា "មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សានិងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ។ កូនៗមានករណីយកិច្ចចិញ្ចឹមនិងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ។" មាត្រា៧២ចែងថា "សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជំងឺ និងព្យាបាលជំងឺ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគដោយឥតបង់ថ្លៃ នៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសេមព្តសាធារណៈ។ រដ្ឋរៀបចំឱ្យមានគិលានដ្ឋាននិងមន្ទីរសេមព្តដល់ជនបទ។"

ខ. **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងមុំទី៣ ចតុកោណទី១ស្តីពីការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ** បានចែងថា "គោលដៅដាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺសំដៅលើកកម្ពស់សុខភាពប្រជាជននិងអាហារូបត្ថម្ភ ដើម្បីគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្ស កំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គមប្រកបដោយចីរភាព។" **និងមុំទី៤ ចតុកោណទី១ស្តីពីការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម** បានចែងថា "គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា គឺការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម ដើម្បីលើកស្ទួយស្ថានភាពសង្គម-សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រី ដែលជាធ្នឹងខ្នងនៃសេដ្ឋកិច្ច សង្គមជាតិ។"

គ. **ច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ដើម្បីការពារសិទ្ធិ សេរីភាព ផលប្រយោជន៍ទប់ស្កាត់ កាត់បន្ថយ និងលុបបំបាត់ការរើសអើងជនពិការ និងស្តារកាយសម្បទា សតិបញ្ញា និងវិជ្ជាជីវៈ ដើម្បីជានាលទ្ធភាពក្នុងការចូលរួមដ៏ពេញលេញនិងដោយស្មើភាពនៃជនពិការក្នុងសកម្មភាពនានារបស់សង្គម។

ឃ. **ច្បាប់ស្តីពីរបបសន្តិសុខសង្គម** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដើម្បីធានាឱ្យមានសមធម៌និងសាមគ្គីធម៌សង្គម និងដើម្បីលើកកម្ពស់សុខុមាលភាពនិងជីវភាពរបស់ប្រជាពលរដ្ឋ។

ង. **ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០១៦-២០២៥**។

ច. **គោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០**។

ឆ- **គោលនយោបាយនិងយុទ្ធសាស្ត្រសុខាភិបាលជាតិ សម្រាប់ថែទាំសុខភាពមនុស្សចាស់ឆ្នាំ២០១៦។**

ជ- **គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០។**

ឈ-**ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០។**

ញ- **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣។**

១.១.២- ក្របខ័ណ្ឌអន្តរជាតិ

ក្រៅពីក្របខ័ណ្ឌគតិយុត្តជាតិ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើលិខិតុបករណ៍អន្តរជាតិមួយចំនួន ដើម្បីលើកកម្ពស់សុខុមាលភាពមនុស្សវ័យចាស់ ក្នុងនោះ រួមមាន៖

- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនពិការ
- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សក្នុងឆ្នាំ១៩៤៨
- សេចក្តីប្រកាសនយោបាយនៃមហាសន្និបាតពិភពលោកលើកទីពីរស្តីពីមនុស្សវ័យចាស់នៅទីក្រុងម៉ាឌ្រីដ ក្នុងឆ្នាំ២០០២
- គោលដៅទី១នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ដែលលើកឡើងអំពី"បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង" បានរំលេចអំពីចំណុចដៅក្នុងការអនុវត្តប្រព័ន្ធជាតិគាំពារសង្គមនិងវិធានការផ្សេងៗឱ្យបានទូទាំងប្រទេស និងសម្រេចឱ្យបានភាគច្រើននូវភាពគ្របដណ្តប់នៃប្រព័ន្ធនេះដល់ប្រជាជនក្រីក្រនិងប្រជាជនងាយរងគ្រោះនៅត្រឹមឆ្នាំ២០៣០ និងគោលដៅទី១០នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ដែលលើកឡើងអំពី"កាត់បន្ថយវិសមភាពនៅក្នុងប្រទេសនិងក្នុងចំណោមបណ្តាប្រទេសនានា" បានរំលេចអំពីចំណុចដៅក្នុងការឯកភាពលើគោលនយោបាយនានា ជាពិសេសគោលនយោបាយស្តីពីសារពើពន្ធប្រាក់បៀវត្ស ការគាំពារសង្គម និងសម្រេចឱ្យបានជាបន្តបន្ទាប់សមភាពច្រើនជាងមុន។

ព្រះរាជាណាចក្រកម្ពុជាបានប្តេជ្ញាចិត្តនៅថ្នាក់តំបន់ ដើម្បីលើកកម្ពស់សុខុមាលភាពមនុស្សវ័យចាស់ឱ្យបានកាន់តែប្រសើរឡើងតាមរយៈ៖

- សេចក្តីប្រកាសព្រុយណេដារូសាឡាមស្តីពី"ការពង្រឹងស្ថាប័នគ្រួសារសម្រាប់ការថែទាំមនុស្សវ័យចាស់" ឆ្នាំ២០១០
- សេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិមនុស្សឆ្នាំ២០១២
- សេចក្តីប្រកាសទីក្រុងគូឡាឡាំពួស្តីពីមនុស្សវ័យចាស់"ការផ្តល់អំណាចដល់មនុស្សវ័យចាស់ក្នុងអាស៊ាន" ឆ្នាំ២០១៥
- សេចក្តីថ្លែងការណ៍អាស៊ានបូកបីស្តីពី"វ័យចាស់សកម្ម" ឆ្នាំ២០១៦។

១.២- ស្ថានភាព

ការកើនឡើងនៃចំនួនប្រជាជនវ័យចាស់ត្រូវបានកត់សម្គាល់ឃើញថា ចាប់តាំងពីសតវត្សមុននៅក្នុងបណ្តាប្រទេសអភិវឌ្ឍជាច្រើន។ នៅដើមទសវត្សទី១០នៃសតវត្សទី២០ ប្រជាជនវ័យចាស់បានចាប់ផ្តើមក្លាយជាកង្វល់នៅក្នុងប្រទេសអភិវឌ្ឍមួយចំនួន ហើយស្ថានភាពនេះបានក្លាយជាបញ្ហាប្រឈមចម្បងនៅក្នុងប្រទេសកំពុងអភិវឌ្ឍចាប់តាំងពីទសវត្សទី១នៃសតវត្សទី២១។ នៅកម្ពុជា ការកើនឡើងនៃប្រជាជនវ័យចាស់បានចាប់ផ្តើមក្រោយគេបន្តិច បើធៀបនឹងបណ្តាប្រទេសកំពុងអភិវឌ្ឍដទៃទៀត ដោយសន្ទុះនៃការកើនឡើងរបស់ប្រជាជនវ័យចាស់បានចាប់ផ្តើមមាននៅក្នុងទសវត្សទីមួយនៃសតវត្សនេះ។ នៅក្នុងឆ្នាំ២០១៩ ចំនួនប្រជាជន

វ័យចាស់សរុបមាន១ ៣៩៤ ១៤៦នាក់(ចំនួនស្ត្រីវ័យចាស់សរុប៨២៩ ២០៧នាក់) ស្មើនឹងប្រមាណ៨,៩ ភាគរយនៃចំនួនប្រជាជនសរុប១៥ ៥៥២ ២១១នាក់។ ប្រសិនបើនិន្នាការនេះនៅតែបន្ត ចំនួនប្រជាជនវ័យចាស់នឹងកើនឡើងរហូតដល់១,៩៩លាននាក់ ស្មើនឹងប្រមាណ១១ភាគរយនៃចំនួនប្រជាជនសរុបនៅឆ្នាំ២០៣០។

នៅពេលដែលចំនួនប្រជាជនវ័យចាស់មានការកើនឡើង បញ្ហាប្រឈមរបស់ពួកគាត់ក៏កាន់តែច្រើនឡើងៗ ផងដែរ ពាក់ព័ន្ធទៅនឹងកត្តាសន្តិសុខហិរញ្ញវត្ថុ ការថែទាំសុខភាព ការថែទាំរយៈពេលវែង របៀបរបបនៃការរស់នៅ ការផ្លាស់ទី ទំនាក់ទំនងអន្តរជំនាន់ និងការគាំទ្រពីប្រជាជនវ័យក្មេង។ នៅក្នុងប្រពៃណីទំនៀមទម្លាប់របស់ប្រជាជនខ្មែរ ការជួយផ្តល់ប្រាក់កាសដល់ឪពុកម្តាយនិងសាច់ញាតិជាមនុស្សវ័យចាស់ បានចាក់ឫសគល់យ៉ាងរឹងមាំនៅក្នុងសង្គមកម្ពុជា។ ប៉ុន្តែ ការប្រតិបត្តិប្រពៃណីបែបនេះនឹងមានការថយចុះនៅថ្ងៃខាងមុខ នៅពេលដែលការគាំទ្រពីមនុស្សវ័យក្មេងទៅដល់មនុស្សវ័យចាស់កាន់តែតិចទៅៗ ជាហេតុធ្វើឱ្យមនុស្សវ័យចាស់ជួបប្រទះបញ្ហាអសន្តិសុខហិរញ្ញវត្ថុ ដែលអាចធ្លាក់ចូលភាពក្រីក្រ។ លើសពីនេះ មនុស្សវ័យចាស់អាចជួបប្រទះបញ្ហាសុខភាពផងដែរ ដោយសារតែប្រព័ន្ធការពារកាយពីជំងឺនានាមានការចុះខ្សោយ ហើយពួកគាត់ជួបប្រទះហានិភ័យកាន់តែខ្ពស់ចំពោះជំងឺមិនឆ្លង ដូចជាជំងឺទឹកនោមផ្អែម មហារីក បេះដូង និងសម្ពាធឈាមខ្ពស់ជាដើម ហើយពួកគាត់អាចប្រឈមនឹងហានិភ័យក្នុងការរស់នៅក្នុងពិការភាព ដែលទាមទារនូវជំនួយសម្រាប់ការរស់នៅប្រចាំថ្ងៃផងដែរ។ ទោះបីជាបញ្ហាប្រឈមមានការកើនឡើងក្តី ប៉ុន្តែប្រជាជនវ័យចាស់កម្ពុជាមានភ័ព្វសំណាងជាងប្រជាជនវ័យចាស់នៅបណ្តាប្រទេសផ្សេងៗ ដោយសារតែនៅប្រទេសកម្ពុជា ប្រជាជនមានប្រពៃណី ទំនៀមទម្លាប់រស់នៅជុំគ្នាជាលក្ខណៈប្រព័ន្ធគ្រួសារដែលមានមនុស្សច្រើនជំនាន់រស់នៅជាមួយគ្នា ហើយការរស់នៅជាប្រព័ន្ធគ្រួសារបែបនេះ គឺជាសំណាញ់សុវត្ថិភាពបែបប្រពៃណីដែលអាចជួយដល់មនុស្សវ័យចាស់មិនឱ្យជួបប្រទះបញ្ហានានាដែលអាចកើតមានឡើងចំពោះពួកគាត់។ ប៉ុន្តែការរស់នៅជុំគ្នារបៀបនេះនឹងមានការថយចុះនៅពេលខាងមុខ ដោយសារតែទេសន្តរប្រវេសន៍របស់ប្រជាជនវ័យក្មេងបានធ្វើចំណាកស្រុកទៅធ្វើការនៅទីក្រុងឬទីប្រជុំជននានាដែលបន្សល់ទុកតែមនុស្សវ័យចាស់រស់នៅឯកោគ្មានទីពឹងឬរស់នៅមើលថែទាំកូនចៅតូចៗ។

រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន តាមរយៈកិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់សុខុមាលភាពមនុស្សវ័យចាស់ ដែលសមិទ្ធផលទាំងនោះត្រូវបានរំលេចក្នុងឯកសាររបស់ក្រសួងស្ថាប័នពាក់ព័ន្ធបានរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៨-២០២០នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ក្នុងនោះរួមមាន៖

+ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

- បានរៀបចំសិក្ខាសាលា មានដូចជាស្វែងរកការគាំទ្រនិងសិទ្ធិមនុស្សវ័យចាស់ដល់តំណាងមនុស្សវ័យចាស់ក្នុងខេត្តចំនួន៣ ហើយបានរៀនសូត្រនិងឆ្លុះបញ្ចាំងពីលទ្ធផលដែលបានសម្រេចកន្លងមកតាមរយៈយុទ្ធនាការស្វែងរកការគាំទ្រមនុស្សវ័យចាស់និងធ្វើការតម្រង់ទិស ព្រមជាមួយផែនការនិងគម្រោងសំណើសម្រាប់រៀបចំទិវាមនុស្សវ័យចាស់កម្ពុជា ១ តុលា ឆ្នាំ២០១៩ សិទ្ធិរបស់មនុស្សវ័យចាស់និងការគាំទ្ររបស់គណៈកម្មាធិការសមាគមសហព័ន្ធជាមួយសមាជិក ដើម្បីបង្កើតយុទ្ធសាស្ត្រនៃការគាំទ្រនិងបានសម្របសម្រួលក្នុងការពិនិត្យនិងកែសម្រួលលក្ខន្តិកៈនិងសមាគមសហព័ន្ធចំនួន៤ បានធ្វើការបោះឆ្នោតជ្រើសរើសសមាជិក៩រូប ធ្វើជាគណៈកម្មាធិការសមាគមសហព័ន្ធអាណត្តិថ្មី និងការផ្សព្វផ្សាយអំពីរបាយការណ៍សិក្សាស្រាវជ្រាវអំពីតម្រូវការនិងបញ្ហាប្រឈមរបស់មនុស្សវ័យចាស់នៅភោជនីយដ្ឋានទន្លេបាសាក់២

- បានគាំទ្រដល់បណ្តាញសមាគមនិងសហព័ន្ធមនុស្សវ័យចាស់រៀបចំយុទ្ធនាការស្វែងរកការគាំទ្រមនុស្សវ័យចាស់ នាឱកាសទិវាសុខភាពពិភពលោកចំនួន១០កន្លែង ក្នុងអំឡុងខែមេសា ឆ្នាំ២០១៩។ តាមរយៈយុទ្ធនាការនេះ មនុស្សវ័យចាស់ចំនួន៣០៥នាក់បានទទួលសេវាពិនិត្យសុខភាពបឋមនិងថ្នាំសម្រន់មួយចំនួនដោយឥតគិតថ្លៃផងដែរ។ ក្នុងនោះ សមាគមចំនួន៨ទទួលបានការឆ្លើយតបពីអាជ្ញាធរឃុំអំពីការសន្យាវិភាជថវិកាឃុំ ដើម្បីជួយគាំទ្រដល់សមាគម និងមណ្ឌលសុខភាពចំនួន៥កន្លែងបានសន្យាចុះពិនិត្យសុខភាពដល់មនុស្សវ័យចាស់នៅតាមសហគមន៍ដោយឥតគិតថ្លៃ
- បានគាំទ្រថវិកានិងបច្ចេកទេសដល់សមាគម ដើម្បីឆ្លើយតបទៅនឹងសំណើរបស់មនុស្សវ័យចាស់លើការគាំទ្រ ការចុះអប់រំសុខភាព ផ្តល់មូលនិធិឃុំ និងគាំទ្រលើធនធានតាមលទ្ធផលដែលអាជ្ញាធរអាចធ្វើបានដល់សមាគមមនុស្សចាស់
- បានគាំទ្រគណៈកម្មការបច្ចេកទេសរបស់បណ្តាញមនុស្សវ័យចាស់កម្ពុជា ក្នុងការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអាជ្ញាធរស្រុក និងឃុំព្រះនេត្រព្រះនិងឃុំបុសស្ទូវ ដោយផ្សារភ្ជាប់ទៅនឹងទិវាយល់ដឹងពិភពលោកអំពីការរំលោភបំពានលើមនុស្សវ័យចាស់។ ក្នុងកិច្ចប្រជុំនេះ អភិបាលរងស្រុក ព្រមទាំងអាជ្ញាធរឃុំទាំងពីរ បានសន្យានឹងវិភាជកញ្ចប់ថវិកាឃុំឆ្នាំ២០២០ ដើម្បីជួយគាំទ្រដល់សមាគមនិងសហព័ន្ធមនុស្សចាស់ក្នុងស្រុកព្រះនេត្រព្រះ
- បានរៀបចំវគ្គបណ្តុះបណ្តាលជាច្រើន មានដូចជាមូលដ្ឋានគ្រឹះនៃការថែទាំមនុស្សវ័យចាស់សម្រាប់ថ្នាក់ជាតិ(មន្ត្រីនាយកដ្ឋាន២លើក) ថ្នាក់ក្រោមជាតិ(មន្ទីរស.អ.យ.រាជធានី ខេត្ត ១លើក) ជំងឺផ្លូវចិត្ត(៦វគ្គ) ជំងឺមិនឆ្លងនិងបញ្ហាសុខភាពផ្សេងៗទៀតទាក់ទងនឹងមនុស្សវ័យចាស់ ដល់បុគ្គលិកមណ្ឌលសុខភាព និងអនុគណៈកម្មការសមាគម(៨វគ្គ) ពង្រឹងសមត្ថភាពសមាគមមនុស្សចាស់ខេត្តព្រៃវែង ត្បូងឃ្មុំ បាត់ដំបង បន្ទាយមានជ័យ កោះកុង ព្រះសីហនុ និងខេត្តប៉ៃលិន ការគ្រប់គ្រងបញ្ជីស្នាមការថែទាំមនុស្សវ័យចាស់តាមផ្ទះ ការថែទាំសុខភាព មុខរបរចិញ្ចឹមជីវិតសម្រាប់មនុស្សវ័យចាស់ដល់សមាគមគំរូទាំង៥ និងប្រព័ន្ធកសិកម្មបែបបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ ជូនកសិករជាមនុស្សវ័យចាស់
- បានរៀបចំកិច្ចប្រជុំលើកទី១ជាមួយអនុគណៈកម្មាធិការដើម្បីមនុស្សចាស់ ទាក់ទងនឹងការផ្សព្វផ្សាយគម្រោងថ្មីនៅតាមតំបន់គោលដៅ និងបានរៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ១ តុលា ឆ្នាំ២០១៨ នៅខេត្តស្វាយរៀង ឆ្នាំ២០១៩ នៅខេត្តបាត់ដំបង និងឆ្នាំ២០២០ នៅខេត្តត្បូងឃ្មុំ
- បានចុះអប់រំសុខភាព ចុះសួរសុខទុក្ខតាមផ្ទះ សម្របសម្រួលដល់ការបង្កើតអនុគណៈកម្មការសុខភាពនិងបណ្តុះបណ្តាលសុខភាពផ្លូវចិត្តដល់សមាគមមនុស្សចាស់ចំនួន៨១
- បានរៀបចំឱ្យមានអ្នកស្ម័គ្រចិត្តទ្រទ្រង់សុខភាពភូមិនិងបុគ្គលិកមណ្ឌលសុខភាពដែលមានការឧបត្ថម្ភថ្នាំនិងបរិក្ខារថែទាំសុខភាពដែលជាតម្រូវការប្រើប្រាស់ក្នុងការចុះពិនិត្យនិងអប់រំសុខភាព និងដំណើរទស្សនកិច្ចសិក្សារវាងសមាគមមនុស្សចាស់/គម្រោងសំណងផ្សេងៗ ដើម្បីចែករំលែកគំនិតនិងការអនុវត្តល្អ

- បានផ្តល់ថវិកាមូលនិធិសង្គមដល់សមាគមមនុស្សចាស់ចំនួន៧ និងបានផ្តល់មូលនិធិដល់សមាគមចំនួន២០ ដើម្បីរៀបចំកម្មវិធីមុខរបរនិងទុនបង្វិលក្នុងសមាគម និងបានសាងសង់ ជួសជុលលំនៅឋានដល់មនុស្សវ័យចាស់ដែលងាយរងគ្រោះនិងសហគមន៍របស់ពួកគាត់ បានចំនួន៤៣ខ្នង ក្នុងស្រុកសំពៅលូន ស្រុកឯកភ្នំ និងស្រុកមោងឫស្សី និងបានសាងសង់ស្ថានីយទឹកសម្រាប់សហគមន៍ដែលមានសមាគមមនុស្សចាស់តាំងនៅ
- បានចុះសិក្សាអំពីស្ថានភាពភូមិក្នុងតំបន់ខេត្តគោលដៅ ដើម្បីឈ្វេងយល់ពីស្ថានភាពនិងចំនួនជនចាស់ជរា
- បានចុះផ្សព្វផ្សាយគោលការណ៍ស្តីពីការបង្កើតនិងគ្រប់គ្រងសមាគមមនុស្សចាស់ នៅគ្រប់២៥រាជធានី ខេត្ត និងបានផ្សព្វផ្សាយអំពីការគ្រប់គ្រងសមាគមនិងទំនាក់ទំនងសុំការគាំទ្រពីអាជ្ញាធរក្នុងស្រុកសំពៅលូន និងបានចុះផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ នៅគ្រប់២៥រាជធានី ខេត្ត
- បានសម្របសម្រួលបង្កើតគណៈកម្មការសមាគមផ្នែកមុខរបរចំនួន៤សមាគម និងទុនបង្វិលចំនួន៦សមាគម និងបានសម្របសម្រួលក្នុងការរៀបចំលក្ខន្តិកៈមុខរបរ ចំនួន និងថ្លៃលក់ ការបើកសម្ពោធផលិតផលដែលត្រូវលក់និងការគាំទ្រពីអាជ្ញាធរនៅក្នុងសមាគមភូមិមាត់ស្រះ ស្រុកភ្នំស្រុកខេត្តបន្ទាយមានជ័យ សមាគមភូមិគោកជ្រៃ និងភូមិដំណាក់ស្លាញ់ ស្រុកពួក ខេត្តសៀមរាប
- បានផ្តល់ឱកាសដល់តំណាងបណ្តាញមនុស្សវ័យចាស់កម្ពុជាចូលរួមក្នុងក្រុមការងារចំពោះកិច្ចកែសម្រួលផែនការសកម្មភាពឆ្នាំ២០១៨-២០២០នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ និងចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្តីពីការប្រមូលធាតុចូលទៅក្នុងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៨-២០២០ និងផែនការសកម្មភាពឆ្នាំ២០២១-២០២៥នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់
- បានរៀបចំក្នុងការចុះត្រួតពិនិត្យគុណភាពទឹកនៅសមាគមចំនួន១០ក្នុងស្រុកឯកភ្នំនិងមោងឫស្សី ហើយបានធ្វើតេស្តទឹកពាងផែនដី(៨០ពាង) ដែលគម្រោងផ្តល់ឱ្យសម្រាប់ផ្ទុកទឹកស្អាតប្រើប្រាស់នារដូវប្រាំង។ ជាលទ្ធផលនៃការធ្វើតេស្តដោយប្រើប្រាស់ឧបករណ៍៣អ៊ឹម បង្ហាញឱ្យឃើញថា ក្រោយពីការផ្សព្វផ្សាយពួកគាត់បានយល់ដឹងអំពីអនាម័យ និងយកចិត្តទុកដាក់ថែរក្សាប្រភពទឹកប្រើប្រាស់របស់ខ្លួនបានល្អប្រសើរជាងឆ្នាំ២០១៧ នេះបើតាមការរាប់បរិមាណមេរោគកូលីហ្វមនិងអ៊ីកូឡាយដែលបានធ្វើតេស្ត និងបានរៀបចំហ្វឹកហ្វឺនជាប្រចាំដល់កសិករដែលជាមនុស្សវ័យចាស់ អំពីបម្រែបម្រួលអាកាសធាតុ និងបានរៀបចំយុទ្ធនាការស្វែងរកការគាំទ្រ(២លើក) ដែលទាក់ទងនឹងបញ្ហាប្រឈមរបស់មនុស្សវ័យចាស់ពាក់ព័ន្ធទៅនឹងគ្រោះមហន្តរាយ និងបានជួយរៀបចំផែនការត្រៀមជម្លៀស និងប្រព័ន្ធជួយអ្នករងគ្រោះដល់សមាគមមនុស្សចាស់ និងបានកំណត់ទីទួលសុវត្ថិភាពសម្រាប់គ្រួសារជម្លៀសកំពុងពេលមានទឹកជំនន់ ដោយផ្សារភ្ជាប់ព័ត៌មាននៃធនធានដែលអាចប្រើប្រាស់បាននៅក្នុងឬជិតទីទួល ដោយរួមទាំងស្រះទឹក ការរក្សាអនាម័យ និងការថែរក្សាសុខភាពកំឡុងពេលជម្លៀស
- បានសហការជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តបាត់ដំបង ចុះផ្តល់កញ្ចប់សង្គ្រោះបន្ទាន់ជូនដល់ប្រជាពលរដ្ឋរងគ្រោះដោយសារខ្យល់កន្ត្រាក់និងគ្រោះទឹកជំនន់។ គ្រួសាររងគ្រោះសរុប

២៩៦គ្រួសារក្នុងស្រុកចំនួន៨ រួមមាន : ស្រុកឯកភ្នំ សំពៅលូន បាណន់ គាស់ក្រឡ ភ្នំព្រឹក កំរៀង សង្កែ និងរុក្ខគិរី

- បានគាំទ្រដល់សមាគមមនុស្សចាស់ចំនួន១០ រៀបចំផែនការសកម្មភាពត្រៀមបង្ការនិងកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ
- បានបង្កើតខិត្តបណ្ណនិងរៀបចំវគ្គផ្សព្វផ្សាយអំពីកម្មវិធីកាត់បន្ថយគ្រោះមហន្តរាយពីបម្រែបម្រួលអាកាសធាតុទៅដល់សមាគមមនុស្សចាស់ចំនួន១០។

+ **ក្រសួងទេសចរណ៍**

- បានបញ្ជាបការយល់ដឹងនៅតាមសិក្ខាសាលាកម្រិតបច្ចេកទេសនិងកម្រិតអន្តរមន្ទីរជំនាញក្នុងការកសាងផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្មរាជធានី ខេត្ត ឆ្នាំ២០២១-២០២៥ ដល់គ្រប់រាជធានី ខេត្ត
- បាននិងកំពុងត្រៀមរៀបចំកម្រងសំណួរសំខាន់ៗក្នុងការកសាងសមត្ថភាពមនុស្សវ័យចាស់សម្រាប់ការចុះសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់វិស័យទេសចរណ៍ដែលបណ្តាលមកពីការរីករាលដាលនៃមេរោគកូវីដ-១៩ នៅឆ្នាំ២០២០។

+ **ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

- មានកម្មវិធី"លេខគ្រោះអាសន្ន" ដែលប្រើរូបសញ្ញាក្នុងការហៅរកការសង្គ្រោះបន្ទាន់ ដោយប្រើលើទូរសព្ទឆ្លាតវៃ
- បានដាក់ផ្លាកសម្គាល់"អាទិភាពមនុស្សវ័យចាស់" នៅតាមបញ្ជរផ្តល់សេវា
- បានបណ្តុះបណ្តាលបញ្ជរបាលដើម្បីជួយសម្រួលដល់មនុស្សវ័យចាស់ក្នុងការទទួលយកសេវា
- បានបំពាក់ម៉ាស៊ីនចាប់លេខរៀង(Query Machine) នៅបញ្ជរភ្នំពេញ
- បានរៀបចំបណ្តុះបណ្តាល មានដូចជាមូលដ្ឋានគ្រឹះICT ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានជូនដល់មន្ត្រីរាជការ(១៧វគ្គ) និងរៀបចំសិក្ខាសាលាបញ្ជាបការយល់ដឹងICT(២លើក) បានចុះធ្វើសម្រង់មតិវាស់ស្ទង់ការប្រើប្រាស់បច្ចេកវិទ្យានៅខេត្តកំពង់ចាម ដើម្បីត្រៀមរៀបចំវគ្គបណ្តុះបណ្តាល
- ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធNerveNet ដើម្បីដាក់ឱ្យដំណើរការនូវកម្មវិធីបណ្តុះបណ្តាលពីចម្ងាយនៅតំបន់ជនបទដាច់ស្រយាល៖
  + នៅក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង : អនុវិទ្យាល័យចំនួន៣និងវិទ្យាល័យ១ សាលាឃុំ១និងសាលាស្រុក១
  + នៅស្រុកព្រះស្តេច ខេត្តព្រៃវែង : អនុវិទ្យាល័យ១និងវិទ្យាល័យ៥។

+ **ក្រសួងបរិស្ថាន**

- មន្ត្រីចូលនិវត្តន៍ត្រូវបានយកចិត្តទុកដាក់ គោរព និងផ្តល់តម្លៃពីសំណាក់ក្រសួងបរិស្ថាន។

+ **ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសិទ្ធិនិងលក្ខខណ្ឌការងារ ដើម្បីទប់ស្កាត់ការរើសអើងមនុស្សវ័យចាស់នៅក្នុងការងារ ត្រូវបានសិក្សាជ្រាវជ្រាវនិងធ្វើវិសោធនកម្ម

- បានរៀបចំលក្ខណវិនិច្ឆ័យកម្រិតហានិភ័យផ្នែកលក្ខខណ្ឌការងារដើម្បីទប់ស្កាត់ការរើសអើងមនុស្សវ័យចាស់នៅក្នុងការងាររបស់សហគ្រាស គ្រឹះស្ថាន
- បានរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសុវត្ថិភាពការងារក្នុងវិស័យសំណង់ ឡឥដ្ឋ និងសេវាកម្មរ៉ាន្ត
- បានរៀបចំទិវាពលកម្មអន្តរជាតិ ១ ឧសភា បាឋកថា និងកម្មវិធីសម្រស់ឯកជារៀងរាល់ឆ្នាំ
- បានរៀបចំយុទ្ធនាការសំវាទសង្គម ដើម្បីលើកកម្ពស់ភាពសុខដុមនីយកម្មនៅក្នុងសហគ្រាសនិងផលិតភាពការងារ ត្រូវបានអនុវត្ត
- បានរៀបចំនិងធ្វើវិសោធនកម្មប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធសុវត្ថិភាពនិងសុខភាពការងារ
- បានរៀបចំគោលនយោបាយជាតិស្តីពីសុវត្ថិភាពនិងសុខភាពការងារត្រូវបានអនុម័តត្រឹមឆ្នាំ២០២១
- ការវាយតម្លៃអំពីមូលដ្ឋានគោលនៃលក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ ត្រូវបានធ្វើជារៀងរាល់ ២ឆ្នាំ/ម្តង ចាប់ផ្តើមពីឆ្នាំ២០២១
- អត្រានៃសហគ្រាសដែលចុះបញ្ជីនៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលអនុលោមតាមស្តង់ដាស្នូលសុវត្ថិភាពនិងសុខភាពការងារ មានការកើនឡើងយ៉ាងតិច៨០%នៅឆ្នាំ២០២៣(កន្លងទៅបានបំពេញបែបបទ ប៉ុន្តែអនុវត្តមិនគ្រប់តាមស្តង់ដា)
- អត្រាសហគ្រាស គ្រឹះស្ថាននាំចេញដែលបានបំពេញបែបបទស្របតាមស្តង់ដាសុវត្ថិភាពនិងសុខភាពការងារស្នូលចំនួន៩០% ត្រឹមឆ្នាំ២០២២
- អត្រាភាគទានផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈត្រូវបានកំណត់
- អត្រាភាគទានផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនិងមន្ត្រីសាធារណៈ ត្រូវបានកំណត់ត្រឹមឆ្នាំ២០២០
- ដាក់ចេញយន្តការតាមដាននិងវាយតម្លៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារត្រឹមឆ្នាំ ២០២០
- ច្បាប់ស្តីពីសុវត្ថិភាពនិងសុខភាពការងារ ត្រូវបានអនុម័តត្រឹមឆ្នាំ២០២៣
- ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសិទ្ធិនិងលក្ខខណ្ឌការងារ ត្រូវបានសិក្សាស្រាវជ្រាវនិងធ្វើវិសោធនកម្ម
- ច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវបានអនុម័តត្រឹមឆ្នាំ២០២៣
- ប្រព័ន្ធគ្រប់គ្រងហានិភ័យការងារនិងការការពាររគ្រោះថ្នាក់ការងារនិងជំងឺវិជ្ជាជីវៈ ត្រូវបានបង្កើតនៅឆ្នាំ២០២០
- កម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៩-២០២៣ ត្រូវបានអនុម័តនិងដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៩
- សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការតាមដាន ត្រួតពិនិត្យការអនុវត្ត និងវាយតម្លៃកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៩-២០២៣ ត្រូវបានរៀបចំត្រឹមឆ្នាំ២០១៩
- សេចក្តីសម្រេចស្តីពីការបង្កើតលេខាធិការដ្ឋានសម្រាប់កម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៩-២០២៣ ត្រូវបានរៀបចំត្រឹមឆ្នាំ២០១៩
- ផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់អនុវត្តកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៩-២០២៣ ត្រូវបានអនុម័ត

- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការធ្វើវិក្រឹតការគ្រូបច្ចេកទេស ត្រូវបានរៀបចំត្រឹមឆ្នាំ២០២០
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ដល់មន្ត្រីសាធារណៈនិងជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវបានកែសម្រួលត្រឹមឆ្នាំ២០២០
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ ត្រូវបានអនុវត្តចាប់ពីឆ្នាំ២០១៩
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពដល់មន្ត្រីសាធារណៈនិងជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវបានកែសម្រួលត្រឹមឆ្នាំ២០២០
- ប្រកាសស្តីពីការហ្វឹកហ្វឺនកូនជាងនិងកម្មសិក្សា ត្រូវបានអនុម័តនៅត្រឹមឆ្នាំ២០១៩
- បានបញ្ជាបការពង្រឹងជំនាញតាមរយៈការពង្រឹងសេវាកម្មទេសចរណ៍បដិសណ្ឋារកិច្ចនិងសេវាកម្មស្នាក់នៅ នៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍និងទេសចរណ៍សហគមន៍ដែលអនុវត្តបានគ្រប់២៥ រាជធានី ខេត្ត
- មន្ត្រីយ៉ាងតិចចំនួន៧៥នាក់/ឆ្នាំត្រូវបានបណ្តុះបណ្តាលក្នុងប្រទេសអំពីបទដ្ឋានថ្មីពាក់ព័ន្ធនឹងសុវត្ថិភាពនិងសុខភាពការងារ
- មន្ត្រីយ៉ាងតិចចំនួន១០នាក់/ឆ្នាំ ទទួលបានការបណ្តុះបណ្តាលពីសុវត្ថិភាពនិងសុខភាពការងារក្រោមកិច្ចសហប្រតិបត្តិការអន្តរជាតិ
- មូលដ្ឋានសុខាភិបាលជាដៃគូរបស់ប.ស.ស. ត្រូវបានពង្រីក ស្របតាមដង់ស៊ីតេកម្មករ និយោជិតជាសមាជិកប.ស.ស.
- ការពេញចិត្តនៃសេវាមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយប.ស.ស. តាមរយៈការធ្វើអង្កេត មានការកើនឡើងជារៀងរាល់ឆ្នាំ
- ការពេញចិត្តនៃសេវាមណ្ឌលស្ថានីតិសម្បទាជាដៃគូរបស់ប.ស.ស. តាមរយៈការធ្វើអង្កេត មានការកើនឡើងនៅរៀងរាល់ឆ្នាំ
- ការពេញចិត្តលើសេវាគាំទ្ររបស់មន្ត្រីប.ស.ស. តាមរយៈការធ្វើអង្កេត មានការកើនឡើងជារៀងរាល់ឆ្នាំ
- យន្តការតាមដាននិងវាយតម្លៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារត្រឹមឆ្នាំ២០២០។

+ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានរៀបចំកិច្ចពិភាក្សាជារួមលើទិដ្ឋភាពបរិយាបន្នហិរញ្ញវត្ថុនិងយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុបានរួមបញ្ចូលទាំងលទ្ធភាពដែលមនុស្សវ័យចាស់អាចទទួលបានសេវាហិរញ្ញវត្ថុចំនួន៥ដង
- ក្នុងឆ្នាំ២០១៩ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសិក្សានិងរៀបចំជាសេចក្តីព្រាងអនុក្រឹត្យស្តីពីជំនួយសង្គមសម្រាប់មនុស្សវ័យចាស់ក្រីក្រគ្មានទីពឹង ប៉ុន្តែរង់ចាំការសម្រេចលើការរៀបចំយន្តការដាក់ឱ្យដំណើរការអនុវត្តកម្មវិធីជាមុន។

+ **ក្រសួងធម្មការនិងសាសនា**

- មនុស្សវ័យចាស់ចំនួន២%ទៅ៣% បានស្នាក់នៅវត្តអារាម ដោយសារស្ថានភាពក្រីក្រ កូនបោះបង់ចោល ស្ម័គ្រចិត្តមកបម្រើព្រះសង្ឃ បដិបត្តិធម៌ និងមានបញ្ហាឪកូនបោះបង់ចោល ទទួលបានការឧបត្ថម្ភពីព្រះសង្ឃ កូនចៅ និងសប្បុរសជននៅក្នុងពិធីបុណ្យទានផ្សេងៗ

- បានផ្សព្វផ្សាយព្រះធម៌តាមលទ្ធភាព ដើម្បីអប់រំកូនៗរបស់មនុស្សវ័យចាស់ឱ្យយល់ដឹងអំពីសីលធម៌ព្រះពុទ្ធសាសនា។

+ **ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

- មនុស្សវ័យចាស់ដែលបានចូលរួមកម្មវិធីវប្បធម៌(សម្តែង ទស្សនា និងគាំទ្រជាដើម) នៅឆ្នាំ២០១៨ ឆ្នាំ២០១៩ និងឆ្នាំ២០២០។

+ **ក្រសួងអភិវឌ្ឍន៍ជនបទ**

- បានរៀបចំវគ្គផ្សព្វផ្សាយអំពីសារៈសំខាន់នៃការលើកកម្ពស់អនាម័យសម្រាប់ជនពិការនិងមនុស្សវ័យចាស់នៅក្នុងខេត្តគោលដៅទាំង៤ រួមមាន : ខេត្តកំពង់ឆ្នាំង ស្វាយរៀង កំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ
- បានចុះអប់រំផ្សព្វផ្សាយនិងជំរុញដល់ប្រជាជនតំបន់គោលដៅឱ្យសង់និងប្រើប្រាស់បង្គន់អនាម័យដែលជួយសម្រួលដល់ជនចាស់ជរា
- បានចុះសិក្សានិងស្វែងរកអ្នកផ្គត់ផ្គង់សម្ភារៈបង្គន់អនាម័យក្នុងខេត្តគោលដៅ
- ផ្តល់សម្ភារៈបង្គន់ដល់ប្រជាជនក្នុងភូមិគោលដៅក្នុងខេត្តទាំង៤ ចំនួន១៦០បង្គន់។

+ **ក្រសួងអប់រំ យុវជន និងកីឡា**

- រៀបចំសិក្ខាសាលាអប់រំផ្សព្វផ្សាយដល់បុគ្គលិកអប់រំវ័យចាស់ស្តីពីវិធានការបង្ការជំងឺឆ្លងនិងជំងឺមិនឆ្លងនិងការស្វែងរកសេវាគាំទ្រសុខភាពផ្លូវចិត្ត
- បានរៀបចំសិក្ខាសាលាបង្កើនការយល់ដឹងអំពីការងារស្មើគ្រចិត្ត និងសារៈសំខាន់ក្នុងការងារជួយជ្រោមជ្រែងដល់មនុស្សវ័យចាស់បង្កើតបណ្តាញស្មើគ្រចិត្តតាមសហគមន៍ចម្រុះ និងចុះពិនិត្យតាមដាន បានចំនួន៤លើក
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយស្តីពីធនធានមនុស្សពេញវ័យនៃកាយឫទ្ធិជាតិកម្ពុជានៅគ្រប់២៥រាជធានី ខេត្ត
- ផ្សព្វផ្សាយដល់សិស្សវិទ្យាល័យអំពីការងារស្មើគ្រចិត្តជួយដល់មនុស្សវ័យចាស់ជរាបានចំនួន២ដង
- ផ្សព្វផ្សាយដល់មនុស្សវ័យក្មេងឱ្យស្មើគ្រចិត្តជួយដល់មនុស្សវ័យចាស់និងសមាគមមនុស្សចាស់
- គណៈកម្មការមុខវិជ្ជាសិក្សាសង្គមបានសិក្សាដាក់បញ្ចូលអំពីការគោរពមនុស្សនៅជុំវិញខ្លួន និងការគោរពឪពុកម្តាយ មនុស្សវ័យចាស់លើមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា
- គណៈកម្មការមុខវិជ្ជាសិក្សាសង្គម មុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា បានសិក្សានិងដាក់បញ្ចូលខ្លឹមសារអំពីការគោរពឪពុកម្តាយ ជីដូនជីតា មនុស្សវ័យចាស់នៅក្នុងកម្មវិធីនិងសៀវភៅសិក្សាសម្រាប់បឋមសិក្សានិងមធ្យមសិក្សា
- បានចុះធ្វើតេស្តកាយសម្បទារាងកាយរបស់ប្រជាជនពីអាយុ២៥ឆ្នាំដល់៧៤ឆ្នាំ នៅខេត្តចំនួន១៣
- ការរៀបចំទិវាកីឡាដើម្បីទាំងអស់គ្នា ទិវាកីឡាអាស៊ាន ទិវាអាស៊ានហាត់ប្រាណដើម្បីសុខភាព
- បានធ្វើការអភិវឌ្ឍសមត្ថភាពនៃគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍លើការងារកសាងផែនការ ការគ្រប់គ្រង និងដឹកនាំមជ្ឈមណ្ឌលសិក្សាសហគមន៍។

+ **ក្រសួងសុខាភិបាល**

- បានផ្តល់សេវាព្យាបាលសុខភាពជូនដល់មនុស្សវ័យចាស់នៅតាមមូលដ្ឋានសុខាភិបាលជាប្រចាំ

- បានអនុវត្តជាប្រចាំក្នុងការបញ្ជូនអ្នកជំងឺដែលជាមនុស្សវ័យចាស់ដែលមានជំងឺពុំរ៉ើរ៉ើផ្សេងៗទៅមូលដ្ឋានសុខាភិបាលដែលមានសេវាសុខភាពឯកទេស និងតាមដានបន្ត
- បានបញ្ចូលនិងចុះអភិបាលលើសេវាថែទាំមនុស្សវ័យចាស់ទៅក្នុងកញ្ចប់សេវាMPA ត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ២០១៩ នៅតាមមណ្ឌលសុខភាព រួមទាំងឱសថដែលចាំបាច់សម្រាប់មនុស្សវ័យចាស់
- បានត្រួតពិនិត្យ ធ្វើរោគវិនិច្ឆ័យ និងព្យាបាលជំងឺរបស់មនុស្សវ័យចាស់នៅតាមមន្ទីរពេទ្យជាតិជាប្រចាំ
- បានផ្តល់សេវាសុខាភិបាលដោយមិនយកថ្លៃដល់មនុស្សវ័យចាស់ក្រីក្រនៅគ្រប់មូលដ្ឋានសុខាភិបាលដែលមិនមានលទ្ធភាពបង់ថ្លៃសេវាវេជ្ជសាស្ត្រ
- បានពង្រឹងការអនុវត្តមូលនិធិសមធម៌ ដើម្បីធានាថា មនុស្សទីទ័លក្រនិងងាយរងគ្រោះបានទទួលផលពេញលេញ
- បានបង្កើតនិងដាក់ដំណើរការមជ្ឈមណ្ឌលព្យាបាលជំងឺមនុស្សចាស់ព្រះសីហនុរាជ នៅក្នុងបរិវេណមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតនៅឆ្នាំ២០១៨ និងដកពិសោធសម្រាប់ជំហានបន្ទាប់នៅឆ្នាំ២០១៩
- បានរៀបចំកែលម្អសេវាពិនិត្យ ព្យាបាលជំងឺពុំរ៉ើរ៉ើរបស់មនុស្សវ័យចាស់ឱ្យមានលក្ខណៈឆ្លើយតបនិងប្រកបដោយគុណភាព។

+ ក្រសួងផែនការ

- បានបោះពុម្ពនិងបញ្ជូនទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីបង្កើនការយល់ដឹងជាសាធារណៈ តាមរយៈការបោះពុម្ពនិងចែកចាយកូនសៀវភៅសង្ខេបអំពីគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ ទាំងភាសាខ្មែរ និងទាំងភាសាអង់គ្លេស
- បានរៀបចំវគ្គបណ្តុះបណ្តាលបញ្ជ្រាបការយល់ដឹងអំពីគោលនយោបាយជាតិប្រជាជន និងប្រជាជនដល់គ្រប់មន្ទីរផែនការ។

+ ក្រសួងមុខងារសាធារណៈ

- បានរៀបចំប្រព័ន្ធព័ត៌មានវិទ្យាដើម្បីកំណត់មូលដ្ឋានទិន្នន័យស្តីពីចំនួនមន្ត្រីរាជការស៊ីវិលទាំងអស់ដែលបានចូលនិវត្តន៍
- ចំពោះចំនួនមន្ត្រីរាជការស៊ីវិលដែលចូលនិវត្តន៍ ហើយនៅបន្តបម្រើការងារ ក្រសួងមុខងារសាធារណៈអាចគ្រប់គ្រងបានតែចំនួនមន្ត្រីរាជការស៊ីវិលដែលចូលនិវត្តន៍ ហើយនៅបន្តបម្រើការងារក្នុងមុខតំណែងនយោបាយ ដូចជាមុខតំណែងរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា ជំនួយការ និងមន្ត្រីដែលមានឋានៈស្មើដែលទទួលប្រាក់បំណាច់ពីរដ្ឋាភិបាល។ ដោយឡែក ក្រសួងមុខងារសាធារណៈ ពុំមានមូលដ្ឋានទិន្នន័យក្នុងករណីមន្ត្រីរាជការស៊ីវិលដែលចូលនិវត្តន៍ ហើយនៅបន្តបម្រើការងារជាមន្ត្រីកិច្ចសន្យានោះទេ។

+ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- រៀបចំសិក្ខាសាលាបង្កើនការយល់ដឹងអំពីការងារពាក់ព័ន្ធនឹងកសិកម្ម
- ជំរុញការដាំដំណាំGAP និងចិញ្ចឹមសត្វ
- បានផ្តល់បច្ចេកទេសកសិកម្ម(ដំណាំស្រូវ បន្លែ ដំណាំសាកវប្បកម្ម...) ដល់មនុស្សវ័យចាស់បាន ៦០០ឃុំ

- ការរៀបចំកម្មវិធីជួបជុំមន្ត្រីចូលនិវត្តន៍នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបាន២ដងក្នុងមួយឆ្នាំ។

+ **ក្រសួងកិច្ចការនារី**

- បានរៀបចំផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ជាពិសេសមនុស្សវ័យចាស់ស្ត្រីទី២(ឆ្នាំ២០១៤-២០១៨)
- បានរៀបចំផែនការយុទ្ធសាស្ត្រដើម្បីសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី នារីរតនៈទី៤(ឆ្នាំ២០១៤-២០១៨) (យុទ្ធសាស្ត្រទី២ : កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី រួមបញ្ចូលមនុស្សវ័យចាស់)
- បានរៀបចំសេចក្តីព្រាងការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាទី៤ ដោយដំពូកទី១: ដោយដាក់បញ្ចូលមនុស្សវ័យចាស់ជាក្រុមងាយរងគ្រោះ
- បានរៀបចំក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបេសកកម្មសំខាន់ គឺការពង្រឹងកិច្ចសហការនិងការឆ្លើយតបទៅនឹងតម្រូវការជនរងគ្រោះ រួមទាំងមនុស្សវ័យចាស់ បានរៀបចំគោលការណ៍ណែនាំ បទដ្ឋានអប្បបរមាស្តីពីច្បាប់ពាក់ព័ន្ធ គោលការណ៍បញ្ជូន បទដ្ឋានអប្បបរមាប្រឹក្សាជាមូលដ្ឋានដល់ជនរងគ្រោះ ដោយរាប់បញ្ចូលមនុស្សវ័យចាស់
- បានធ្វើការផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការរំលោភបំពានផ្លូវភេទ ការជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារដល់សហគមន៍ និងបានអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ដោយគិតគូរសំខាន់លើការផ្តល់កិច្ចការពារដល់មនុស្សវ័យចាស់
- បានពង្រឹងសមត្ថភាពអ្នកផ្តល់សេវាអំពីរបៀបគាំទ្រ ការឆ្លើយតប ផ្នែកផ្លូវចិត្ត ច្បាប់ សេវាសង្គមដល់ជនរងគ្រោះ ជនងាយរងគ្រោះ ឱ្យមានប្រសិទ្ធភាពនិងទាន់ពេលវេលា
- បានរៀបចំក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបេសកកម្មសំខាន់ គឺការពង្រឹងកិច្ចសហការនិងការឆ្លើយតបទៅនឹងតម្រូវការជនរងគ្រោះ រួមទាំងមនុស្សវ័យចាស់
- ផ្តល់សេវាជួយគាំទ្រ(ប្រឹក្សាយោបល់ផ្លូវចិត្ត ផ្នែកច្បាប់ និងធ្វើការសម្របសម្រួលបញ្ជូនទៅសេវាពាក់ព័ន្ធ រួមទាំងសេវាមេធាវី) ជូនដល់ជនរងគ្រោះដោយអំពើហិង្សា ជាពិសេសមនុស្សវ័យចាស់
- បានរៀបចំគោលការណ៍ណែនាំ បទដ្ឋានអប្បបរមាស្តីពីច្បាប់ពាក់ព័ន្ធ គោលការណ៍បញ្ជូន បទដ្ឋានអប្បបរមាប្រឹក្សាជាមូលដ្ឋានដល់ជនរងគ្រោះ ដោយរាប់បញ្ចូលមនុស្សវ័យចាស់។

+ **ក្រសួងសាធារណការនិងដឹកជញ្ជូន**

- មិនគិតថ្លៃធ្វើដំណើរតាមរថយន្តក្រុងសម្រាប់មនុស្សវ័យចាស់១០០% ចាប់ពីអាយុ៦០ឆ្នាំឡើងទៅ ដោយអនុវត្តតាមប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ចាប់ពីឆ្នាំ២០១៨ រហូតដល់បច្ចុប្បន្ននេះ
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីពាណិជ្ជកម្មតាមមធ្យោបាយសាធារណៈ និងគិតគូរលើតម្លៃធ្វើដំណើរសាធារណៈដោយមិនយកប្រាក់ឬយកតម្លៃតិចជាងធម្មតាសម្រាប់មនុស្សវ័យចាស់១វគ្គ នៅឆ្នាំ២០១៩

- អនុវត្តបានតែការងារមួយចំនួននៅក្នុងរថយន្តក្រុង ដូចជា : មានកៅអីអង្គុយ បង្កាន់ដៃគោងឡើង ភ្នាក់ងារសម្រួលជូនមនុស្សវ័យចាស់
- បានចុះសកម្មភាពការងារមួយចំនួនលើការត្រួតពិនិត្យទីស្នាក់ការនិងស្ថានីយអ្នកដំណើររបស់ក្រុមហ៊ុនដឹកជញ្ជូនក្នុងប្រទេស។

+ **ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់ : គិតចាប់តាំងពីចាប់ផ្តើមអនុវត្តរហូតដល់ខែវិច្ឆិកា ឆ្នាំ២០២០ បានរៀបចំនិងអនុម័តផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់ ចំនួន៨៧ឃុំ សង្កាត់ បញ្ចប់ការសិក្សាបានចំនួន៧៦ឃុំ សង្កាត់ និងកំពុងដំណើរការចំនួន៩០ឃុំ សង្កាត់ ដែលអនុវត្តនៅរាជធានីភ្នំពេញនិង ១៩ខេត្ត
- ប្លង់គោលប្រើប្រាស់ថ្នាក់ស្រុក ខណ្ឌ ទីប្រជុំជន : គិតចាប់តាំងពីចាប់ផ្តើមអនុវត្តរហូតដល់ខែវិច្ឆិកា ឆ្នាំ២០២០ បានសម្រេចដូចខាងក្រោម : ១)បានអនុម័តដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ ទីប្រជុំជនបានចំនួន៧ រួមមាន : ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនទីរួមខេត្តត្បូងឃ្មុំ ទីប្រជុំជនកោះរ៉ុង ស្រុកបរិបូណ៌ ខណ្ឌជ្រោយចង្វារ ខណ្ឌសែនសុខ ទីប្រជុំជនជ្រៃធំនៃស្រុកកោះធំ និង ទីប្រជុំជនស្វាយអន្ទរនៃស្រុកស្វាយអន្ទរ។ ២)បានបញ្ចប់ការសិក្សាកសាងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ ទីប្រជុំជនបានចំនួន២១ រួមមាន : ស្រុកកំពង់ត្រាច ខេត្តកំពត ខណ្ឌមានជ័យ ខណ្ឌព្រែកព្នៅ ខណ្ឌដូនពេញ ខណ្ឌទួលគោក ខណ្ឌ៧មករា ខណ្ឌច្បារអំពៅ និងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទីប្រជុំជនអ្នកលឿង(ឃុំអ្នកលឿង ស្រុកពាមរក៍) ខេត្តព្រៃវែង ស្រុកអង្គរជុំ ស្រុកក្រឡាញ់ ស្រុកអង្គរធំ ស្រុកបន្ទាយស្រី ស្រុកដីក្រែង ស្រុកពួក ស្រុកប្រាសាទបាគង ស្រុកសូទ្រនិគម ស្រុកស្រីស្នំ ស្រុកស្វាយលើ និងស្រុកវ៉ារិន ខេត្តសៀមរាប ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី។ ៣)កំពុងដំណើរការកសាងប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ ទីប្រជុំជនបានចំនួន៣២ រួមមាន : ស្រុកជើងព្រៃនិងស្រុកព្រៃឈរ ខេត្តកំពង់ចាម ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ស្រុកកណ្តាលស្ទឹង ស្រុកកៀនស្វាយ ស្រុកខ្សាច់កណ្តាល ស្រុកកោះធំ ស្រុកលើកដែក ស្រុកល្វាឯម ស្រុកមុខកំពូល ស្រុកអង្គស្នួល ស្រុកពញាឮ និងស្រុកស្អាង ខេត្តកណ្តាល ស្រុកចិត្របុរី ខេត្តក្រចេះ ខណ្ឌចំការមន ខណ្ឌដង្កោ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌឫស្សីកែវ និងខណ្ឌកំបូល រាជធានីភ្នំពេញ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ស្រុកអណ្តូងមាស ស្រុកកូនមុំ ស្រុកលំផាត់ ស្រុកតាវែង និងស្រុករ៉ូនសៃ ខេត្តរតនគិរី ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ស្រុកសេសាន ស្រុកសៀមបូក ស្រុកសៀមប៉ាង និងស្រុកថាឡាបរីវ៉ាត់ ខេត្តស្ទឹងត្រែង ស្រុកគិរីវង់ ខេត្តតាកែវ ស្រុកដំណាក់ចង្អើរ ខេត្តកែប
- ប្លង់គោលនិងផែនការប្រើប្រាស់ដីធ្លីថ្នាក់ក្រុង : គិតចាប់តាំងពីចាប់ផ្តើមអនុវត្តរហូតដល់ខែវិច្ឆិកា ឆ្នាំ ២០២០ បានសម្រេចដូចខាងក្រោម : ១)បានអនុម័តដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង បានចំនួន១០ រួមមានក្រុងតាខ្មៅ ក្រុងបាត់ដំបង ក្រុងកំពត ក្រុងកែប ក្រុងសៀមរាប ក្រុងខេមរភូមិន្ទ គម្រោងអភិវឌ្ឍក្រុងបូកគោ ក្រុងបាវិត ក្រុងប៉ោយប៉ែត និងក្រុងស្ទឹងត្រែង។ ២)បានបញ្ចប់ការសិក្សាកសាងប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុងបានចំនួន៦ រួមមានក្រុងព្រះសីហនុ ក្រុងកំពង់ចាម ក្រុងក្រចេះ

ក្រុងដូនកែវ ក្រុងព្រៃវែង និងក្រុងច្បារមន។ ៣)កំពុងដំណើរការសិក្សាប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុងបានចំនួន៤ រួមមានក្រុងកំពង់ឆ្នាំង ក្រុងព្រះវិហារ ក្រុងស្វាយរៀង និងក្រុងសួង

- ផែនការរៀបចំដែនដីថ្នាក់រាជធានី ខេត្ត : គិតចាប់តាំងពីចាប់ផ្តើមអនុវត្តរហូតដល់ខែវិច្ឆិកា ឆ្នាំ២០២០ បានសម្រេចដូចខាងក្រោម : ១)បានរៀបចំនិងអនុម័តដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដី និងផែនការរៀបចំដែនដីថ្នាក់រាជធានី ខេត្ត ចំនួន៣ រួមមាន ១- ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ។ ២- ផែនការប្រើប្រាស់ដីខេត្តព្រះសីហនុ និង៣- ផែនការប្រើប្រាស់ដីខេត្តបាត់ដំបង។ ២)បានបញ្ចប់ការសិក្សានិងកំពុងស្នើសុំការអនុម័តដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តតាកែវ។ ៣)បានរៀបចំនិងកំពុងដំណើរការរៀបចំដែនដីថ្នាក់ខេត្តចំនួន៧ រួមមាន ខេត្តសៀមរាប ខេត្តប៉ៃលិន ខេត្ត មណ្ឌលគិរី ខេត្តកំពង់ធំ ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម និងខេត្តក្រចេះ
- សម្បទានដីសង្គមសម្រាប់គ្រួសារប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅ : បានធ្វើការបែងចែកដីឡូត៍លំនៅឋាននិងដីសម្រាប់បង្កបង្កើនផលជូនគ្រួសារអតីតយុទ្ធជនចំនួន១០៧គ្រួសារ ស្ថិតនៅឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ និងចំនួន១៧៨គ្រួសារ ស្ថិតនៅឃុំចុងកាល់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ។ បានចាប់ឆ្នោតយកឡូត៍ដីដំហានទី៣ ជូនមុខសញ្ញាទទួលដីសម្បទានសង្គមកិច្ចក្រុម៩៩៨ គ្រួសារនិងក្រុម៣៥៣គ្រួសារ ចំនួន១៣៨គ្រួសារក្នុងចំណោម១៩៥គ្រួសារ នៅសាលាស្រុកឆ្លូង ខេត្តក្រចេះ
- សាងសង់ផ្ទះជូនគ្រួសារកងទ័ពនគរបាលនិងអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ : ការងារសាងសង់ផ្ទះជូនគ្រួសារកងទ័ពនិងនគរបាលជាតិប្រចាំឆ្នាំ២០២០ ចំនួន៥៣៣ខ្នង(សហការជាមួយអគ្គិសនីកម្ពុជាចំនួន៣៦ខ្នង)នៅខេត្តស្ទឹងត្រែង ខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារសម្រេចបានលទ្ធផល : ផ្ទះចំនួន៣២០ខ្នងសម្រេចបាន១០០% ផ្ទះចំនួន២០ខ្នងសម្រេចបាន៨៤% ផ្ទះចំនួន ១៥ខ្នងសម្រេចបាន៦២% ផ្ទះចំនួន២ខ្នងសម្រេចបាន៣៥% ផ្ទះចំនួន៣៨ខ្នងសម្រេចបាន៣%។ ជារួមការសាងសង់សម្រេចបាន៧៩,៦៨% និងសម្ភារៈនៅក្នុងការដ្ឋានមានចំនួន១៣,៦៩%។
- បានចេញសេចក្តីសម្រេចលេខ០៣៩ សសរ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់ស្តាបត្យកម្មចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយានយន្តសម្រាប់សាធារណជននិងជនពិការ និងបានផ្សព្វផ្សាយជូនដល់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្ត
- បានផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យនគរូបនីយកម្មនិងសំណង់ : ១)អនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ស្តីពីលិខិតអនុញ្ញាតសាងសង់។ ២)អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន។ ៣)អនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥ស្តីពីការកែសម្រួលនៃអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ខេត្ត និងទីប្រជុំជន។ ៤)សេចក្តីណែនាំលេខ០០២ ដនស/សណន ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០២០ស្តីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់

- បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តលើការរៀបចំសណ្តាប់ធ្នាប់សំដៅបម្រើឱ្យគោលដៅក្នុងការធ្វើចរាចរណ៍ប្រកបដោយសុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួលដល់សាធារណជននិងជនពិការ។

+ **ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**

- បានផ្សព្វផ្សាយច្បាប់នានាដើម្បីគាំពារដល់មនុស្សវ័យចាស់មានដូចជា៖
  ១)ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
  ២)ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
  ៣)ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

+ **គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ**

- បានផ្សព្វផ្សាយព័ត៌មានអំពីកម្មវិធីកាត់បន្ថយគ្រោះមហន្តរាយ ដែលមានការរាប់បញ្ចូលមនុស្សវ័យចាស់ទៅដល់សមាគមមនុស្សចាស់ចំនួន៤០សមាគម និងបានផ្សព្វផ្សាយដល់សាធារណជនអំពីការជួយជ្រោមជ្រែងដល់មនុស្សវ័យចាស់នៅពេលជួបប្រទះគ្រោះអាសន្ន
- បានជំរុញឱ្យមានការចូលរួមរបស់មនុស្សវ័យចាស់ពាក់ព័ន្ធទៅនឹងការកាត់បន្ថយគ្រោះមហន្តរាយ
- បានបោះពុម្ពសៀវភៅផ្សព្វផ្សាយដើម្បីបង្ការករណីមានគ្រោះអាសន្នផ្សេងៗចំនួន២០០០ក្បាលនៅឆ្នាំ២០១៨ ចំនួន៥០០០ក្បាលនៅឆ្នាំ២០១៩ និងចំនួន៥០០០ក្បាលនៅឆ្នាំ២០២០
- បានរៀបចំវគ្គបណ្តុះបណ្តាលជាច្រើន មានដូចជានៅឆ្នាំ២០១៨(៨០វគ្គ) ឆ្នាំ២០១៩(៤៨វគ្គ) និងនៅឆ្នាំ២០២០(៥៨វគ្គ)ដើម្បីឱ្យមានការយល់ដឹងអំពីការត្រៀមខ្លួនទប់ទល់នឹងគ្រោះមហន្តរាយ និងការពារហានិភ័យ ដូចជាការជួយសង្គ្រោះនិងផ្តល់ទីជម្រកដល់មនុស្សវ័យចាស់ កុមារ និងជនពិការ អ្នកបម្រើការងារជួយសង្គ្រោះ ឬស្ថារសម្បទាមនុស្សវ័យចាស់ឱ្យយល់ដឹងអំពីបញ្ហាមនុស្សវ័យចាស់ក្នុងកំឡុងពេលមានគ្រោះអាសន្ន និងក្រុមវេជ្ជសាស្ត្រអំពីជំនាញផ្នែកមនុស្សវ័យចាស់ សម្រាប់ មនុស្សវ័យចាស់នៅពេលជួបគ្រោះមហន្តរាយ។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដ៏គ្រចះគ្រចង់នេះ យោងតាមរបាយការណ៍របស់ក្រសួង ស្ថាប័នពាក់ព័ន្ធក៏បានបង្ហាញឱ្យឃើញថា ការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៨-២០២០នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ បានតិចតួចនៅឡើយ ដោយសារតែផែនការសកម្មភាពឆ្នាំ២០១៨-២០២០ អនុម័តនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨ ជាហេតុនាំឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធមិនបានលើកគម្រោងថវិកានៅឆ្នាំ២០១៧ ដើម្បីអនុវត្តផែនការសកម្មភាពនៅឆ្នាំ២០១៨។ បន្ទាប់មក នៅឆ្នាំ២០១៨ ក្រសួង ស្ថាប័នពាក់ព័ន្ធចាប់ផ្តើមលើកគម្រោងថវិកាសម្រាប់អនុវត្តនៅឆ្នាំ២០១៩។ ក្រោយមកទៀត នៅឆ្នាំ២០២០ ក្រសួង ស្ថាប័នពាក់ព័ន្ធភាគច្រើនមិនបានអនុវត្តសកម្មភាព ដោយសារតែជំងឺកូវីដ-១៩ដែលបានរីករាលដាលជាសកលជាហេតុនាំឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធមិនអាចអនុវត្តសកម្មភាពដូចមានចែងក្នុងផែនការសកម្មភាពឆ្នាំ២០១៨-២០២០បានទេ។ ស្របពេលជាមួយគ្នានេះ ផែនការសកម្មភាពឆ្នាំ២០១៨-២០២០នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ក៏មានបញ្ហាប្រឈមសេសសល់និងបញ្ហាប្រឈមថ្មីៗមួយចំនួន ដែលជាកត្តាចម្បងនាំឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធមិនអាចអនុវត្តសកម្មភាពដែលខ្លួនបានលើកឡើង ប៉ុន្តែ បញ្ហាប្រឈមទាំងនោះនឹងត្រូវលើកយកមកបង្ហាញជារួមនៅក្នុងផ្នែកបន្ទាប់។ ទោះបីជាយ៉ាងណាក៏ដោយ ក្រសួង ស្ថាប័នពាក់ព័ន្ធបានធ្វើការប្តេជ្ញាចិត្តបន្តខិតខំប្រឹងប្រែងថែមទៀត ក្នុងការធ្វើឱ្យសម្រេចបានតាមផែនការដែលបានគ្រោងទុក ដើម្បីរួមចំណែកក្នុងការលើកកម្ពស់សុខុមាលភាពមនុស្សវ័យចាស់ឱ្យកាន់តែល្អប្រសើរឡើង។

១.៣_បញ្ហាអាទិភាព

បញ្ហាប្រឈមនៃការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៨-២០២០នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ នឹងត្រូវធ្វើការលើកឡើងនៅក្នុងផ្នែកនេះ។ បញ្ហាប្រឈមទាំងនោះ រួមមាន៖

+ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

- មិនទាន់មានសន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញាអន្តរជាតិស្តីពីមនុស្សវ័យចាស់ និងច្បាប់ស្តីពីការលើកកម្ពស់និងការការពារសិទ្ធិមនុស្សវ័យចាស់ដូចបណ្តាប្រទេសក្នុងតំបន់អាស៊ាន
- កត្តាបម្រែបម្រួលក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០១៦-២០២៥
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការលើកកម្ពស់សុខុមាលភាពមនុស្សវ័យចាស់មិនទាន់មានលក្ខណៈគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមនិងតម្រូវការរបស់មនុស្សវ័យចាស់(ដូចជារបបសន្តិសុខសង្គម សុខភាព សិទ្ធិ ការផ្តល់ឱកាសការងារ ការថែទាំរយៈពេលវែង និងសេវាសាធារណៈផ្សេងៗ។ល។)
- មិនទាន់មានលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់ក្នុងការគ្រប់គ្រងមន្ទីរពេទ្យ មជ្ឈមណ្ឌល មណ្ឌលសុខភាពសមាគម អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនចំពោះជនជាតិខ្មែរនិងបរទេសលើការបណ្តុះបណ្តាលជំនាញថែទាំមនុស្សវ័យចាស់ពាក់ព័ន្ធទៅនឹងការផ្តល់សេវាថែទាំមនុស្សវ័យចាស់
- មិនទាន់មានឯកសារសម្រាប់ធ្វើការបណ្តុះបណ្តាលជំនាញចិត្តសាស្ត្រនិងសុខភាពផ្លូវកាយនិងផ្លូវចិត្តដល់អ្នកថែទាំតាមផ្ទះក្នុងការផ្តល់សេវាថែទាំដល់មនុស្សវ័យចាស់
- មិនទាន់រៀបចំសៀវភៅ បង្កើតខិត្តបណ្ណ និងផ្សព្វផ្សាយណែនាំស្តីពីការបង្ការករណីមានគ្រោះមហន្តរាយឬគ្រោះអាសន្នផ្សេងៗសម្រាប់ការពារមនុស្សវ័យចាស់
- ខ្វះការសិក្សាស្រាវជ្រាវអំពីតម្រូវការផ្នែកច្បាប់ គោលការណ៍ណែនាំស្តីពីការថែទាំរយៈពេលវែងនិងខ្លីនៅតាមមណ្ឌលនិងសហគមន៍ និងបញ្ហាប្រឈមនិងតម្រូវការសម្រាប់មនុស្សវ័យចាស់(ដូចជាបញ្ហាសន្តិសុខហិរញ្ញវត្ថុ បញ្ហាសុខភាពផ្លូវកាយនិងផ្លូវចិត្ត ការរំលោភបំពាន មិនអើពើ អើសអើង ហិង្សា និងតម្រូវការលើអាហារូបត្ថម្ភ។ល។
- មិនទាន់មានការសិក្សាស្រាវជ្រាវអំពីលទ្ធភាពក្នុងការពង្រីកសេវាដឹកជញ្ជូនសាធារណៈដល់មនុស្សវ័យចាស់ដោយឥតគិតថ្លៃ នៅគ្រប់២៥រាជធានី ខេត្ត និងសមត្ថភាពនិងផលិតភាពរបស់មនុស្សវ័យចាស់នៅក្នុងការបំពេញការងារនៅតាមវិស័យសាធារណៈនិងវិស័យឯកជន
- ខ្វះការសិក្សាស្រាវជ្រាវអំពីវត្តអារាមនិងអារាមសាសនាដែលអាចផ្តល់ទីជម្រកនិងកន្លែងស្នាក់នៅសម្រាប់មនុស្សវ័យចាស់ដែលរងគ្រោះនិងងាយរងគ្រោះ
- សមាគមមនុស្សចាស់ គឺជាអង្គការសហគមន៍ដែលបង្កើតឡើងក្នុងគោលបំណងចង់ឱ្យមនុស្សវ័យចាស់ចេះជួយគ្នាទៅវិញទៅមក លើកកម្ពស់ជីវភាព គុណភាពជីវិត និងសេចក្តីថ្លៃថ្នូររបស់មនុស្សវ័យចាស់ ប៉ុន្តែសមាគមមនុស្សចាស់ពុំមានលទ្ធភាពក្នុងការចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ ដូចមានចែងក្នុងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលឆ្នាំ២០១៥ បានឡើយ

- មិនមានកម្មវិធីផ្សព្វផ្សាយអំពីសារៈសំខាន់នៃសិទ្ធិ តួនាទី ការចូលរួម អប់រំសុខភាព ការរំលោភបំពានមិនអើពើ អើសអើង ហិង្សា និងគ្រោះមហន្តរាយដល់មនុស្សវ័យចាស់នៅគ្រប់២៥រាជធានី ខេត្ត
- មិនទាន់រៀបចំកិច្ចប្រជុំពិភាក្សាស្តីពីការពិនិត្យលទ្ធភាពក្នុងការវិភាជថវិកាមូលនិធិឃុំ សង្កាត់ ដើម្បីជួយដល់ដំណើរការ និងទ្រទ្រង់ដល់សមាគមមនុស្សចាស់នៅគ្រប់២៥រាជធានី ខេត្ត និងកម្មវិធីប្រឡងប្រណាំងស្តីពីការនិពន្ធ ការផលិតស្ប៉តពាក់ព័ន្ធទៅនឹងវិស័យការងាររបស់មនុស្សវ័យចាស់នៅតាមសហគមន៍
- មិនទាន់ផ្តល់ការបណ្តុះបណ្តាល ដូចជាសមាជិកគ្រួសារ អ្នកថែទាំមនុស្សវ័យចាស់ ដែលមានអ្នកជំងឺជាមនុស្សវ័យចាស់ឱ្យមានការយល់ដឹងអំពីរបៀបរបបនៃការថែទាំ ចិត្តសាស្ត្រ ព័ត៌មាន និងសេវាផ្សេងៗ
- ខ្វះថវិកាសម្រាប់ការបណ្តុះបណ្តាលសមាជិកសមាគមអំពីដំណើរការរបស់សមាគមនិងកម្មវិធីដែលអាចជួយដល់សមាជិកសមាគម និងកម្មវិធីស្វែងរកថវិកាដើម្បីទ្រទ្រង់សមាគម
- ខ្វះថវិកាសម្រាប់បណ្តុះបណ្តាលអប់រំណែនាំ និងបង្កើនការយល់ដឹងដល់យុវជន ឱ្យចេះត្រៀមខ្លួនមុនពេលឈានចូលវ័យចាស់ តាមរយៈការអប់រំឱ្យចេះសន្សំថវិកា សុខភាពផ្លូវកាយនិងផ្លូវចិត្ត អនាម័យ និងរបបអាហារ
- ខ្វះថវិកាសម្រាប់ធ្វើការផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ និងផែនការសកម្មភាពនៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ ដល់គ្រឹះស្ថានអប់រំសាធារណៈនិងឯកជន សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធ និង២៥រាជធានី ខេត្ត
- ខ្វះថវិកាដើម្បីធ្វើការផ្សព្វផ្សាយអំពីបញ្ហាជំងឺនានាដែលមនុស្សវ័យចាស់តែងតែប្រឈម និងវិធានការបង្ការមុនពេលឈានចូលវ័យចាស់
- មិនមានថវិកាសម្រាប់រៀបចំសិក្ខាសាលាចែករំលែកបទពិសោធនៃការបង្កើតនិងគ្រប់គ្រងសមាគមមនុស្សចាស់នៅតាមរាជធានី ខេត្ត
- ខ្វះថវិកាសម្រាប់បោះពុម្ពខិត្តបណ្ណនិងសៀវភៅស្តីពីការបង្ការករណីមានគ្រោះមហន្តរាយឬគ្រោះអាសន្នផ្សេងៗសម្រាប់ការពារមនុស្សវ័យចាស់
- ពុំមានថវិកាសម្រាប់គាំទ្រដល់ដំណើរការសមាគមមនុស្សចាស់ឃុំ សង្កាត់ កញ្ចប់សង្គ្រោះបន្ទាន់ ចុះសួរសុខទុក្ខ និងចុះពង្រឹងការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ ទាំង២៥រាជធានី ខេត្ត
- ខ្វះថវិកាសម្រាប់សាងសង់ស្ថានីយទឹកស្អាតសម្រាប់សហគមន៍របស់គាត់ និងរៀបចំកម្មវិធីកៀរគរសប្បុរសជននិងដៃគូអភិវឌ្ឍសម្រាប់គាំទ្រដល់សមាគមមនុស្សចាស់
- សកម្មភាពមួយចំនួនមិនអាចអនុវត្តបាន ដោយសារតែការរីករាលដាលនៃជំងឺកូវីដ-១៩
- ខ្វះដៃគូអភិវឌ្ឍសម្រាប់គាំទ្រដល់ការអនុវត្តសកម្មភាព
- មិនទាន់មានមូលនិធិទ្រទ្រង់មនុស្សវ័យចាស់
- ដៃគូអភិវឌ្ឍនិងសប្បុរសជនគាំទ្រដល់សមាគមមនុស្សចាស់ នៅមានកម្រិតនៅឡើយ។

+ **ក្រសួងទេសចរណ៍**

- ការចូលរួមពីភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍នៅមានកម្រិត ជាពិសេសវិស័យឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍនានា
- ការចូលរួមវគ្គបណ្តុះបណ្តាលមិនបានពេញលេញ ព្រោះជាប់រវល់ប្រតិបត្តិការ
- មនុស្សវ័យចាស់ភាគច្រើនពុំមានជំនាញឆ្លើយតបតាមតម្រូវការការងាររបស់សហគមន៍ ដោយសារបញ្ហាសុខភាពដែលធ្វើឱ្យការចូលរួមរបស់មនុស្សវ័យចាស់ពុំមាននិរន្តរភាព។

+ **ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- មិនមានថវិកាសម្រាប់រៀបចំកម្មវិធីជួបជុំចែករំលែកបទពិសោធនិងសក្តានុពលរបស់មនុស្សវ័យចាស់ដល់មនុស្សជំនាន់ក្រោយ
- មិនទាន់មានការសិក្សាស្រាវជ្រាវអំពីលទ្ធភាពរបស់វិស័យឯកជន និងសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងការទទួលយកមនុស្សវ័យចាស់ដើម្បីបំពេញការងារ និងការរស់នៅប្រកបដោយសុវត្ថិភាពសម្រាប់មនុស្សវ័យចាស់
- មិនទាន់មានគោលការណ៍ណែនាំស្តីពីការរស់នៅប្រកបដោយសុវត្ថិភាពសម្រាប់មនុស្សវ័យចាស់
- ខ្វះថវិកាសម្រាប់រៀបចំសិក្ខាសាលាលើកកម្ពស់និងបង្កើនការយល់ដឹងអំពីបញ្ហាប្រឈមនិងតម្លៃនៃការចូលរួមរបស់មនុស្សវ័យចាស់ក្នុងគ្រួសារ សហគមន៍ និងសង្គមទៅដល់មនុស្សជំនាន់ក្រោយ និងអប់រំផ្សព្វផ្សាយស្តីពីសុវត្ថិភាពចំណីអាហារ អាហារមានសុវត្ថិភាព និងរបបអាហារមានតុល្យភាព
- មិនមានថវិកាសម្រាប់រៀបចំកម្មវិធីជួបជុំចែករំលែកបទពិសោធនិងសក្តានុពលរបស់មនុស្សវ័យចាស់ដល់មនុស្សជំនាន់ក្រោយ
- មិនទាន់មានការសិក្សាស្រាវជ្រាវអំពីលទ្ធភាពរបស់វិស័យឯកជន និងសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការទទួលយកមនុស្សវ័យចាស់ដើម្បីបំពេញការងារ
- ខ្វះការសិក្សាស្រាវជ្រាវអំពីការរស់នៅប្រកបដោយសុវត្ថិភាពសម្រាប់មនុស្សវ័យចាស់
- មិនទាន់មានគោលការណ៍ណែនាំស្តីពីការរស់នៅប្រកបដោយសុវត្ថិភាពសម្រាប់មនុស្សវ័យចាស់
- ខ្វះថវិកាសម្រាប់រៀបចំសិក្ខាសាលាអប់រំផ្សព្វផ្សាយស្តីពីសុវត្ថិភាពចំណីអាហារ អាហារមានសុវត្ថិភាព និងរបបអាហារមានតុល្យភាព
- ខ្វះថវិកាសម្រាប់រៀបចំសិក្ខាសាលាលើកកម្ពស់និងបង្កើនការយល់ដឹងអំពីបញ្ហាប្រឈមនិងតម្លៃនៃការចូលរួមរបស់មនុស្សវ័យចាស់ក្នុងគ្រួសារ សហគមន៍ និងសង្គម ទៅដល់មនុស្សជំនាន់ក្រោយ។

+ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- ការរៀបចំដាក់ឱ្យដំណើរការកម្មវិធីគាំពារជនចាស់ជរា មិនទាន់មានការសិក្សាច្បាស់លាស់លើទិដ្ឋភាពមួយចំនួន ដូចជាការកំណត់លក្ខណៈនិច្ឆ័យអ្នកទទួលផល កម្រិតអត្ថប្រយោជន៍ ការសិក្សាលទ្ធភាពសម្រាប់ការកំណត់អត្តសញ្ញាណអ្នកទទួលផលនិងស្ថាប័នអនុវត្ត ព្រមទាំងការរៀបចំអភិវឌ្ឍសមត្ថភាពស្ថាប័ន។ ទន្ទឹមនឹងនេះ កម្មវិធីគាំពារជនចាស់ជរានឹងត្រូវដាក់ឱ្យដំណើរការជាកម្មវិធីកញ្ចប់គ្រួសារដែលត្រូវបានសម្រេចឱ្យមានការសិក្សានៅរយៈពេលមធ្យមក្រោមកម្មវិធីកញ្ចប់គ្រួសារ និងមានការចង្អុលបង្ហាញលម្អិត ដូចក្នុងស្មារតីលិខិតលេខ ៥១៣១ សហវ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩។

+ **ក្រសួងមហាផ្ទៃ**

- មិនទាន់មានការជំរុញឱ្យមានការបញ្ចូលបញ្ហាទាក់ទងទៅនឹងមនុស្សវ័យចាស់ ទៅក្នុងផែនការវិនិយោគរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

+ **ក្រសួងសុខាភិបាល**

- ខ្វះធនធានមនុស្សដែលមានឯកទេសលើបញ្ហាសុខភាពមនុស្សវ័យចាស់នៅតាមមណ្ឌលសុខភាព
- មិនទាន់បង្កើតផ្នែកពិគ្រោះ ព្យាបាល និងផ្តល់យោបល់ពាក់ព័ន្ធការតាមដានលើសុខភាពមនុស្សវ័យចាស់នៅតាមមណ្ឌលសុខភាព និងមិនទាន់មានយន្តការការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃចំពោះការផ្តល់សេវាសុខភាពមូលដ្ឋានដល់មនុស្សវ័យចាស់ ដើម្បីធានាថា ការផ្តល់សេវានោះប្រកបដោយប្រសិទ្ធភាពខ្ពស់
- ខ្វះថវិកាសម្រាប់បណ្តុះបណ្តាល ដូចជាគ្រូពេទ្យជំនាញពិគ្រោះយោបល់ផ្នែកសុខភាពមនុស្សវ័យចាស់នៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងមន្ទីរពេទ្យជំនាញព្យាបាលមនុស្សវ័យចាស់ និងក្រមសីលធម៌វិជ្ជាជីវៈដល់បុគ្គលិកសុខាភិបាលនៅតាមមូលដ្ឋានសុខាភិបាល ខ្វះថវិកាសម្រាប់បណ្តុះបណ្តាលនិងផ្តល់ឧបករណ៍ចាំបាច់ដល់ក្រុមស្មគ្រចិត្តសុខភាពភូមិដែលមានស្រាប់ និងដែលត្រូវជ្រើសរើសថ្មី(បើចាំបាច់) ដើម្បីតាមដានស្ថានភាពមនុស្សវ័យចាស់
- ខ្វះថវិកាសម្រាប់គាំទ្រដល់មន្ត្រីពាក់ព័ន្ធ ដើម្បីទស្សនកិច្ចសិក្សាឈ្វេងយល់ក្នុងការផ្តល់សេវាថែទាំ និងសេវាសុខភាពដល់មនុស្សវ័យចាស់ពីបណ្តាប្រទេសជិតខាងនិងថ្នាក់តំបន់
- ខ្វះថវិកាសម្រាប់រៀបចំសិក្ខាសាលាស្តីពីការអប់រំផ្លូវចិត្តឱ្យមានការជឿជាក់លើខ្លួនឯង និងសម្រាប់រៀបចំសិក្ខាសាលាអប់រំផ្សព្វផ្សាយស្តីពីវិធានការបង្ការជំងឺឆ្លងនិងជំងឺមិនឆ្លង និងស្វែងរកសេវាគាំទ្រសុខភាពផ្លូវចិត្ត
- ពុំមានលទ្ធភាពក្នុងការបង្កើតក្រុមស្មគ្រចិត្តភូមិ ដោយមានបច្ចេកវិទ្យាគាំទ្រនិងងាយស្រួលតាមដានស្ថានភាពមនុស្សវ័យចាស់
- មិនទាន់បង្កើត ដូចជាផ្នែកផ្តល់សេវាសុខភាពដល់មនុស្សវ័យចាស់នៅមន្ទីរពេទ្យថ្នាក់ជាតិ និងបង្កើតឬបន្ថែមសេវា(និងបង្កើតជាផ្នែក)ស្តារសុខភាពរបស់មនុស្សវ័យចាស់(Rehabilitation service) ទៅកញ្ចប់សេវាសំណុំសកម្មភាពពេញលេញទៅថ្នាក់មន្ទីរពេទ្យបង្អែកនិងកម្រិតខេត្ត
- មិនទាន់បានរៀបចំតារាងសូចនាករថ្មីទាក់ទងទៅនឹងមនុស្សវ័យចាស់ដែលត្រូវបញ្ចូលទៅក្នុងប្រព័ន្ធរាយការណ៍ជាប្រចាំរបស់វិស័យសុខាភិបាល
- មិនទាន់រៀបចំកម្មវិធីសិក្សាឯកសារបណ្តុះបណ្តាលជំនាញព្យាបាលសុខភាពមនុស្សវ័យចាស់ ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិកសុខាភិបាលនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក មន្ទីរពេទ្យថ្នាក់ខេត្តនិងថ្នាក់ជាតិ
- មិនមានថវិកាសម្រាប់បំពាក់នូវសម្ភារៈបរិក្ខារសមស្របសម្រាប់មន្ទីរពេទ្យនីមួយៗ ក្នុងការថែទាំព្យាបាលមនុស្សវ័យចាស់ និងមិនមានថវិកាសម្រាប់ផ្តល់នូវឱសថឱ្យបានគ្រប់គ្រាន់និងមានគុណភាពសម្រាប់ការព្យាបាលមនុស្សវ័យចាស់(ដាក់បញ្ចូលទៅក្នុងបញ្ជីឱសថសារវន្តរបស់ក្រសួងសុខាភិបាល)

- មិនទាន់មាន ដូចជាសេវាថែទាំនិងព្យាបាលតាមផ្ទះចំពោះមនុស្សវ័យចាស់ដែលត្រូវការថែទាំរយៈពេលវែង រៀបចំការពិភាក្សាកម្រិតនយោបាយស្តីពីការថែទាំរយៈពេលវែង(ទាំងនៅតាមសហគមន៍និងតាមមណ្ឌលថែទាំ) និងរៀបចំកម្មវិធីសិក្សាវិជ្ជាជីវៈថែទាំសុខភាពមនុស្សវ័យចាស់នៅតាមសាលាគ្រឹះស្ថានអប់រំសុខភាពសាធារណៈនិងឯកជន
- មិនទាន់រៀបចំកម្មវិធីសិក្សាវិជ្ជាជីវៈថែទាំសុខភាពមនុស្សវ័យចាស់នៅតាមសាលា គ្រឹះស្ថានអប់រំសុខភាពសាធារណៈនិងឯកជន
- កៀរគរនិងពង្រឹងការសហការជាមួយអង្គការសង្គមស៊ីវិលដែលធ្វើការលើការងារសុខភាពមនុស្សវ័យចាស់។

+ **ក្រសួងកិច្ចការនារី**

- មានការលំបាកក្នុងការកំណត់ថវិកាប៉ាន់ស្មានសម្រាប់សកម្មភាពដែលបានលើកឡើងក្នុងផែនការសកម្មភាព ព្រោះថវិការបស់ក្រសួង ស្ថាប័នប្រើប្រាស់សម្រាប់តែសកម្មភាពដែលស្ថិតនៅក្នុងផែនការសកម្មភាពរបស់ក្រសួង ស្ថាប័នតែប៉ុណ្ណោះ។

+ **ក្រសួងសាធារណការនិងដឹកជញ្ជូន**

- មិនទាន់បានរៀបចំសម្ភារៈដែលបង្កភាពងាយស្រួលដល់មនុស្សវ័យចាស់ក្នុងការធ្វើដំណើរតាមមធ្យោបាយសាធារណៈ
- កំពុងរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត និងមិនមានថវិកាអនុវត្តការសិក្សាស្តីពីលទ្ធភាពក្នុងការផ្តល់សេវាធ្វើដំណើរទៅធ្វើការរបស់កម្មករ និយោជិតវ័យចាស់
- មិនបានផ្សព្វផ្សាយពីការកំណត់តម្លៃឬមិនយកថ្លៃចំពោះមធ្យោបាយធ្វើដំណើរសាធារណៈចំពោះកម្មករ និយោជិតវ័យចាស់ ព្រោះមិនមានកញ្ចប់ថវិកាជាតិផ្តល់ឱ្យរៀបចំការផ្សព្វផ្សាយ
- ខ្វះថវិកាដើម្បីអនុវត្តគម្រោងបំពាក់សម្ភារៈដែលបង្កភាពងាយស្រួលដល់មនុស្សវ័យចាស់ក្នុងការធ្វើដំណើរតាមមធ្យោបាយសាធារណៈ
- ខ្វះថវិកាដើម្បីអនុវត្តគម្រោងគ្រប់គ្រង តាមដាន និងត្រួតពិនិត្យលើការធ្វើចំណតនិងស្ថានីយអ្នកដំណើររបស់ក្រុមហ៊ុនដឹកជញ្ជូនក្នុងប្រទេស។

+ **ក្រសួងមុខងារសាធារណៈ**

- ពុំមានមូលដ្ឋានទិន្នន័យក្នុងករណីមន្ត្រីរាជការស៊ីវិលដែលចូលនិវត្តន៍ ទទួលបានឱកាសបន្តបម្រើការងារនៅក្នុងអង្គភាពដើម
- មិនទាន់មានក្រុមការងារទទួលបន្ទុកលើការងារមនុស្សវ័យចាស់ នៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ។

+ **ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

- មិនមានថវិកាសម្រាប់បង្កើតកម្មវិធីAppsពាក់ព័ន្ធទៅនឹងបញ្ហាប្រឈមនិងតម្រូវការរបស់មនុស្សវ័យចាស់ដល់សាធារណជនដើម្បីជ្រាបជាព័ត៌មាន ក៏ដូចជាចេះត្រៀមខ្លួនមុននឹងឈានដល់វ័យចាស់
- មិនទាន់រៀបចំឱ្យមានបណ្តាញទំនាក់ទំនងតាមបណ្តាញទូរគមនាគមន៍និងបច្ចេកវិទ្យាទំនើប។

+ **ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- មិនទាន់មានលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងអគារសាធារណៈនិងអគាររបស់វិស័យឯកជន

- មិនទាន់មានគោលការណ៍ណែនាំស្តីពីការរៀបចំហេដ្ឋារចនាសម្ព័ន្ធទៅតាមទីសាធារណៈដែលបង្កភាពងាយស្រួលដល់មនុស្សវ័យចាស់ងាយស្រួលធ្វើដំណើរ
- មិនទាន់រៀបចំសួនច្បារសាធារណៈឱ្យបានសមស្របដែលមានបរិក្ខារគ្រប់គ្រាន់បម្រើឱ្យការហាត់ប្រាណដែលមានលក្ខណៈអំណោយផលដល់មនុស្សឈានចូលវ័យចាស់និងមនុស្សវ័យចាស់។

+ **គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ**

- មិនទាន់មានទិន្នន័យអំពីការចូលរួមរបស់មនុស្សវ័យចាស់ពាក់ព័ន្ធការកាត់បន្ថយគ្រោះមហន្តរាយ។

១.៤- ដំណោះស្រាយបញ្ហាប្រឈម

ដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈមខាងលើ ក្រសួង ស្ថាប័នពាក់ព័ន្ធគួរតែ៖

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យលទ្ធភាពក្នុងការផ្តល់ថវិកាសម្រាប់អនុវត្តផែនការសកម្មភាពនៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេស ផ្តោតសំខាន់លើក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តផ្ទាល់
- បង្កើតច្បាប់ស្តីពីការលើកកម្ពស់និងការការពារសិទ្ធិមនុស្សវ័យចាស់
- រៀបចំច្បាប់ គោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តគួរផ្តោតសំខាន់ទៅលើមនុស្សវ័យចាស់ដូចជាកុមារផងដែរ
- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការលើកកម្ពស់សុខុមាលភាពមនុស្សវ័យចាស់ឱ្យមានលក្ខណៈគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមនិងតម្រូវការរបស់មនុស្សវ័យចាស់(ដូចជារបបសន្តិសុខសង្គម សុខភាព សិទ្ធិ ការផ្តល់ឱកាងារ ការថែទាំរយៈពេលវែង និងសេវាសាធារណៈផ្សេងៗ។ល។)
- សិក្សាស្រាវជ្រាវអំពីតម្រូវការផ្នែកច្បាប់សម្រាប់មនុស្សវ័យចាស់
- សិក្សាស្រាវជ្រាវអំពីវត្តអារាមនិងអារាមសាសនាថា តើអាចផ្តល់ទីជម្រកនិងកន្លែងស្នាក់នៅសម្រាប់មនុស្សវ័យចាស់ដែលរងគ្រោះនិងងាយរងគ្រោះ
- សិក្សាស្រាវជ្រាវអំពីបញ្ហាប្រឈមនិងតម្រូវការរបស់មនុស្សវ័យចាស់(ដូចជាបញ្ហាសន្តិសុខហិរញ្ញវត្ថុ បញ្ហាសុខភាពផ្លូវកាយនិងផ្លូវចិត្ត ការរំលោភបំពាន មិនអើពើ រើសអើង អំពើហិង្សា និងតម្រូវការលើអាហារូបត្ថម្ភ។ល។)
- រៀបចំលិខិតបទដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងមន្ទីរពេទ្យ មជ្ឈមណ្ឌល មណ្ឌលសុខភាព សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនពាក់ព័ន្ធទៅនឹងការផ្តល់សេវាថែទាំនិងការបណ្តុះបណ្តាលជំនាញថែទាំមនុស្សវ័យចាស់
- ក្រសួងមហាផ្ទៃគួរពិចារណាលើកលែងក្នុងការចុះបញ្ជីសមាគមនុស្សចាស់ ដើម្បីផ្តល់ភាពងាយស្រួលនិងលើកទឹកចិត្តដល់មនុស្សវ័យចាស់បង្កើតសមាគមក្នុងគោលបំណងលើកកម្ពស់ជីវភាព គុណភាពជីវិត និងសេចក្តីថ្លៃថ្នូររបស់មនុស្សវ័យចាស់
- រៀបចំលិខិតបទដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងជនបរទេសដែលប្រកបជំនាញថែទាំនិងបណ្តុះបណ្តាលជំនាញថែទាំមនុស្សវ័យចាស់

- សិក្សាស្រាវជ្រាវអំពីសមត្ថភាពនិងផលិតភាពរបស់មនុស្សវ័យចាស់នៅក្នុងការបំពេញការងារនៅតាមវិស័យសាធារណៈ វិស័យឯកជន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- សិក្សាស្រាវជ្រាវអំពីលទ្ធភាពរបស់វិស័យឯកជន និងសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងការទទួលយកមនុស្សវ័យចាស់ដើម្បីបំពេញការងារ
- រៀបចំកម្មវិធីផ្សព្វផ្សាយអំពីការរំលោភបំពាន មិនអើពើ រើសអើងនិងអំពើហិង្សាទៅលើមនុស្សវ័យចាស់
- សិក្សាស្រាវជ្រាវអំពីគោលនយោបាយថែទាំរយៈពេលវែង
- សិក្សាស្រាវជ្រាវអំពីគោលនយោបាយថែទាំនៅតាមសហគមន៍និងមណ្ឌលថែទាំ
- សិក្សាស្រាវជ្រាវអំពីលទ្ធភាពក្នុងការពង្រីកសេវាដឹកជញ្ជូនសាធារណៈដល់មនុស្សវ័យចាស់ដោយឥតគិតថ្លៃនៅគ្រប់២៥រាជធានី ខេត្ត
- រៀបចំឯកសារសម្រាប់បណ្តុះបណ្តាលអំពីសុខភាពផ្លូវកាយនិងផ្លូវចិត្ត
- សិក្សាស្រាវជ្រាវអំពីការរស់នៅប្រកបដោយសុវត្ថិភាពសម្រាប់មនុស្សវ័យចាស់
- រៀបចំសិក្ខាសាលាស្តីពីការអប់រំផ្លូវចិត្តឱ្យមានការជឿជាក់លើខ្លួនឯង
- ផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ ដល់គ្រឹះស្ថានអប់រំសាធារណៈនិងឯកជន សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំគោលការណ៍ណែនាំស្តីពីការរស់នៅប្រកបដោយសុវត្ថិភាពសម្រាប់មនុស្សវ័យចាស់
- រៀបចំសម្ភារៈដែលបង្កភាពងាយស្រួលដល់មនុស្សវ័យចាស់ ក្នុងការធ្វើដំណើរតាមមធ្យោបាយសាធារណៈ
- រៀបចំគោលការណ៍ណែនាំនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងអគារសាធារណៈនិងអគាររបស់វិស័យឯកជន ដើម្បីបង្កភាពងាយស្រួលដល់មនុស្សវ័យចាស់ងាយស្រួលធ្វើដំណើរ
- រៀបចំសិក្ខាសាលាអប់រំផ្សព្វផ្សាយស្តីពីវិធានការបង្ការជំងឺឆ្លងនិងជំងឺមិនឆ្លង និងស្វែងរកសេវាគាំទ្រសុខភាពផ្លូវចិត្ត
- រៀបចំសិក្ខាសាលាអប់រំណែនាំនិងបង្កើនការយល់ដឹងដល់មនុស្សពេញវ័យឱ្យចេះត្រៀមខ្លួនមុនពេលឈានចូលវ័យចាស់ តាមរយៈការអប់រំឱ្យចេះសន្សំថវិកា សុខភាពផ្លូវកាយនិងផ្លូវចិត្ត អនាម័យ និងរបបអាហារ
- បង្កើតកម្មវិធីAppsពាក់ព័ន្ធទៅនឹងបញ្ហាប្រឈមនិងតម្រូវការរបស់មនុស្សវ័យចាស់ដល់សាធារណជនដើម្បីជ្រាបជាព័ត៌មាន ក៏ដូចជាចេះត្រៀមខ្លួនមុននឹងឈានដល់វ័យចាស់
- ជំរុញឱ្យមានការបញ្ចូលបញ្ហាទាក់ទងទៅនឹងមនុស្សវ័យចាស់ទៅក្នុងផែនការវិនិយោគរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ
- បង្កើតផ្នែកពិគ្រោះ ព្យាបាល និងផ្តល់យោបល់ពាក់ព័ន្ធការតាមដានលើសុខភាពមនុស្សវ័យចាស់នៅតាមមណ្ឌលសុខភាព
- បណ្តុះបណ្តាលគ្រូពេទ្យជំនាញពិគ្រោះយោបល់ផ្នែកសុខភាពមនុស្សវ័យចាស់នៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងមន្ទីរពេទ្យ
- គាំទ្រដល់មន្ត្រីពាក់ព័ន្ធដើម្បីទស្សនកិច្ចសិក្សាឈ្វេងយល់ក្នុងការផ្តល់សេវាថែទាំនិងសេវាសុខភាពដល់មនុស្សវ័យចាស់ពីបណ្តាប្រទេសជិតខាងនិងថ្នាក់តំបន់

- បង្កើតក្រុមស្ម័គ្រចិត្តភូមិ ដោយមានបច្ចេកវិទ្យាគាំទ្រនិងងាយស្រួលតាមដានស្ថានភាពមនុស្សវ័យចាស់
- បណ្តុះបណ្តាលនិងផ្តល់ឧបករណ៍ចាំបាច់ដល់ក្រុមស្ម័គ្រចិត្តសុខភាពភូមិដែលមានស្រាប់និងត្រូវជ្រើសរើសថ្មី(បើចាំបាច់)ដើម្បីតាមដានស្ថានភាពមនុស្សវ័យចាស់
- បណ្តុះបណ្តាលដល់សមាគមមនុស្សចាស់នៅតាមឃុំ សង្កាត់ ក៏ដូចជាមន្ត្រីសង្គមកិច្ច ដើម្បីផ្តល់ការណែនាំដល់មនុស្សវ័យចាស់អំពីបញ្ហាសុខភាព និងជាយន្តការតាមដានមើលករណីមនុស្សវ័យចាស់នៅឯកោនិងងាយរងគ្រោះ
- បណ្តុះបណ្តាលជំនាញព្យាបាលមនុស្សវ័យចាស់និងក្រមសីលធម៌វិជ្ជាជីវៈដល់បុគ្គលិកសុខាភិបាលនៅតាមមូលដ្ឋានសុខាភិបាល
- មានយន្តការការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃចំពោះការផ្តល់សេវាសុខភាពមូលដ្ឋានដល់មនុស្សវ័យចាស់ ដើម្បីធានាថា ការផ្តល់សេវានោះប្រកបដោយប្រសិទ្ធភាពខ្ពស់
- បង្កើតឬបន្ថែមសេវា(និងបង្កើតជាផ្នែក)ស្តារសុខភាពមនុស្សវ័យចាស់(Rehabilitation service) ទៅកញ្ចប់សេវាសំណុំសកម្មភាពពេញលេញទៅថ្នាក់មន្ទីរពេទ្យបង្អែកនិងកម្រិតខេត្ត
- បង្កើតផ្នែកផ្តល់សេវាសុខភាព បំពាក់នូវសម្ភារៈបរិក្ខារសមស្រប និងផ្តល់ឱសថឱ្យបានគ្រប់គ្រាន់ ព្រមទាំងមានគុណភាពសម្រាប់ព្យាបាលមនុស្សវ័យចាស់នៅមន្ទីរពេទ្យថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- រៀបចំកម្មវិធីសិក្សា ឯកសារបណ្តុះបណ្តាលជំនាញព្យាបាលសុខភាពមនុស្សវ័យចាស់ ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិកសុខាភិបាលនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក មន្ទីរពេទ្យថ្នាក់ខេត្ត និងថ្នាក់ជាតិ
- រៀបចំការពិភាក្សាកម្រិតនយោបាយស្តីពីការថែទាំរយៈពេលវែង(ទាំងនៅតាមផ្ទះ សហគមន៍ និងតាមមណ្ឌលថែទាំ)
- រៀបចំកម្មវិធីសិក្សាវិជ្ជាជីវៈថែទាំសុខភាពមនុស្សវ័យចាស់នៅតាមសាលា គ្រឹះស្ថានអប់រំសុខភាពសាធារណៈនិងឯកជន
- បណ្តុះបណ្តាលដល់អ្នកថែទាំមនុស្សវ័យចាស់តាមផ្ទះឱ្យយល់ដឹងអំពីចំណេះដឹង ព័ត៌មាន និងសេវានានាដើម្បីជួយដល់មនុស្សវ័យចាស់នៅពេលជួបគ្រោះអាសន្ន
- មានក្រុមការងារទទួលបន្ទុកលើការងារមនុស្សវ័យចាស់នៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំវគ្គបណ្តុះបណ្តាលជំនាញចិត្តសាស្ត្រដល់អ្នកថែទាំតាមផ្ទះក្នុងការផ្តល់សេវាថែទាំដល់មនុស្សវ័យចាស់
- រៀបចំឯកសារសម្រាប់ធ្វើការបណ្តុះបណ្តាលជំនាញចិត្តសាស្ត្រដល់អ្នកថែទាំតាមផ្ទះក្នុងការផ្តល់សេវាថែទាំដល់មនុស្សវ័យចាស់
- ចុះពង្រឹងការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃអំពីដំណើរការរបស់សមាគមមនុស្សចាស់នៅគ្រប់២៥ រាជធានី ខេត្ត
- រៀបចំកិច្ចប្រជុំពិភាក្សាស្តីពីការពិនិត្យលទ្ធភាពក្នុងការវិភាជថវិកាមូលនិធិឃុំ សង្កាត់ ដើម្បីជួយដល់ដំណើរការនិងទ្រទ្រង់ដល់សមាគមមនុស្សចាស់នៅគ្រប់២៥រាជធានី ខេត្ត
- បណ្តុះបណ្តាលសមាជិកសមាគមអំពីដំណើរការរបស់សមាគមនិងកម្មវិធីដែលអាចជួយដល់សមាជិកសមាគម និងកម្មវិធីស្វែងរកថវិកាដើម្បីទ្រទ្រង់សមាគម

- រៀបចំកិច្ចប្រជុំពិភាក្សាជាមួយអនុគណៈកម្មាធិការដើម្បីមនុស្សវ័យចាស់នៅតាមរាជធានី ខេត្ត ដើម្បីរៀបចំសកម្មភាពគាំទ្រដល់មនុស្សវ័យចាស់និងសមាគមមនុស្សចាស់
- រៀបចំសិក្ខាសាលាចែករំលែកបទពិសោធនៃការបង្កើតនិងគ្រប់គ្រងសមាគមមនុស្សចាស់នៅតាមរាជធានី ខេត្ត
- បង្កើតនូវកម្មវិធីអប់រំសុខភាពនិងផ្សព្វផ្សាយអំពីសិទ្ធិទទួលបានរបស់មនុស្សវ័យចាស់
- រៀបចំកម្មវិធីប្រឡងប្រណាំងស្តីពីការនិពន្ធការផលិតស្បែតពាក់ព័ន្ធនឹងវិស័យការងាររបស់មនុស្សវ័យចាស់នៅតាមសហគមន៍
- រៀបចំកម្មវិធីផ្សព្វផ្សាយអំពីសារៈសំខាន់និងតួនាទីរបស់មនុស្សវ័យចាស់ និងការចូលរួមរបស់មនុស្សវ័យចាស់ក្នុងការអភិវឌ្ឍសហគមន៍និងសង្គម
- ចុះផ្សព្វផ្សាយនិងរៀបចំផែនការសកម្មភាពកាត់បន្ថយគ្រោះមហន្តរាយដល់មនុស្សវ័យចាស់និងសមាគមមនុស្សចាស់នៅគ្រប់២៥រាជធានី ខេត្ត
- រៀបចំឯកសារសម្រាប់ធ្វើការផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងអំពីបញ្ហាគ្រោះមហន្តរាយដល់សមាគមមនុស្សចាស់
- រៀបចំកញ្ចប់សង្គ្រោះបន្ទាន់សម្រាប់មនុស្សវ័យចាស់
- រៀបចំសៀវភៅនិងខិត្តបណ្ណណែនាំស្តីពីការបង្ការករណីមានគ្រោះមហន្តរាយ ឬគ្រោះអាសន្នផ្សេងៗសម្រាប់ការពារមនុស្សវ័យចាស់
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីកាត់បន្ថយគ្រោះមហន្តរាយពីបម្រែបម្រួលអាកាសធាតុដល់សមាគមមនុស្សចាស់នៅគ្រប់២៥រាជធានី ខេត្ត
- បោះពុម្ពខិត្តបណ្ណនិងសៀវភៅស្តីពីការបង្ការករណីមានគ្រោះមហន្តរាយឬគ្រោះអាសន្នផ្សេងៗសម្រាប់ការពារមនុស្សវ័យចាស់
- រៀបចំសិក្ខាសាលាអប់រំផ្សព្វផ្សាយស្តីពីសុវត្ថិភាពចំណីអាហារ អាហារមានសុវត្ថិភាព និងរបបអាហារមានតុល្យភាព
- រៀបចំសិក្ខាសាលាលើកកម្ពស់និងបង្កើនការយល់ដឹងអំពីបញ្ហាប្រឈមនិងតម្លៃនៃការចូលរួមរបស់មនុស្សវ័យចាស់ក្នុងគ្រួសារ សហគមន៍ និងសង្គមទៅដល់មនុស្សជំនាន់ក្រោយ។

២. ទិសដៅនិងយុទ្ធសាស្ត្រ

ដើម្បីសម្រេចបានតាមចក្ខុវិស័យនិងគោលដៅនៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ និងឆ្លើយតបទៅនឹងបញ្ហាទាំងឡាយដែលត្រូវបានរំពឹងទុកថា នឹងកើតមានឡើងជាមួយនឹងដំណើរឈានទៅរកវ័យចាស់ ដូចមានកំណត់ក្នុងផ្នែកទី៤នៃគោលនយោបាយជាតិនេះ។ ទិសដៅនិងយុទ្ធសាស្ត្រដើម្បីឆ្លើយតបទៅនឹងបញ្ហានីមួយៗត្រូវបានគូសបញ្ជាក់នៅក្នុងផ្នែកនេះ។ ការរៀបចំបញ្ហាអាទិភាពនៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០មិនបញ្ជាក់ថា អាទិភាពណាមួយមានសារៈសំខាន់ជាងអាទិភាពណាមួយនោះឡើយ។ ជាការពិត អាទិភាពជាច្រើនមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ហើយដូចនេះអាទិភាពទាំងអស់នោះមានសារៈសំខាន់ស្មើគ្នា។

២.១_ អាទិភាពទី១ : ការធានាឱ្យបានឆ្ងាសន្តិសុខហិរញ្ញវត្ថុ

ទិសដៅ១.១ : បង្កលក្ខណៈឱ្យមនុស្សចាស់អាចមានឱកាសបន្តធ្វើការងារដែលផ្តល់ផលប្រយោជន៍ក្នុងករណីដែលពួកគាត់ចង់ និងមានលទ្ធភាពអាចធ្វើបាន

យុទ្ធសាស្ត្រ៖

(i) បង្កើនការយល់ដឹងអំពីការរើសអើងនៅក្នុងការងារ ដោយផ្តែកលើអាយុក្នុងចំណោមអ្នកមានចំណែកពាក់ព័ន្ធសំខាន់ៗ រួមមានក្រុមមនុស្សចាស់ សហជីពកម្មករ និងសមាគមនិយោជក។

(ii) ជំរុញការបង្កើតក្របខ័ណ្ឌគាំទ្រផ្នែកច្បាប់សម្រាប់ករណីការរើសអើងផ្នែកអាយុ។

(iii) បញ្ជាបការយល់ដឹងដល់និយោជកអំពីបទពិសោធនិងសក្តានុពលវិជ្ជមានរបស់កម្មករនិងនិយោជិតចាស់។

(iv) ដាក់ឱ្យមានបទប្បញ្ញត្តិច្បាប់ដែលតម្រូវឱ្យនិយោជកផ្តល់នូវលក្ខខណ្ឌការងារ ដូចជាគ្រឿងបរិក្ខារដែលងាយប្រើប្រាស់ អាហារដែលផ្តល់សុខភាពល្អ សេវាសុខភាពមូលដ្ឋាន និងបរិស្ថានកន្លែងធ្វើការងារទូទៅដែលសមស្របសម្រាប់កម្មកនិយោជិតវ័យចាស់។

(v) សិក្សាអំពីលទ្ធភាពនៃការរៀបចំប្រព័ន្ធលើកទឹកចិត្តសម្រាប់សហគ្រាសដែលជួលបុគ្គលិក កម្មករនិយោជិតវ័យចាស់ ហើយនិងលើកទឹកចិត្តឱ្យសហគ្រាសទាំងនោះ ផ្តល់ការសម្រួលនិងលក្ខខណ្ឌការងារសមស្រប។

(vi) លើកកម្ពស់លទ្ធភាពអាចធ្វើការងារបានរបស់មនុស្សចាស់ តាមរយៈសមត្ថភាព ជំនាញដែលមានស្រាប់ ឬការបណ្តុះបណ្តាលឡើងវិញនិងការអប់រំជាប្រចាំ។

(vii) ពិចារណាដាក់ចេញនូវវិធានការដើម្បីសម្រួលដល់ការធ្វើដំណើរទៅធ្វើការរបស់កម្មករ និយោជិតវ័យចាស់ ដោយគិតគូរឱ្យមានតម្លៃសមរម្យសម្រាប់ការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ។

(viii) សិក្សាអំពីលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុសម្រាប់មនុស្សចាស់។

ឥសដៅ២.២ : ពង្រីកជែនគ្រប់ជណ្តប់នៃគម្រោងកិច្ចគាំពារសង្គមនិងសុខុមាលភាពសង្គមដែលមានលក្ខណៈទូលំទូលាយ

យុទ្ធសាស្ត្រ៖

(i) សិក្សាអំពីលទ្ធភាពក្នុងការដាក់ចេញឱ្យដំណើរការនូវកម្មវិធីគាំពារមនុស្សចាស់និងជនចាស់ជរាដែលជាសមាជិកនៃគ្រួសារដែលកាន់បណ្ណសមធម៌ ស្របតាមក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម។

(ii) ពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តនូវកម្រៃលគាំពារសង្គមជាជំហានៗ ដើម្បីធានាថា មនុស្សចាស់ដែលគ្មានប្រាក់សោធននិវត្តន៍ឬមានមិនគ្រប់គ្រាន់ ហើយដែលគ្មានសមាជិកគ្រួសារមើលថែ អាចទទួលបាននូវប្រាក់ចំណូលសមរម្យ ដើម្បីកុំឱ្យពួកគាត់ធ្លាក់ចូលទៅក្នុងភាពក្រីក្រ។

(iii) បង្កើនការយល់ដឹងនិងជំរុញកូនចៅជាមនុស្សពេញវ័យដែលមានលទ្ធភាពផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ឪពុកម្តាយឬជីដូនជីតាចាស់ជរានិងសាច់ញាតិជិតស្និទ្ធរបស់ខ្លួន ដើម្បីបំពេញករណីយកិច្ចរបស់ខ្លួនក្នុងនាមជាកូនចៅ។

២.២_ អាទិភាពទី២ : សុខភាពនិងសុខុមាលភាព

ឥសដៅ២.១ : ជំរុញលើកទឹកចិត្តឱ្យដំណើរឈានចូលវ័យចាស់ប្រកបដោយសុខភាពល្អ និងពង្រីកការថែទាំសុខភាពតាមលក្ខណៈការការពារជាមុន

យុទ្ធសាស្ត្រ៖

(i) រៀបចំឱ្យមានដំណើរការជីវិតមួយប្រកបដោយសុខភាពល្អពេលវ័យចាស់ និងមានការការពារទប់ស្កាត់ជំងឺ តាមរយៈការដាក់ឱ្យដំណើរការនូវការផ្តល់ព័ត៌មានដែលមានលក្ខណៈជាការអប់រំសម្រាប់មនុស្សចាស់ អ្នកមើលថែទាំ និងអ្នកផ្តល់សេវាសុខភាព រួមទាំងព័ត៌មានអំពីសារៈសំខាន់នៃសកម្មភាពផ្នែករាងកាយ អនាម័យល្អ និងរបបអាហារមានគុណ្យភាព។

(ii) រៀបចំឱ្យមានសេវាប្រឹក្សាយោបល់សម្រាប់មនុស្សចាស់នៅមណ្ឌលសុខភាព។

(iii) បង្កលក្ខណៈឱ្យមនុស្សចាស់ អាចទទួលបាននូវសេវាពិនិត្យសុខភាពជាប្រចាំសម្រាប់ការពិនិត្យតាមដាននិងព្យាបាល និងអាចមានលទ្ធភាពទទួលបានថ្នាំបង្ការសម្រាប់ការការពារទប់ស្កាត់ជំងឺ និងការលើកកម្ពស់សុខភាពនៅពេលវ័យចាស់។

(iv) បង្កើតប្រព័ន្ធតាមដាននៅទូទាំងប្រទេស ដើម្បីពិនិត្យតាមដានមើលមនុស្សចាស់ជរាដែលនៅឯកោ និងមនុស្សចាស់ដែលងាយរងគ្រោះ។

ឥសដៅ២.២ : បង្កើតសេវាសុខាភិបាលមួយដែលមានលក្ខណៈឆ្លើយតប ដែលអាចទទួលបាននិងធានាបាននូវសេវាព្យាបាលប្រកបដោយគុណភាព

យុទ្ធសាស្ត្រ៖

(i) ផ្តល់ឱ្យមូលដ្ឋានសុខាភិបាលដែលផ្តល់សេវាព្យាបាលសុខភាព នូវបុគ្គលិកគ្រប់គ្រាន់ប្រកបដោយវិជ្ជាជីវៈ មានក្រមសីលធម៌ និងនៅប្រចាំការ ដើម្បីផ្តល់សេវាសុខភាពមូលដ្ឋានដល់មនុស្សចាស់ រួមទាំងការបញ្ជូនទៅឱ្យសេវាសុខភាពឯកទេសនិងតាមដានបន្តផងដែរ។

(ii) ត្រៀមលក្ខណៈឱ្យមន្ទីពេទ្យថ្នាក់ជាតិ អាចផ្តល់នូវសេវាសុខភាពពេញលេញសម្រាប់មនុស្សចាស់ ក្នុងនោះ រួមទាំងការត្រួតពិនិត្យ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលផ្សេងៗ។

(iii) ដាក់ឱ្យមានអ្នកវិជ្ជាជីវៈសុខាភិបាល ដែលបានទទួលការបណ្តុះបណ្តាលអំពីសុខភាពមនុស្សចាស់នៅមជ្ឈមណ្ឌលសុខភាពទាំងអស់។

(iv) កសាងសមត្ថភាពឱ្យបានគ្រប់គ្រាន់នៅតាមមន្ទីរពេទ្យនានា ក្នុងការថែទាំអ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ ដើម្បីអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មនុស្សចាស់ក្នុងការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ។

(v) ពង្រីកវិសាលភាពគ្របដណ្តប់សេវាថែទាំសុខភាពប្រកបដោយគុណភាពដោយឥតគិតថ្លៃ និងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់មនុស្សចាស់ក្រីក្រ ដែលមានមានលទ្ធភាពបង់ថ្លៃសេវាវេជ្ជសាស្ត្រមួយចំនួន។

(vi) ធានាថា មន្ទីរពេទ្យរដ្ឋទាំងអស់មានសេវាវេជ្ជសាស្ត្រសម្រាប់មនុស្សចាស់ប្រកបដោយគុណភាព។

(vii) ធានាឱ្យមានឱសថសំខាន់ៗដែលត្រូវការជាទូទៅសម្រាប់ការព្យាបាលជំងឺដែលប៉ះពាល់មនុស្សចាស់។

ឥសដៅ២.៣ : ឆ្លើយតបនឹងតម្រូវការរបស់មនុស្សចាស់សម្រាប់ការថែទាំរយៈពេលវែង

យុទ្ធសាស្ត្រ៖

(i) ពិចារណារៀបចំឱ្យមានសេវាថែទាំនិងព្យាបាលតាមផ្ទះ ចំពោះមនុស្សចាស់ដែលត្រូវការការថែទាំរយៈពេលវែង ដោយសារពិការភាព ជំងឺរង្វេងវង្វាន់ឬជំងឺដល់អាយុជីវិត។

(ii) ផ្តល់ការបណ្តុះបណ្តាលនិងការលើកទឹកចិត្ត ដល់សមាជិកគ្រួសារដែលត្រូវការមើលថែអ្នកជំងឺរ៉ៃ ចាស់ទាំងឡាយណាដែលត្រូវការការមើលថែទាំរយៈពេលវែង។

(iii) ពិចារណារៀបចំបង្កើតមជ្ឈមណ្ឌលថែទាំ សម្រាប់មនុស្សចាស់ទាំងឡាយណាដែលត្រូវការការថែទាំរយៈពេលយូរ។

(iv) កែលម្អលទ្ធភាពទទួលបានការប្រើប្រាស់សេវាតាមមូលដ្ឋានសុខាភិបាល សម្រាប់ការពិនិត្យនិងការព្យាបាលជំងឺរ៉ាំរ៉ៃនានា ដូចជាជំងឺលើសសម្ពាធឈាម ជំងឺទឹកនោមផ្អែម ជំងឺសរសៃឈាមក្នុងខួរក្បាល ជំងឺមហារីក ជំងឺវង្វេងវង្វាន់ និងជំងឺបាត់បង់ការចងចាំ។

ឥសដៅ២.៤ : បន្តគិតគូរដោះស្រាយឱ្យមានបុគ្គលិកសុខាភិបាលគ្រប់គ្រាន់និងដែលមានការបណ្តុះបណ្តាល

យុទ្ធសាស្ត្រ៖

(i) វាយតម្លៃលើតម្រូវការអ្នកប្រកបវិជ្ជាជីវៈផ្នែកថែទាំសុខភាពនិងសង្គមកិច្ច និងរៀបចំកម្មវិធីអប់រំឬបណ្តុះបណ្តាលបន្ថែមសម្រាប់បុគ្គលិកទាំងនេះ ទៅតាមសេចក្តីត្រូវការនាពេលបច្ចុប្បន្ន។

(ii) លើកកម្ពស់ការអប់រំនិងការបណ្តុះបណ្តាលផ្នែកការថែទាំសុខភាពនិងការថែទាំមនុស្សចាស់ សម្រាប់អ្នកប្រកបវិជ្ជាជីវៈផ្នែកថែទាំសុខភាពនិងសង្គមកិច្ច អ្នកស្ម័គ្រចិត្ត និងអ្នកថែទាំ។

(iii) បណ្តុះឱ្យមាននៅក្នុងគំនិតរបស់អ្នកផ្តល់សេវាសុខភាព អំពីទិដ្ឋភាពវិជ្ជមានរបស់មនុស្សចាស់ ព្រមទាំងការយកចិត្តទុកដាក់និងការគោរពដែលមនុស្សចាស់សមតែទទួលបាន។

(iv) បង្កើនចំនួនអ្នកជំនាញដែលបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈជំងឺមនុស្សចាស់។

(v) ដាក់ឱ្យមានមុខវិជ្ជាសិក្សាស្តីពីការថែទាំសុខភាពមនុស្សចាស់ នៅគ្រប់កម្មវិធីសិក្សាវិជ្ជាជីវៈសុខាភិបាល។

២.៣_អាទិភាពទី៣ : រៀបរបបនៃការរស់នៅ

ឥសដៅ៣.១ : ការលើកទឹកចិត្តឱ្យមានដំណើរឈានចូលរួមចាស់នៅនឹងកន្លែងដែលមនុស្សចាស់កំពុងរស់នៅ

យុទ្ធសាស្ត្រ៖

(i) ផ្តល់ការបណ្តុះបណ្តាលមូលដ្ឋានដល់អ្នកថែទាំតាមផ្ទះក្នុងការថែទាំមនុស្សចាស់នូវចំណេះដឹងនិងព័ត៌មានអំពីសេវាមានសារប្រយោជន៍ និងការចាត់ចែងក្នុងស្ថានភាពមានអាសន្ន។

(ii) ផ្តល់ការប្រឹក្សាយោបល់ដល់អ្នកថែទាំតាមផ្ទះ ដើម្បីផ្តល់នូវភាពធូរស្រាលដល់ពួកគាត់ពីភាពតានតឹងផ្លូវចិត្ត ដែលជាលទ្ធផលកើតចេញពីការផ្តល់ការថែទាំ។

(iii) ជានាឱ្យមានការបង្កើននិងការកែលម្អការចុះទៅសួរសុខទុក្ខតាមផ្ទះដោយអ្នកបម្រើការសុខភាពនិងមន្ត្រីសុខុមាលភាពសង្គម។

(iv) លើកទឹកចិត្តឱ្យសហគ្រាសផ្តល់ការសម្រួលដល់និយោជិតទាំងឡាយណាដែលមានមនុស្សចាស់ជាសមាជិកគ្រួសារណាម្នាក់នៅផ្ទះដែលត្រូវការការថែទាំ។

(v) លើកទឹកចិត្តអ្នកស្ម័គ្រចិត្តតាមសហគមន៍ ឱ្យជួយជ្រោមជ្រែងដល់មនុស្សចាស់ជារនៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់ពួកគាត់។

(vi) ធ្វើឱ្យមនុស្សចាស់មានលទ្ធភាពកាន់តែងាយស្រួល ក្នុងការទាក់ទងជាមួយនឹងសមាជិកគ្រួសារនិងសេវាគ្រាអាសន្ន ក្នុងករណីដែលត្រូវការ។

(vii) ដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត ដើម្បីការពារមនុស្សចាស់ពីការរំលោភបំពានគ្រប់ទម្រង់លើមនុស្សចាស់(ការរំលោភបំពានលើផ្លូវកាយ ពាក្យសម្តី ហិរញ្ញវត្ថុ និងផ្លូវចិត្ត)។

ទិសដៅ៣.២ : ផ្តល់ការរៀបចំការរស់នៅសមស្របសម្រាប់មនុស្សចាស់ដែលពុំមានការគាំទ្រពីគ្រួសារ

យុទ្ធសាស្ត្រ៖

(i) ពិចារណារៀបចំបង្កើតមជ្ឈមណ្ឌលមនុស្សចាស់នៅតាមសហគមន៍សម្រាប់ផ្តល់ជម្រកដល់មនុស្សចាស់ដែលគ្មានទីពឹង។

(ii) ជួយជ្រោមជ្រែងនិងផ្តល់ប្រឹក្សាដល់វត្តអារាមឱ្យពង្រីកនិងកែលម្អមូលដ្ឋានវត្តអារាម សម្រាប់ជាជម្រកដល់មនុស្សចាស់ងាយរងគ្រោះ។

(iii) ពិចារណារៀបចំឱ្យមានបទដ្ឋានដែលមានលក្ខណៈសមស្រប សម្រាប់មជ្ឈមណ្ឌលសុខភាពនិងមនុស្សចាស់នៅតាមសហគមន៍។

(iv) បង្កើតឱ្យមានកញ្ចប់សង្គ្រោះបឋមសម្រាប់មនុស្សចាស់នៅក្នុងមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក។

២.៤_ អាទិភាពទី៤ : បរិស្ថានអំណោយផល

ទិសដៅ៤.១ : បង្កលក្ខណៈឱ្យមនុស្សចាស់អាចរស់នៅដោយឯករាជ្យបាន ប្រសិនបើពួកគាត់អាចនិងមានបំណងរស់នៅបែបបនេះ

យុទ្ធសាស្ត្រ៖

(i) ផ្តល់ព័ត៌មានដល់មនុស្សចាស់អំពីការបន្សុំដែលនឹងត្រូវធ្វើឡើង ដើម្បីបង្កលក្ខណៈឱ្យពួកគាត់អាចរស់នៅដោយមានសុវត្ថិភាព និងកាត់បន្ថយហានិភ័យនៃការជួបគ្រោះថ្នាក់នានា ដូចជាការដួលការអិលជាដើម។

(ii) គិតគូរពិចារណាជំរុញឱ្យមានសេវាមូលដ្ឋានសំខាន់ៗ សម្រាប់មនុស្សចាស់នៅតាមតំបន់ដែលមានមជ្ឈមណ្ឌលមនុស្សចាស់នៅតាមសហគមន៍។

(iii) ផ្តល់ដល់មនុស្សចាស់នូវលទ្ធភាពក្នុងការទាក់ទងរកជំនួយដែលអាចទុកចិត្តបាន ឬលទ្ធភាពក្នុងការទាក់ទាញចំណាប់អារម្មណ៍របស់មនុស្សដទៃទៀត ក្នុងករណីពួកគាត់ត្រូវការ។

ទិសដៅ៤.២ : ជួយសម្រួលដល់ការផ្លាស់ទីរបស់មនុស្សចាស់

យុទ្ធសាស្ត្រ៖

(i) កែលម្អមធ្យោបាយធ្វើដំណើរសាធារណៈ ដោយបញ្ចូលការគិតគូរដោះស្រាយសេចក្តីត្រូវការរបស់មនុស្សចាស់។

(ii) ផ្តល់ការយកចិត្តទុកដាក់លើទិដ្ឋភាពមនុស្សចាស់នៅតាមសំណង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈទាំងអស់ រួមមានផ្លូវថ្នល់ ផ្លូវថ្មើរជើង និងបង្គន់អនាម័យ ដើម្បីអាចផ្តល់លទ្ធភាពចេញចូលដោយងាយស្រួល និងច្រកឆ្លងកាត់ប្រកបដោយសុវត្ថិភាពសម្រាប់មនុស្សចាស់។

(iii) ផ្តល់គន្លងផ្លូវពិសេស និងមូលដ្ឋានសម្ភារៈ និងគ្រឿងបរិក្ខារដែលមិនបង្កឧបសគ្គដល់មនុស្សចាស់នៅកន្លែងសាធារណៈ ដូចជាទីផ្សារ ធនាគារជាដើម។

(iv) ដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត ដែលតម្រូវឱ្យអគារសាធារណៈទាំងអស់អាចចេញចូលបានដោយងាយស្រួលនិងដោយសុវត្ថិភាព សម្រាប់មនុស្សចាស់និងជនពិការ។

(v) លើកកម្ពស់ការយល់ដឹងអំពីមនុស្សចាស់តាមរយៈប្រព័ន្ធផ្សព្វផ្សាយសាធារណៈនានា។

២.៥_អាទិភាពទី៥ : សមាគមមនុស្សចាស់និងវ័យចាស់សកម្ម

ទិសដៅ៥.១ : គាំទ្រដល់ការបង្កើតសមាគមមនុស្សចាស់នៅទូទាំងប្រទេស

យុទ្ធសាស្ត្រ៖

(i) ពង្រឹងសមាគមមនុស្សចាស់ដែលមានស្រាប់ និងពង្រីកបណ្តាញឱ្យទៅដល់កម្រិតថ្នាក់ក្រោមជាតិ។

(ii) ផ្តល់មូលនិធិនិងផ្តល់ការសម្រួលដល់ការបង្កើតសមាគមមនុស្សចាស់នៅឃុំសង្កាត់។

(iii) ផ្តល់ការបណ្តុះបណ្តាលដល់សមាជិកសមាគមមនុស្សចាស់ស្តីពីការបង្កើតនិងដំណើរការសមាគមមនុស្សចាស់។

(iv) លើកទឹកចិត្តឱ្យមានទំនាក់ទំនងរវាងអង្គការមិនមែនរដ្ឋាភិបាលនិងរាជរដ្ឋាភិបាល ដើម្បីបង្កើតបណ្តាញប្រជាជនវ័យចាស់នៅគ្រប់វិស័យ។

(v) លើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ក្នុងការផ្តល់ប្រឹក្សាដល់គណៈកម្មាធិការគ្រប់គ្រងសមាគមមនុស្សចាស់និងក្នុងការចាត់ចែងសកម្មភាពរបស់ខ្លួន។

(vi) បង្កើតយន្តការមួយ ដែលតាមរយៈនេះ សមាគមមនុស្សចាស់អាចមានការប្រាស្រ័យទាក់ទងនិងផ្លាស់ប្តូរបទពិសោធជាមួយគ្នាជាប្រចាំ។

ទិសដៅ៥.២ : ពង្រឹងតួនាទីរបស់សមាគមមនុស្សចាស់

យុទ្ធសាស្ត្រ៖

(i) គាំទ្រដល់សមាគមមនុស្សចាស់ក្នុងការបង្កើតឡើងនូវសន្តិសុខនៃមូលដ្ឋានទ្រទ្រង់ជីវភាពរស់នៅតាមរយៈការបណ្តុះបណ្តាលពួកគាត់អំពីសកម្មភាពបង្កើតប្រាក់ចំណូល។

(ii) ផ្តល់ការបណ្តុះបណ្តាលដល់សមាគមមនុស្សចាស់អំពីការថែទាំសុខភាពមូលដ្ឋាន និងបង្កលក្ខណៈឱ្យពួកគាត់អាចបង្កើតនិងដំណើរការនូវគម្រោងថែទាំតាមផ្ទះ ហើយតាមរយៈនេះ ពួកគាត់អាចចូលរួមវិភាគទានក្នុងការលើកកម្ពស់ការថែទាំសុខភាព។

(iii) លើកកម្ពស់ស្មារតី"មនុស្សចាស់ជួយមនុស្សចាស់" ជាមូលដ្ឋានគ្រឹះរបស់សមាគមមនុស្សចាស់ដើម្បីលើកទឹកចិត្តដល់មនុស្សចាស់ដែលសកម្មនិងមានសុខភាពល្អជាងឱ្យជួយមនុស្សចាស់រួមជំនាន់ដែលមានសមត្ថភាពមិនសូវល្អដូចពួកគាត់។

២.៦_អាទិភាពទី៦ : ធំនាក់ធំនឆអន្តរជំនាន់

ទិសដៅ៦.១ : ពង្រីកឱកាសសម្រាប់ការចូលរួមរបស់មនុស្សចាស់នៅក្នុងជីវភាពសាធារណៈ

យុទ្ធសាស្ត្រ៖

(i) បង្កើតក្រុមមនុស្សចាស់នៅក្នុងអាជ្ញាធរមូលដ្ឋាននីមួយៗ ដើម្បីធានាបានថា មនុស្សចាស់មានសំឡេងនៅក្នុងដំណើរការនៃការសម្រេចចិត្ត ហើយសេចក្តីត្រូវការរបស់ពួកគាត់ត្រូវបានលើកយកមកពិចារណា។

(ii) ជានាថា មនុស្សចាស់ត្រូវបានធ្វើឱ្យមានការពាក់ព័ន្ធនៅក្នុងការរៀបចំនិងការអនុវត្តគោលនយោបាយទាំងឡាយដែលដៈឥទ្ធិពលដល់ពួកគាត់ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់មូលដ្ឋាន។

(iii) បង្កើតមូលដ្ឋានទិន្នន័យស្តីពីជំនាញរបស់អ្នកឯកទេសដែលបានចូលនិវត្តន៍ ធ្វើជាឧបករណ៍ប្រឹក្សាសម្រាប់សហគមន៍និងរដ្ឋបាលគ្រប់កម្រិត។

(iv) ផ្តល់ការសម្រួលដល់ការចូលរួមរបស់មនុស្សចាស់នៅក្នុងព្រឹត្តិការណ៍សាធារណៈនានា ដូចជាការចូលរួមនៅក្នុងការបោះឆ្នោត សកម្មភាពផ្នែកវប្បធម៌និងសាសនាជាដើម។

ទិសដៅ៦.២ : ជំរុញឱ្យមានឥរិយាបថវិជ្ជមានចំពោះជំណើរឈានដល់វ័យចាស់ និងមនុស្សចាស់

យុទ្ធសាស្ត្រ៖

(i) លើកកម្ពស់ការយល់ដឹងថា មនុស្សចាស់មិនមែនជាបន្ទុកលើសហគមន៍ទេ ប៉ុន្តែពួកគាត់នាំអត្ថប្រយោជន៍មកដល់សង្គមវិញ។

(ii) កែប្រែទស្សនៈខុសឆ្គងដែលថា មនុស្សចាស់ពុំមានគោលដៅប្រកបដោយអត្ថន័យសម្រាប់ពេលវេលាដែលនៅសេសសល់ក្នុងជីវិតរបស់ខ្លួនឡើយ ក្រៅពីការរង់ចាំសេចក្តីស្លាប់។

(iii) លើកទឹកចិត្តឱ្យមានការបង្កើតកម្មវិធីទូរទស្សន៍ វិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយទាំងឡាយដែលផ្តោតការយកចិត្តទុកដាក់លើការចូលរួមវិភាគទានរបស់មនុស្សចាស់និងតួនាទីដែលមនុស្សចាស់បានធ្វើនៅក្នុងសហគមន៍។

ទិសដៅ៦.៣ : ពង្រឹងទំនាក់ទំនងអន្តរជំនាន់

យុទ្ធសាស្ត្រ៖

(i) លើកទឹកចិត្តមនុស្សវ័យក្មេងឱ្យស្មើគ្រចិត្តជួយមនុស្សវ័យចាស់។

(ii) ជំរុញឱ្យមានការរៀបចំសកម្មភាពនានា ដែលមនុស្សគ្រប់វ័យទាំងអស់អាចចូលរួមបាន។

(iii) រៀបចំធ្វើបទបង្ហាញអមដោយការពិភាក្សាអំពីការបំពេញបន្ថែមគ្នាទៅវិញទៅមករបស់មនុស្សជំនាន់ខុសគ្នា សម្រាប់មនុស្សពេញវ័យនៅក្មេងនិងមនុស្សចាស់។

(iv) រៀបចំបណ្តុះបណ្តាលនិងគាំទ្រដល់មនុស្សចាស់ លើបញ្ហាការប្រើប្រាស់មធ្យោបាយប្រាស្រ័យទាក់ទងគ្នា ដូចជាទូរសព្ទដៃ ប្រព័ន្ធផ្សព្វផ្សាយសង្គម ជាដើម ដើម្បីឱ្យពួកគាត់រក្សានូវទំនាក់ទំនងជាមួយនឹងកូនចៅ ជាមួយមនុស្សពេញវ័យ និងសាច់ញាតិក្មេងៗដទៃទៀតរបស់ពួកគាត់។

(v) ដាក់បញ្ចូលវគ្គសិក្សាអំពីសារៈសំខាន់នៃការគោរពនិងការធ្វើទំនាក់ទំនងជាមួយនឹងមនុស្សចាស់នៅក្នុងកម្មវិធីសិក្សា ស្ថាប័នបណ្តុះបណ្តាលនិងសាលារៀននានា។

(vi) បង្ហាញជាសាធារណៈនូវសមិទ្ធផលរបស់មនុស្សចាស់ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ។

(vii) ផ្តល់កិត្តិយសដល់ស្នាដៃមានលក្ខណៈជាគំរូដែលមនុស្សចាស់សម្រេចបាន ដូចជាការងារស្មើគ្រចិត្តឬការងារច្នៃប្រឌិត ដោយផ្តល់ពានរង្វាន់និង/ឬវិញ្ញាបនបត្រទទួលស្គាល់ស្នាដៃ។

២.៧_ អាទិភាពទី៧ : ការរំលោភបំពាននិងអំពើហិង្សាលើមនុស្សចាស់

ទិសដៅ៧.១ : កាត់បន្ថយនិងទប់ស្កាត់ករណីនៃការរំលោភបំពានលើមនុស្សចាស់

យុទ្ធសាស្ត្រ៖

(i) ដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត ដើម្បីការពារមនុស្សចាស់ពីការរំលោភបំពាននិងអំពើហិង្សា។

(ii) បំពាក់បំប៉នចំណេះដឹងដល់មនុស្សចាស់ អំពីសណ្ឋាននៃការរំលោភបំពានលើមនុស្សចាស់និងសិទ្ធិរបស់ពួកគាត់ក្នុងការការពារខ្លួនពីការរំលោភបំពាននេះ។

(iii) លើកទឹកចិត្តមនុស្សចាស់ឱ្យរាយការណ៍អំពីការរំលោភបំពានលើមនុស្សចាស់ ឬពិភាក្សាអំពីករណីនៃការរំលោភបំពានលើមនុស្សចាស់ជាមួយនឹងសាច់ញាតិជិតស្និទ្ធ មិត្តភក្តិ ឬវេជ្ជបណ្ឌិតរបស់ពួកគាត់។

(iv) បញ្ជាបការយល់ដឹងដល់សហគមន៍អំពីសារៈសំខាន់នៃការរាយការណ៍នូវករណីជាក់ស្តែងបានកើតមានឬសូម្បីតែករណីសង្ស័យពីការរំលោភបំពានលើមនុស្សចាស់ដែលពួកគាត់បានដឹង។

(v) ផ្តល់សិទ្ធិឱ្យបុគ្គលិកសុខាភិបាលអាចស្រាវជ្រាវឈ្វេងយល់ ហើយក្នុងករណីចាំបាច់ រាយការណ៍ជូនអាជ្ញាធរពាក់ព័ន្ធអំពីករណីការរំលោភបំពានលើមនុស្សចាស់ដែលអ្នកជំងឺជាមនុស្សចាស់របស់ពួកគេបានឆ្លងកាត់។

ឥសដៅ៧.២ : ការការពារមនុស្សចាស់កុំឱ្យធ្លាក់ជាជនរងគ្រោះនៃអំពើហិង្សានិងបទឧក្រិដ្ឋ

យុទ្ធសាស្ត្រ៖

(i) ពង្រឹងសមត្ថភាពនគរបាលអំពីជំនាញដើម្បីការពារមនុស្សចាស់និងទប់ស្កាត់អំពើហិង្សាលើមនុស្សចាស់។

(ii) ជំរុញឱ្យសហគមន៍មានការយល់ដឹងអំពីបញ្ហាសុវត្ថិភាពរបស់មនុស្សចាស់ដែលរស់នៅតែម្នាក់ឯងក្នុងតំបន់របស់ពួកគាត់។

២.៨_ អាទិភាពទី៨ : ស្ថានភាពមានអាសន្ន

ឥសដៅ៨.១ : ជានាឱ្យមានកិច្ចខិតខំប្រឹងប្រែងក្នុងការសង្គ្រោះឬការស្តារសម្បទា ដោយផ្តល់ការយកចិត្តទុកដាក់សមស្របចំពោះមនុស្សចាស់

យុទ្ធសាស្ត្រ៖

(i) ផ្តល់អាទិភាពដល់មនុស្សចាស់ កុមារ និងជនពិការ នៅក្នុងផែនការកាត់បន្ថយហានិភ័យ ក្នុងនោះមានការប្រកាសភាពអាសន្នអំពីគ្រោះមហន្តរាយ ការជួយសង្គ្រោះ ការផ្តល់ទីជម្រក ក៏ដូចជានៅក្នុងការផ្តួចផ្តើមគំនិតអំពីការស្តារសម្បទាក្រោយពេលគ្រោះមហន្តរាយ។

(ii) លើកទឹកចិត្តឱ្យមានការចូលរួមពីមនុស្សចាស់ នៅក្នុងការរៀបចំផែនការកាត់បន្ថយគ្រោះមហន្តរាយនៅគ្រប់កម្រិតទាំងអស់ ដើម្បីឱ្យបានគំនិតយោបល់ទៅលើបញ្ហានានាទាក់ទងនឹងបញ្ហាមនុស្សចាស់។

(iii) បណ្តុះបណ្តាលអ្នកបម្រើការងារជួយសង្គ្រោះ ឬស្តារសម្បទាឱ្យអាចកំណត់ទីតាំងដែលមនុស្សចាស់កំពុងស្ថិតនៅក្នុងកំឡុងពេលមានគ្រោះអាសន្ន និងឱ្យអាចវាយតម្លៃអំពីភាពងាយរងគ្រោះរបស់មនុស្សចាស់ ទាក់ទងនឹងស្ថានភាពផ្នែករាងកាយនិងផ្លូវចិត្តរបស់ពួកគាត់។

(iv) បញ្ជាបការយល់ដឹងដល់អ្នកបម្រើការងារជួយសង្គ្រោះឬស្តារសម្បទាអំពីបញ្ហានានាដែលជួបប្រទះដោយមនុស្សចាស់។

(v) ផ្តល់ការការពារបន្ថែមដល់ស្ត្រីវ័យចាស់ពីការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្នែករាងកាយ ផ្លូវចិត្ត ផ្លូវភេទ និងហិរញ្ញវត្ថុ នៅក្នុងស្ថានភាពមានអាសន្ន។

(vi) រៀបចំកម្មវិធីជួយសង្គ្រោះឬស្តារសម្បទាឱ្យមានលក្ខណៈអំណោយផលចំពោះមនុស្សចាស់។

(vii) ជានាថា មជ្ឈមណ្ឌលសម្រាប់ការជម្លៀសមានការរៀបចំពិសេសដែលសមស្របទៅនឹងសេចក្តីត្រូវការរបស់មនុស្សចាស់។

(viii) បង្កើនចំនួនអ្នកវិជ្ជាជីវៈផ្នែកមនុស្សចាស់ នៅក្នុងក្រុមវេជ្ជសាស្ត្រដែលបញ្ជូនចេញទៅកាន់ទីកន្លែងជួយគ្រោះមហន្តរាយ។

(ix) លើកកម្ពស់ការយល់ដឹងជាសាធារណៈដើម្បីពង្រីកការជួយជ្រោមជ្រែងទៅដល់មនុស្សចាស់ដែលជួបការលំបាកក្នុងកំឡុងពេលមានអាសន្ន។

ឥសដៅ៨.២ : បញ្ជ្រាបការយល់ដឹងដល់មនុស្សចាស់អំពីវិធីដើម្បីរៀបចំខ្លួនឆ្លើយតបទៅនឹងករណីមានអាសន្ន

យុទ្ធសាស្ត្រ៖

(i) ផ្តល់ការណែនាំនិងការបណ្តុះបណ្តាលដល់មនុស្សវ័យចាស់អំពីរបៀបដោះស្រាយនៅពេលមានគ្រោះមហន្តរាយធម្មជាតិនិងករណីអាសន្នផ្សេងៗទៀត ដូចជាការផ្លាស់ទីកន្លែងរស់នៅរបស់ប្រជាជនជាដើម។

(ii) ផលិតនិងចែកចាយសៀវភៅណែនាំសម្រាប់មនុស្សចាស់ ដោយគូសបញ្ជាក់អំពីការប្រុងប្រយ័ត្នជាមុននិងសកម្មភាពទាំងឡាយដែលត្រូវធ្វើ ក្នុងករណីមានអាសន្នតាមប្រភេទផ្សេងៗពីគ្នា។

(iii) ដាក់ឱ្យដំណើរការនូវប្រព័ន្ធមួយ ដែលមនុស្សចាស់អាចចុះបញ្ជីអាសយដ្ឋានរបស់ពួកគាត់និងព័ត៌មានលម្អិតដែលពាក់ព័ន្ធដទៃទៀត ដើម្បីជួយឱ្យក្រុមអ្នកសង្គ្រោះអាចកំណត់ទីតាំងរបស់ពួកគាត់បានទាន់ពេលនៅពេលមានអាសន្ន ជាពិសេស នៅតាមទីតាំងដែលជួបគ្រោះមហន្តរាយញឹកញាប់។

(iv) ផ្តល់ការណែនាំដល់មនុស្សចាស់អំពីរបៀបទាក់ទាញចំណាប់អារម្មណ៍របស់មនុស្សដទៃនៅពេលជួបនឹងគ្រោះថ្នាក់ខ្លាំងហួសប្រមាណក្នុងស្ថានភាពអាសន្ន។

២.៩_ អាទិភាពទី៩ : ការត្រៀមខ្លួនរបស់ប្រជាជនវ័យក្មេង

ឥសដៅ៩.១ : ផ្តល់បរិស្ថានមួយដែលប្រជាជនវ័យក្មេងអាចត្រៀមខ្លួនបានកាន់តែប្រសើរសម្រាប់ពេលឈានចូលវ័យចាស់

យុទ្ធសាស្ត្រ៖

(i) ពង្រីកវិសាលភាពគ្រប់ដណ្តប់យន្តការការពារផ្នែកហិរញ្ញវត្ថុសម្រាប់ការត្រៀមរៀបចំនៅពេលចូលដល់វ័យចាស់តាមរយៈការអនុវត្តផែនការប្រាក់សោធននិវត្តន៍ និងគម្រោងសន្សំប្រាក់ ដើម្បីធានាឱ្យមានប្រាក់ចំណូលសមរម្យ សម្រាប់ប្រជាជនដែលចូលរួមក្នុងរបបសោធនភាគទ្រកិច្ចនិងស្ម័គ្រចិត្ត និងការកាត់បន្ថយជាអតិបរមានូវការធ្លាក់ទៅក្នុងភាពក្រីក្រនៅពេលឈានដល់វ័យចាស់។

(ii) ផ្សព្វផ្សាយព័ត៌មានស្តីពីរបៀបរស់នៅដែលមានសុខភាពល្អ ដូចជាទម្លាប់ទទួលទានអាហារធ្វើឱ្យមានសុខភាពល្អនិងការហាត់ប្រាណទៀងទាត់ជាដើម ដើម្បីជួយឱ្យមនុស្សចាស់នាពេលអនាគតអាចរក្សាបាននូវបទដ្ឋានសុខភាពកាន់តែខ្ពស់ថែមទៀត។

(iii) ផ្តល់គម្រោងជានាវ៉ាប់រងសុខភាពជូនមនុស្សក្នុងវ័យធ្វើការងារ ដែលផ្តល់ការគ្រប់ដណ្តប់សម្រាប់ពេលគាត់ឈានចូលដល់វ័យចាស់ផងដែរ។

(iv) បណ្តុះឱ្យមាននៅក្នុងផ្នត់គំនិតរបស់ប្រជាជនវ័យក្មេងនូវការឱ្យតម្លៃដល់មនុស្សចាស់ ដើម្បីលុបបំបាត់នូវការភ័យខ្លាចរបស់ពួកគាត់ចំពោះការក្លាយជាមនុស្សចាស់ និងអារម្មណ៍អវិជ្ជមានទាំងឡាយដែលពួកគាត់អាចមានចំពោះជីវិតវ័យចាស់។

(v) ផ្តល់ឱកាសឱ្យមនុស្សវ័យក្មេងធ្វើការងារស្ម័គ្រចិត្តសម្រាប់មនុស្សចាស់នៅតាមផ្ទះនិងអង្គការសម្រាប់មនុស្សចាស់ ដើម្បីឱ្យពួកគាត់មានព័ត៌មានផ្ទាល់អំពីរបៀបដោះស្រាយបញ្ហាទាំងឡាយដែលនឹងអាចកើតមានឡើងក្នុងវ័យចាស់។

(vi) បង្កើនការយល់ដឹងជាសាធារណៈអំពីសារៈសំខាន់នៃដំណើរឈានចូលវ័យចាស់ប្រកបដោយភាពថ្លៃថ្នូរ តាមរយៈការអប់រំក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធដែលត្រូវធ្វើឡើងជាប្រចាំ។

ឥសដៅ៩.២ : ជំរុញលើកទឹកចិត្តដល់មនុស្សវ័យក្មេងឱ្យត្រៀមខ្លួន សម្រាប់ការឈានចូលវ័យចាស់ប្រកបដោយសុខភាពល្អនិងសកម្ម

យុទ្ធសាស្ត្រ៖

(i) ដាក់បញ្ចូលមុខវិជ្ជាស្តីពីរបៀបរៀបចំការរស់នៅប្រកបដោយសុខភាពល្អនិងអាកប្បកិរិយា និងឥរិយាបថចេះស្វែងរកសុខភាពល្អ នៅក្នុងកម្មវិធីសិក្សារបស់សាលា។

(ii) បង្ហាញពីការគោរពនិងការថែទាំឪពុកម្តាយនិងសាច់ញាតិចាស់ជរា ដើម្បីបង្ហាញជាគំរូល្អដល់កូនៗរបស់ខ្លួនពីសារៈសំខាន់នៃករណីយកិច្ចទាំងអស់នេះ។

(iii) លើកទឹកចិត្តឱ្យមានការពិនិត្យសុខភាពជាប្រចាំ។

(iv) បញ្ជាបការយល់ដឹងអំពីផលប៉ះពាល់នៃការផ្លាស់ប្តូរដែលមិនអាចចៀសបាន ដែលកើតចេញមកពីការចូលនិវត្តន៍និងដំណើរឈានចូលវ័យចាស់។

៣. ផែនការសកម្មភាព

ផែនការសកម្មភាពឆ្នាំ២០២១-២០២៥នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ គឺផ្អែកលើចក្ខុវិស័យរបស់គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ដែលលើកឡើងថា ដើម្បីធានាថា មនុស្សវ័យចាស់អាចចូលរួមដោយមានសេរីភាពនិងកិត្តិយសពេញលេញ នៅក្នុងសកម្មភាពគ្រួសារ សហគមន៍ សេដ្ឋកិច្ច សង្គម សាសនា និងនយោបាយ ហើយធានាថា មនុស្សវ័យក្មេងទទួលបាននូវចំណេះដឹង ដែលអាចជួយឱ្យពួកគាត់អាចដឹកនាំជីវិតផ្ទាល់ខ្លួនប្រកបដោយផលិតភាព សុខភាពល្អ សកម្ម និងកិត្តិយសនៅក្នុងវ័យចាស់។

៣.១. បរិយាយសង្ខេបអំពីវិសាលភាពផែនការ

ផែនការសកម្មភាពឆ្នាំ២០២១-២០២៥នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ គ្របដណ្តប់លើ៖

- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ដៃគូអភិវឌ្ឍ
- អង្គការសង្គមស៊ីវិល

- ជនរងគ្រោះនិងងាយរងគ្រោះ
- សាធារណជនទូទៅ។

៣.២_ ដំណើរការអនុវត្តផែនការសកម្មភាព និងក្រសួង ស្ថាប័នទទួលខុសត្រូវ

ផែនការសកម្មភាពឆ្នាំ២០២១-២០២៥នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ នឹងត្រូវបានដាក់ឱ្យអនុវត្តក្នុងអំឡុងពេល៥ឆ្នាំ ដែលកំណត់អំពីសកម្មភាពនានាដែលចាំបាច់ធ្វើកិច្ចអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ ដើម្បីធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌរស់នៅនិងគុណភាពជីវិតរបស់ប្រជាជនវ័យចាស់កម្ពុជា។ ផែនការសកម្មភាពនេះបានស្នើឡើងសម្រាប់អនុវត្តក្នុងរយៈពេលមធ្យមដោយក្រសួង ស្ថាប័នចំនួន២៨ ហើយដែលស្ថិតក្រោមការដឹកនាំសម្របសម្រួលរបស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់។ នៅក្នុងផែនការសកម្មភាពទាំងឡាយដែលបានស្នើឡើង គឺផ្អែកលើការតម្រង់ទិសគោលនយោបាយ និងកម្មវិធីដែលជាក់សំខាន់លើលទ្ធផលចុងក្រោយ ធាតុចេញ ចំណុចដៅ សកម្មភាព និងសូចនាករសម្រាប់វាស់វែងវឌ្ឍនភាព និងលទ្ធផលដែលសម្រេចបាន។

ក្រសួង ស្ថាប័នអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ ដែលមានការទទួលខុសត្រូវក្នុងការស្នើឡើងនូវសកម្មភាពរបស់ខ្លួននៅក្នុងផែនការសកម្មភាពឆ្នាំ២០២១-២០២៥ រួមមានចំនួន២៨ ក្រសួង ស្ថាប័ន ដូចមានបង្ហាញនៅក្នុងតារាងខាងក្រោម៖

ក្រសួង ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយតាមអាទិភាពនីមួយៗ

ល.រ.	អាទិភាព	ក្រសួង ស្ថាប័នអនុវត្តគោលនយោបាយ
១	ការធានាឱ្យបាននូវសន្តិសុខហិរញ្ញវត្ថុ	- ទីស្តីការគណៈរដ្ឋមន្ត្រី - ក្រសួងបរិស្ថាន - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ - ក្រសួងពាណិជ្ជកម្ម - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ - ក្រសួងមុខងារសាធារណៈ - ក្រសួងទេសចរណ៍ - ក្រសួងសាធារណការនិងដឹកជញ្ជូន - ធនាគារជាតិនៃកម្ពុជា - ក្រសួងផែនការ - ក្រសួងមហាផ្ទៃ - ក្រសួងសុខាភិបាល - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ក្រសួងអប់រំ យុវជន និងកីឡា - ក្រសួងព័ត៌មាន - ក្រសួងរ៉ែនិងថាមពល

		- គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
២	សុខភាពនិងសុខុមាលភាព	- ទីស្តីការគណៈរដ្ឋមន្ត្រី - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា - ក្រសួងសុខាភិបាល - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ - ក្រសួងមហាផ្ទៃ - ក្រសួងអប់រំ យុវជន និងកីឡា - ក្រសួងបរិស្ថាន - ក្រសួងផែនការ - ក្រសួងព័ត៌មាន
៣	របៀបរបបនៃការរស់នៅ	- ក្រសួងសុខាភិបាល - ក្រសួងទេសចរណ៍ - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ - ក្រសួងអប់រំ យុវជន និងកីឡា - ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ - ក្រសួងធម្មការនិងសាសនា - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ - កាកបាទក្រហមកម្ពុជា - គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
៤	បរិស្ថានអំណោយផល	- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ - ក្រសួងសាធារណការនិងដឹកជញ្ជូន - ក្រសួងអភិវឌ្ឍន៍ជនបទ - ក្រសួងព័ត៌មាន - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ - កាកបាទក្រហមកម្ពុជា
៥	សមាគមមនុស្សចាស់និងវ័យចាស់សកម្ម	- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា - ក្រសួងមហាផ្ទៃ - ក្រសួងសុខាភិបាល - កាកបាទក្រហមកម្ពុជា

៦	ទំនាក់ទំនងអន្តរជំនាន់	- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា - ក្រសួងមុខងារសាធារណៈ - ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ - ក្រសួងធម្មការនិងសាសនា - ក្រសួងព័ត៌មាន - ក្រសួងអប់រំ យុវជន និងកីឡា - ក្រសួងបរិស្ថាន - ក្រសួងទេសចរណ៍ - ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ - ក្រសួងពាណិជ្ជកម្ម
៧	ការរំលោភបំពាននិងអំពើហិង្សាលើមនុស្សចាស់	- ក្រសួងមហាផ្ទៃ - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា - ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច - ក្រសួងកិច្ចការនារី
៨	ស្ថានភាពមានអាសន្ន	- ក្រសួងមហាផ្ទៃ - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា - ក្រសួងកិច្ចការនារី - គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
៩	ការត្រៀមខ្លួនរបស់ប្រជាជនវ័យក្មេង	- ក្រសួងពាណិជ្ជកម្ម - ក្រសួងសុខាភិបាល - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា - ក្រសួងអប់រំ យុវជន និងកីឡា - ក្រសួងទេសចរណ៍ - ក្រសួងផែនការ - ធនាគារជាតិនៃកម្ពុជា

៣.៣_ តារាងអនុវត្តការងារ

អភិក្រមសម្រាប់ផែនការសកម្មភាពឆ្នាំ២០២១-២០២៥នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ឆ្នាំ២០១៧-២០៣០ គឺរួមចំណែកដោះស្រាយបញ្ហាមនុស្សវ័យចាស់ ដូចជាការកាត់បន្ថយភាពក្រីក្រ លើកកម្ពស់គុណភាពជីវិតរបស់មនុស្សវ័យចាស់ ការលើកកម្ពស់សុខភាពនិងសុខុមាលភាពរបស់មនុស្សវ័យចាស់ជាដើម។

ដំណើរការនៃការរៀបចំផែនការសកម្មភាពនេះ គឺជាផ្នែកមួយនៃដំណើរការធ្វើផែនការពាក់ព័ន្ធនឹងបញ្ហាមនុស្សវ័យចាស់ ដែលជាការពង្រីកពីការរៀបចំគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ ទៅដល់ការអនុវត្តគោលនយោបាយនេះ។ ដំណើរការនេះបានបញ្ជាក់ពីការទទួលស្គាល់នូវតួនាទីសំខាន់នៃផែនការសកម្មភាព ក្នុងការតម្រង់ទិសដល់ការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-

២០៣០ ហើយបានកំណត់នូវកិច្ចអន្តរាគមន៍គន្លឹះៗ និងសកម្មភាពសំខាន់ៗសម្រាប់ការអនុវត្តគោលនយោបាយនេះ ដោយធ្វើឱ្យមានការពាក់ព័ន្ធពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល។

ការរៀបចំផែនការសកម្មភាពនេះ ត្រូវបានធ្វើឡើងនៅក្នុងដំណើរការដែលមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយ តាមរយៈនៃការផ្តល់ធាតុចូលនិងការធ្វើសិក្ខាសាលាពិភាក្សាពិគ្រោះយោបល់ដើម្បីធានាឱ្យមានការចូលរួមយ៉ាងទូលំទូលាយ និងភាពជាម្ចាស់ការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ រួមជាមួយនឹងការចូលរួមចំណែករបស់អ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ក្នុងការអនុវត្តសកម្មភាពទាំងឡាយដែលបានកំណត់នៅក្នុងផែនការសកម្មភាពនេះ។

នៅក្នុងដំណើរការនៃការអនុវត្តផែនការសកម្មភាពនេះ ដើម្បីធានានូវសង្គតិភាពនៅក្នុងក្របខ័ណ្ឌរួមនៃគោលនយោបាយជាតិ ក្នុងនោះ រួមមានយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយជាតិប្រជាជន គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ក៏ដូចជាដើម្បីធានានូវលទ្ធភាពក្នុងការអនុវត្តកម្មវិធី អនុកម្មវិធី គម្រោង និងសកម្មភាពទាំងនោះ ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ឬថវិកាកម្មវិធីរបស់ក្រសួង ស្ថាប័ន។ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវធានាថា កម្មវិធី អនុកម្មវិធី គម្រោង និងសកម្មភាពទាំងឡាយដែលបានស្នើត្រូវអនុវត្តទៅតាមទិសដៅមួយ ដែលនាំឱ្យសម្រេចបាននូវគោលដៅរួមនៃគោលនយោបាយនេះ។ ទន្ទឹមនឹងនេះ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ មានតួនាទីសម្របសម្រួលការតាមដានត្រួតពិនិត្យក្នុងការអនុវត្តផែនការសកម្មភាពនេះ ដោយត្រូវរៀបរៀងលទ្ធផលធៀបនឹងសូចនាករទាំងឡាយដែលបានកំណត់ ហើយក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវចូលរួមជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយផ្តល់ធាតុចូលសម្រាប់របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ក៏ដូចជាសម្រាប់វដ្តនៃផែនការសកម្មភាពបន្ត។

ដូចបានអធិប្បាយខាងលើ ផែនការសកម្មភាពនេះ ដាក់បញ្ចូលនូវតារាងម៉ាទ្រិក ដែលជាផ្នែកមួយដ៏សំខាន់ដោយរំលេចនូវកម្មវិធី អនុកម្មវិធី គម្រោង និងសកម្មភាព រួមទាំងសូចនាករ ចំណុចដៅ ប្រភពហិរញ្ញប្បទាន និងចំណាយប៉ាន់ស្មាន ពេលវេលា ស្ថាប័នទទួលខុសត្រូវ។ តារាងម៉ាទ្រិកនេះ គឺជាឧបករណ៍ស្នូលនៃផែនការសកម្មភាពសម្រាប់វាស់វែងអំពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ។ កម្មវិធី អនុកម្មវិធី គម្រោង និងសកម្មភាពកំពុងដំណើរការ ឬជាកម្មវិធី អនុកម្មវិធី គម្រោង និងសកម្មភាពថ្មីៗទាំងឡាយដែលពាក់ព័ន្ធនឹងទិសដៅនិងយុទ្ធសាស្ត្រនីមួយៗ។ ក្នុងន័យនេះ ក្របខ័ណ្ឌពេលវេលានៃផែនការសកម្មភាពនេះ ហើយការឆ្លើយតបទៅនឹងទិសដៅ និងយុទ្ធសាស្ត្រគោលនយោបាយ និងកម្មវិធីទាំងអស់ នឹងត្រូវធ្វើឡើងជាបន្តបន្ទាប់នៅក្នុងក្របខ័ណ្ឌពេលវេលានៃផែនការសកម្មភាពតាមដំណាក់កាលនីមួយៗ។

កម្មវិធី អនុកម្មវិធី គម្រោង និងសកម្មភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបានលើកឡើងនៅក្នុងតារាងម៉ាទ្រិកនៃផែនការសកម្មភាពឆ្នាំ២០២១-២០២៥។ កម្មវិធី អនុកម្មវិធី និងគម្រោងសរុបចំនួន៣២ដែលផ្តល់ដោយក្រសួង ស្ថាប័នចំនួន២៨ ត្រូវដាក់បញ្ចូលនៅក្នុងតារាងម៉ាទ្រិកនៃផែនការសកម្មភាពលើកទីពីរនេះ(សូមពិនិត្យមើលតារាងម៉ាទ្រិកនៃផែនការសកម្មភាពឆ្នាំ២០២១-២០២៥)។ សូចនាករដាក់លាក់មិនត្រូវរំលេចក្នុងផែនការសកម្មភាពឆ្នាំ២០២១-២០២៥នេះទេ ដោយសូចនាករដាក់លាក់នេះនឹងដាក់នៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗក្នុងការអនុវត្តផែនការជាតិនេះ។

តារាងម៉ាទ្រិកនៃផែនការសកម្មភាពឆ្នាំ២០២១-២០២៥

អាទិភាពទី១ : សន្តិសុខហិរញ្ញវត្ថុ

ទិសដៅ១.១ : បង្កលក្ខណៈឱ្យមនុស្សចាស់អាចមានឱកាសបន្តធ្វើការងារដែលផ្តល់ផលប្រយោជន៍ ក្នុងករណីដែលពួកគាត់ចង់និងមានលទ្ធភាពអាចធ្វើបាន

យុទ្ធសាស្ត្រ១.១.១ : បង្កើនការយល់ដឹងអំពីការរើសអើងនៅក្នុងការងារ ដោយផ្តែកលើអាយុក្នុងចំណោមអ្នកមានចំណែកពាក់ព័ន្ធសំខាន់ៗ រួមមានក្រុមមនុស្សចាស់ សហជីពកម្មករ និងសមាគមនិយោជក

សកម្មភាព	ចំណុចដៅ/សូចនាករ	ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)					ប្រភពធនធាន	ស្ថាប័នទទួលខុសត្រូវ
		២០២១	២០២២	២០២៣	២០២៤	២០២៥		
១- លើកកម្ពស់ការយល់ដឹងអំពីគុណតម្លៃរបស់មនុស្សវ័យចាស់ និងការរើសអើងការងារពាក់ព័ន្ធនឹងអាយុនៅតាមបណ្តាញផ្សព្វផ្សាយនានា រួមមានវិទ្យុ ទូរទស្សន៍ និងបណ្តាញទំនាក់ទំនងសង្គម	- ធ្វើការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងតាមបណ្តាញទំនាក់ទំនងសង្គមនានា	១០	១០	១០	១០	១០	ថវិកាជាតិ	ទីស្តីការគណៈរដ្ឋមន្ត្រី
២- រៀបចំសិក្ខាសាលាបង្កើនការយល់ដឹងអំពីការរើសអើងមនុស្សវ័យចាស់នៅក្នុងការងារ	- ចំនួនសិក្ខាសាលា២លើក - ចំនួនអ្នកចូលរួម៦០នាក់	០	១០	០	១០	០	ថវិកាជាតិ	ក្រសួងបរិស្ថាន
៣- សិក្សាស្រាវជ្រាវអំពីការរើសអើងមនុស្សវ័យចាស់(សមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស និងវិស័យឯកជន)	- ចំនួនរបាយការណ៍ស្តីពីការរើសអើងមនុស្សវ័យចាស់នៅតាមសមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស និងវិស័យឯកជន	០	០	៤០	៤០	៤០	ថវិកាជាតិ	ក្រសួងស.អ.យ.
៤- រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការរើសអើងមនុស្សវ័យចាស់	- ចំនួន៣លើក - ចំនួន២៨ក្រសួង ស្ថាប័ន - ចំនួន២៥រាជធានី ខេត្ត - ចំនួន៣០វិស័យឯកជន និងសមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស	០	០	៣០	៣០	៣០	ថវិកាជាតិ	ក្រសួងស.អ.យ.

	- ចំនួន១០គ្រឹះស្ថានបណ្តុះបណ្តាល - អ្នកចូលរួម៣២៤នាក់							
៥- លើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង: - បន្តសិក្សាស្រាវជ្រាវលទ្ធភាពធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសិទ្ធិនិងលក្ខខណ្ឌការងារស្របតាមតម្រូវការសង្គមសេដ្ឋកិច្ច	- អត្រាសហគ្រាស គ្រឹះស្ថាននាំចេញដែលរំលោភលើលក្ខខណ្ឌស្នូល៣១ចំណុចមានការថយចុះ - អត្រាសហគ្រាស គ្រឹះស្ថាននាំចេញដែលរំលោភលើលក្ខខណ្ឌ៤១ចំណុចមានការថយចុះ	១៧ ៦៧៩,៧	៨ ៨៣៩,៤	១០ ៥៧១,៧	០	០	ថវិកាជាតិ	ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(អគ្គនាយកដ្ឋានការងារ)
៦- រៀបចំសិក្ខាសាលាបញ្ជ្រាបការយល់ដឹងអំពីការចូលរួមនិងការរើសអើងមនុស្សវ័យចាស់ក្នុងក្របខ័ណ្ឌពាណិជ្ជកម្ម(តាមខេត្តគោលដៅសំខាន់ៗ)	- ចំនួនសិក្ខាសាលា៥លើក - ចំនួនអ្នកចូលរួម៨០នាក់	០	០	៥០	៥០	៥០	ថវិកាជាតិ ថវិកាដៃគូ	ក្រសួងពាណិជ្ជកម្ម

យុទ្ធសាស្ត្រ១.១.២ : ជំរុញការបង្កើតក្របខ័ណ្ឌគាំទ្រផ្នែកច្បាប់សម្រាប់ករណីនៃការរើសអើងផ្នែកអាយុ								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
៧- ពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធទៅនឹងការរើសអើងមនុស្សវ័យចាស់ដោយផ្អែកលើអាយុទាំងនៅក្នុងផ្នែកឯកជន សង្គមស៊ីវិល និងរដ្ឋ	- ចុះធ្វើអធិការកិច្ចតាមអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន៨ដង	១០	១០	១០	១០	១០	ថវិកាជាតិ	ទីស្តីការគណៈរដ្ឋមន្ត្រី
៨- សិក្សាស្រាវជ្រាវអំពីតម្រូវការផ្នែកច្បាប់សម្រាប់ការការពារនិងលើកកម្ពស់សុខុមាលភាពមនុស្សវ័យចាស់	- ចំនួនរបាយការណ៍ស្តីពីតម្រូវការផ្នែកច្បាប់សម្រាប់ការការពារនិងលើកកម្ពស់សុខុមាលភាពមនុស្សវ័យចាស់	០	០	៤០	៤០	៤០	ថវិកាជាតិ	ក្រសួងស.អ.យ.

៩- បង្កើតច្បាប់ស្តីពីការលើកកម្ពស់និងការពារសិទ្ធិមនុស្សវ័យចាស់	- ច្បាប់ស្តីពីការលើកកម្ពស់និងការពារសិទ្ធិមនុស្សវ័យចាស់ត្រូវបានបង្កើតនិងអនុម័ត	០	០	៤០	៤០	៤០	ថវិកាជាតិ	ក្រសួងស.អ.យ.
១០- បង្កើតលិខិតបទដ្ឋានគតិយុត្តក្នុងការលើកកម្ពស់និងការពារសិទ្ធិមនុស្សវ័យចាស់	- ចំនួនលិខិតបទដ្ឋានគតិយុត្តសម្រាប់ការលើកកម្ពស់និងការពារសិទ្ធិមនុស្សវ័យចាស់ត្រូវបានបង្កើតនិងអនុម័ត	០	០	២០	២០	២០	ថវិកាជាតិ	ក្រសួងស.អ.យ.
១១- ពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធទៅនឹងការរើសអើងមនុស្សវ័យចាស់នៅក្នុងវិស័យឯកជន សមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស និងវិស័យសាធារណៈ	- ចំនួនការធ្វើអធិការកិច្ចវិស័យឯកជន សមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស និងវិស័យសាធារណៈ	០	០	២០	២០	២០	ថវិកាជាតិ	ក្រសួងស.អ.យ.
១២- សិក្សាស្រាវជ្រាវអំពីលទ្ធភាពរបស់វិស័យឯកជន សមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេសក្នុងការផ្តល់ឱកាសការងារមនុស្សវ័យចាស់	- របាយការណ៍ស្តីពីការស្រាវជ្រាវអំពីលទ្ធភាពរបស់វិស័យឯកជន សមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេសក្នុងការផ្តល់ឱកាសការងារមនុស្សវ័យចាស់	០	០	៤០	៤០	៤០	ថវិកាជាតិ	ក្រសួងស.អ.យ.
១៣- បន្តសិក្សាស្រាវជ្រាវលទ្ធភាពធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសិទ្ធិនិងលក្ខខណ្ឌការងារ ស្របតាមតម្រូវការសង្គមសេដ្ឋកិច្ច	- ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសិទ្ធិនិងលក្ខខណ្ឌការងារត្រូវបានសិក្សាស្រាវជ្រាវនិងធ្វើវិសោធនកម្ម	១៧ ៦២៩,៧	៨ ៨៣៩,៤	១០ ៥៧១,៧	0	0	ថវិកាជាតិ	ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(អគ្គនាយកដ្ឋានការងារ)

យុទ្ធសាស្ត្រ១.១.៣ : បញ្ជ្រាបការយល់ដឹងដល់និយោជក អំពីបទពិសោធនិងសក្តានុពលវិជ្ជមានរបស់កម្មករ និយោជិតវ័យចាស់								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
១៤- រៀបចំសិក្ខាសាលា ដើម្បីធ្វើឱ្យនិយោជកដឹងអំពីសក្តានុពលរបស់បុគ្គលិក កម្មករ និងនិយោជិតដែលមានវ័យចាស់	- សិក្ខាសាលាចំនួន២ ដើម្បីលើកកម្ពស់សក្តានុពលវិជ្ជមានរបស់មនុស្សវ័យចាស់	២៦	២៦	២៦	២៦	២៦	ថវិកាជាតិ	ទីស្តីការគណៈរដ្ឋមន្ត្រី
១៥- រៀបចំសិក្ខាសាលាស្តីពីការផ្តល់ឱកាសការងារសម្រាប់មនុស្សវ័យចាស់	- ចំនួន២៨លើក - ចំនួនក្រសួង ស្ថាប័ន - ចំនួន២៥រាជធានី ខេត្ត - ចំនួនវិស័យឯកជន និងសមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស - ចំនួនគ្រឹះស្ថានបណ្តុះបណ្តាល - ចំនួនអ្នកចូលរួម៤៥០០នាក់	០	០	១៥០	១៥០	១៥០	ថវិកាជាតិ	ក្រសួងស.អ.យ.
១៦- បន្តពង្រឹងគុណភាពនិងប្រសិទ្ធភាពអធិការកិច្ចការងារ ដោយផ្អែកលើហានិភ័យនិងវិធីសាស្ត្រអធិការកិច្ចប្រកបដោយវិជ្ជាជីវៈ ដោយកំណត់ជាគោលការណ៍សហគ្រាស គ្រឹះស្ថាន និងរងអធិការកិច្ចចំនួន១ដង/ឆ្នាំ	- លក្ខខណ្ឌវិនិច្ឆ័យកម្រិតហានិភ័យផ្អែកលក្ខខណ្ឌការងាររបស់សហគ្រាស គ្រឹះស្ថានត្រូវបានរៀបចំ	១៧ ៦២៩,៧	៨ ៨៣៩,៤	១០ ៥៧១,៧	០	០	ថវិកាជាតិ	ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(អគ្គនាយកដ្ឋានការងារ)

យុទ្ធសាស្ត្រ១.១.៤ : ជាក់ឱ្យមានបទប្បញ្ញត្តិច្បាប់ដែលតម្រូវឱ្យនិយោជកផ្តល់នូវលក្ខខណ្ឌការងារ ដូចជាគ្រឿងបរិក្ខារដែលងាយប្រើប្រាស់ អាហារដែលផ្តល់សុខភាពល្អ សេវាសុខភាពមូលដ្ឋាន និងបរិស្ថានកន្លែងធ្វើការងារទូទៅដែលសមស្របសម្រាប់កម្មករ និយោជិតវ័យចាស់								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
១៧- រៀបចំកិច្ចប្រជុំស្តីពីការកំណត់លក្ខខណ្ឌការងារសម្រាប់មនុស្សវ័យ	- ចំនួន៦លើក - អ្នកចូលរួម៣០០នាក់	០	០	១០	១០	១០	ថវិកាជាតិ	ក្រសួងស.អ.យ. សហការជាមួយ

ចាស់								ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
១៨_ បង្កើតលិខិតបទដ្ឋានគតិយុត្តក្នុងការកំណត់លក្ខខណ្ឌការងារសម្រាប់មនុស្សវ័យចាស់	- ចំនួនលិខិតបទដ្ឋានគតិយុត្តក្នុងការកំណត់លក្ខខណ្ឌការងារសម្រាប់មនុស្សវ័យចាស់ត្រូវបានបង្កើតនិងអនុម័ត	០	០	២០	២០	២០	ថវិកាជាតិ	ក្រសួងស.អ.យ. សហការជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
១៩_ សហការចុះពង្រឹងប្រព័ន្ធសុខភាពនិងសុវត្ថិភាពការងារនៅកន្លែងធ្វើការ	- ចំនួន៦លើក	០	០	១០	១០	១០	ថវិកាជាតិ	ក្រសួងស.អ.យ. សហការជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
២០_ ពង្រឹងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ: - បន្តរៀបចំច្បាប់លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងសុវត្ថិភាពនិងសុខភាពការងារ ដោយសហការជាមួយដៃគូអភិវឌ្ឍតាមតម្រូវការសង្គម សេដ្ឋកិច្ច	- ច្បាប់ស្តីពីសុវត្ថិភាពនិងសុខភាពការងារត្រូវបានអនុម័តត្រឹមឆ្នាំ២០២៣ - ប្រកាសនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសុវត្ថិភាពនិងសុខភាពការងារត្រូវបានរៀបចំនិងធ្វើវិសោធនកម្ម - គោលនយោបាយជាតិស្តីពីសុវត្ថិភាពនិងសុខភាពការងារត្រូវបានអនុម័តត្រឹមឆ្នាំ២០២១	៨៤៤,៦	៨២៨,២	១ ៦៤៨,២	០	០	ថវិកាជាតិ	ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(អគ្គនាយកដ្ឋានការងារ)

យុទ្ធសាស្ត្រ១.១.៥ : សិក្សាអំពីលទ្ធភាពនៃការរៀបចំប្រព័ន្ធលើកទឹកចិត្តសម្រាប់សហគ្រាសដែលជួលបុគ្គលិក កម្មករ និយោជិតវ័យចាស់ ហើយនិងលើកទឹកចិត្តឱ្យសហគ្រាសទាំងនោះផ្តល់ការសម្រួលនិងលក្ខខណ្ឌការងារសមស្រប								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
២១- រៀបចំកិច្ចប្រជុំស្តីពីពិនិត្យលទ្ធភាពនៃការរៀបចំប្រព័ន្ធលើកទឹកចិត្តសម្រាប់ក្រសួង ស្ថាប័ន វិស័យឯកជន សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេសក្នុងការផ្តល់ឱកាសការងារសម្រាប់មនុស្សវ័យចាស់	- ចំនួន៣លើក - អ្នកចូលរួម៣០០នាក់	០	០	២០	២០	២០	ថវិកាជាតិ	ក្រសួងស.អ.យ.
២២- បង្កើតលិខិតបទដ្ឋានគតិយុត្តសម្រាប់លើកទឹកចិត្តដល់ក្រសួង ស្ថាប័ន វិស័យឯកជន សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស ក្នុងការផ្តល់ឱកាសការងារសម្រាប់មនុស្សវ័យចាស់	- ចំនួនលិខិតបទដ្ឋានគតិយុត្តសម្រាប់លើកទឹកចិត្តដល់ក្រសួង ស្ថាប័ន វិស័យឯកជន សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស ក្នុងការផ្តល់ឱកាសការងារសម្រាប់មនុស្សវ័យចាស់	០	០	២០	២០	២០	ថវិកាជាតិ	ក្រសួងស.អ.យ.

យុទ្ធសាស្ត្រ១.១.៦ : លើកកម្ពស់លទ្ធភាពអាចធ្វើការងារបានរបស់មនុស្សចាស់ តាមរយៈសមត្ថភាពជំនាញដែលមានស្រាប់ ឬការបណ្តុះបណ្តាលឡើងវិញ និងការអប់រំជាប្រចាំ								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
២៣- បន្តលើកទឹកចិត្តបុគ្គលិកដែលចូលនិវត្តន៍នៅមានសមត្ថភាពបំពេញការងារឱ្យនៅបម្រើការងារនៅកន្លែងដើម	- ចំនួនបុគ្គលិកដែលត្រូវចូលនិវត្តន៍នៅបន្តបម្រើការងារ	០	០	១០	១០	១០	ថវិកាជាតិ	ក្រសួងមុខងារសាធារណៈ
២៤- ចងក្រងអ្នកជំនាញវ័យចាស់ឬចូលនិវត្តន៍ដើម្បីក្លាយជាទីប្រឹក្សាឬគ្រូបង្គោលក្នុងវិស័យទេសចរណ៍	- ២៥រាជធានី ខេត្ត	១៩៧	១៥៨	១៧៥	១៥៨	១៧៥	ថវិកាជាតិ ឯកជន ដៃគូអភិវឌ្ឍ	ក្រសួងទេសចរណ៍

២៥_ បណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ដល់ប្រជាសហគមន៍ (ភាគច្រើនមានវ័យចាស់) ដើម្បីគាំទ្រសេវាកម្មនៅមូលដ្ឋាន	- ចំនួនសិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាល២៥០០នាក់	២១០	១២៥	១៨២	១៣០	១៨៥	ថវិកាជាតិ ឯកជន ដៃគូអភិវឌ្ឍ	ក្រសួងទេសចរណ៍
២៦_ ធ្វើការវាយតម្លៃ និងទទួលស្គាល់សមត្ថភាពអ្នកជំនាញវ័យចាស់ដែលគ្មានវិញ្ញាបនបត្រ ឬ សញ្ញាបត្រវិជ្ជាជីវៈ	- ឯកសារវាយតម្លៃ និងទទួលស្គាល់សមត្ថភាពជំនាញ និងចំនួនវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព	២៣៥	១៦៩	១៩៣	១៤៧	១៩២	ថវិកាជាតិ ឯកជន ដៃគូអភិវឌ្ឍ	ក្រសួងទេសចរណ៍
២៧_ បណ្តុះបណ្តាលជំនាញថ្មីៗដល់អ្នកជំនាញវ័យចាស់ ដើម្បីចាប់យកការងារថ្មីៗក្នុងវិស័យតាមលទ្ធភាព	- ២៥ រាជធានី ខេត្ត	២០៩	១៧៩	២៥២	១៧៥	១៨៣	ថវិកាជាតិ ឯកជន ដៃគូអភិវឌ្ឍ	ក្រសួងទេសចរណ៍
២៨_ រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបំពេញបន្ថែមនូវតម្រូវការសមត្ថភាពជំនាញដល់មន្ត្រីវ័យចាស់ដែលកំពុងបម្រើការងារ	- សិក្ខាសាលាចំនួន៤លើក - អ្នកចូលរួមចំនួន១០០នាក់	០	១៥	១៥	១៥	១៥	ថវិកាជាតិ	ក្រសួងបរិស្ថាន
២៩_ សិក្សាស្រាវជ្រាវអំពីលទ្ធភាពឬសមត្ថភាពក្នុងការបំពេញការងាររបស់មនុស្សវ័យចាស់	- ចំនួនរបាយការណ៍ស្តីពីការស្រាវជ្រាវអំពីលទ្ធភាពឬសមត្ថភាពក្នុងការបំពេញការងាររបស់មនុស្សវ័យចាស់នៅតាមក្រសួងស្ថាប័ន វិស័យឯកជន សមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស	០	០	៤០	៤០	៤០	ថវិកាជាតិ	ក្រសួងស.អ.យ.
៣០_ លើកទឹកចិត្តបុគ្គលិកដែលចូលនិវត្តន៍នៅមានសមត្ថភាពបំពេញការងារឱ្យនៅបម្រើការងារនៅកន្លែងដើម	- ចំនួនបុគ្គលិកដែលត្រូវចូលនិវត្តន៍នៅបន្តបម្រើការងារ	០	០	០	០	០	ថវិកាជាតិ	ក្រសួងស.អ.យ.
៣១_ ផ្តល់ឱកាសជូនដល់មន្ត្រីដែលបានចូលនិវត្តន៍ ក្លាយជាទីប្រឹក្សាជំនួយការ ដើម្បីបន្តបម្រើការងារដល់	- ផ្តល់នូវប្រភពហិរញ្ញវត្ថុសម្រាប់មន្ត្រីវ័យចាស់ ដោយទទួលបានប្រាក់ចំណូល	៤០០	៤០០	៤០០	៤០០	៤០០	ថវិកាជាតិ	គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

អង្គភាព	- បានបន្តការចែករំលែកចំណេះដឹងនិងបទពិសោធដល់មន្ត្រីជំនាន់ក្រោយក្នុងអង្គភាព							
៣២- ផ្តល់ឱកាសជូនដល់មន្ត្រីដែលចូលនិវត្តន៍អាចបន្តបម្រើការងារនៅតាមទីស្តីការក្រសួង ឬមន្ទីរាជធានីខេត្តក្រោមក្របខ័ណ្ឌជាទីប្រឹក្សាក្រសួងឬមន្ត្រីជាប់កិច្ចសន្យា	- ជានាជីវភាពសមរម្យដល់មនុស្សវ័យចាស់ ដោយអាចបន្តទទួលបានប្រាក់ចំណូល - ជានានិរន្តរភាពការងារ និងទទួលបានការចែករំលែកចំណេះដឹងនិងបទពិសោធការងារពីមន្ត្រីចូលនិវត្តន៍	៥០២	៥០២	៥០២	៥០២	៥០២	ថវិកាជាតិ	ក្រសួងរ៉ែនិងថាមពល
៣៣- រៀបចំកម្មវិធីសំណេះសំណាលនិងការជួបប្រជុំផ្សេងៗជាមួយមន្ត្រីចូលនិវត្តន៍ដោយមានការឧបត្ថម្ភថវិកានិងសម្ភារៈមួយចំនួន	- រៀបចំកម្មវិធី១លើកក្នុង១ឆ្នាំនៅក្រសួងរ៉ែនិងថាមពល - ផ្តល់វិញ្ញាបនបត្រនិងស្នាដៃការងារផ្សេងៗ - ទទួលបានការយល់ដឹងពីបទពិសោធការងារ និងសុខទុក្ខរបស់មន្ត្រីចូលនិវត្តន៍	១៥	១៥	១៥	១៥	១៥	ថវិកាជាតិ	ក្រសួងរ៉ែនិងថាមពល
៣៤- ផ្តល់ឱកាសជូនដល់មន្ត្រីដែលចូលនិវត្តន៍អាចបន្តការងារក្រោមក្របខ័ណ្ឌនៅតាមមន្ទីរ ក្រសួង ជាទីប្រឹក្សា សាស្ត្រាចារ្យ អ្នកជំនាញ ឬមន្ត្រីជាប់កិច្ចសន្យា។	- ជានាបានជីវភាពសមរម្យដល់មនុស្សវ័យចាស់ - ជានាស្ថិរភាពនិងនិរន្តរភាពការងារ - ផ្ទេរចំណេះដឹង ចំណេះធ្វើ បទពិសោធដល់មន្ត្រីជំនាន់ក្រោយ	០	៥០	៥០	១០០	១០០	ថវិកាជាតិ	ក្រសួងព័ត៌មាន
៣៥- ផ្តល់ឱកាសជូនដល់មន្ត្រីដែលចូលនិវត្តន៍អាចបន្តបម្រើការងារនៅតាមទីស្តីការក្រសួងឬមន្ទីរាជធានីខេត្ត ក្រោមក្របខ័ណ្ឌជាទីប្រឹក្សាក្រសួងឬមន្ត្រីជាប់កិច្ចសន្យា	- ជានាជីវភាពសមរម្យដល់មន្ត្រីវ័យចាស់ ដោយអាចបន្តទទួលបានប្រាក់ចំណូល - ជានានិរន្តរភាពការងារ និងទទួលបានការចែករំលែកចំណេះ	០	០	៦០០	៦០០	៦០០	ថវិកាជាតិ	ក្រសួងពាណិជ្ជកម្ម

	ដឹងនិងបទពិសោធការងារពីមន្ត្រីចូលនិវត្តន៍							
៣៦- ផ្តល់ឱកាសជូនដល់មន្ត្រីដែលបានចូលនិវត្តន៍ក្លាយជាទីប្រឹក្សាជំនួយការ ដើម្បីបន្តបម្រើការងារដល់អង្គភាពឬក្រសួង	- ផ្តល់នូវប្រភពហិរញ្ញវត្ថុសម្រាប់មន្ត្រីវ័យចាស់ដោយទទួលបានប្រាក់ចំណូល - បានបន្តការចែករំលែកចំណេះដឹងនិងបទពិសោធដល់មន្ត្រីជំនាន់ក្រោយក្នុងអង្គភាពឬក្រសួង	៤	៣	៤,៥	៦	៧	ថវិកាជាតិ	ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

យុទ្ធសាស្ត្រ១.១.៧ : ពិចារណាជាក់ចេញនូវវិធានការដើម្បីសម្រួលដល់ការធ្វើដំណើរទៅធ្វើការរបស់កម្មករ និយោជិតវ័យចាស់ ដោយគិតគូរឱ្យមានតម្លៃសមរម្យសម្រាប់ការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
៣៧- សិក្សាស្រាវជ្រាវអំពីលទ្ធភាពក្នុងការផ្តល់សេវាធ្វើដំណើរដោយឥតគិតថ្លៃដល់មនុស្សវ័យចាស់	- របាយការណ៍ស្តីពីការសិក្សាស្រាវជ្រាវអំពីលទ្ធភាពក្នុងការផ្តល់សេវាធ្វើដំណើរដោយឥតគិតថ្លៃដល់មនុស្សវ័យចាស់	០	០	៤០	៤០	៤០	ថវិកាជាតិ និងថវិកាដៃគូ	ក្រសួងស.អ.យ.
៣៨- រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីលទ្ធភាពក្នុងការផ្តល់សេវាធ្វើដំណើរដោយឥតគិតថ្លៃដល់មនុស្សវ័យចាស់	- ចំនួន៦លើក - អ្នកចូលរួម១២០០នាក់	០	០	៤០	៤០	៤០	ថវិកាជាតិ	ក្រសួងស.អ.យ.
៣៩- រៀបចំកិច្ចប្រជុំស្តីពីលទ្ធភាពក្នុងការផ្តល់សេវាធ្វើដំណើរដោយឥតគិតថ្លៃដល់មនុស្សវ័យចាស់	- ចំនួន៦លើក - អ្នកចូលរួម៦០០នាក់	០	០	២០	២០	២០	ថវិកាជាតិ	ក្រសួងស.អ.យ. សហការជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន

យុទ្ធសាស្ត្រ១.១.៨ : សិក្សាអំពីលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុសម្រាប់មនុស្សចាស់								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
៤០_ រៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយរបស់ធនាគារឯកជនស្តីពីអត្ថប្រយោជន៍នៃការសន្សំប្រាក់ទុកដល់មន្ត្រីរាជការ	- ចំនួន២លើក - អ្នកចូលរួម៦០នាក់	០	០	១០	០	១០	ថវិកាជាតិ	ក្រសួងបរិស្ថាន
៤១_ រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយធនាគារជាតិនៃកម្ពុជាដើម្បីស្វែងរកលទ្ធភាពជួយដល់មនុស្សវ័យចាស់ទទួលបានសេវាហិរញ្ញវត្ថុ(ធានារ៉ាប់រងសុខភាព ហានិភ័យការងារ...)	- ចំនួន៣លើក	០	០	១០	១០	១០	ថវិកាជាតិ	ក្រសួងស.អ.យ.
៤២_ សហការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុឯកជន ដើម្បីស្វែងរកលទ្ធភាពជួយដល់មនុស្សវ័យចាស់ទទួលបានសេវាហិរញ្ញវត្ថុ(ធានារ៉ាប់រងសុខភាព ហានិភ័យការងារ...)	- ចំនួន៣លើក	០	០	១០	១០	១០	ថវិកាជាតិ	ក្រសួងស.អ.យ.
៤៣_ សិក្សាស្រាវជ្រាវស្តីពីកិច្ចគាំពារសង្គមសម្រាប់មនុស្សវ័យចាស់	- ចំនួនរបាយការណ៍នៃការសិក្សាស្រាវជ្រាវស្តីពីកិច្ចគាំពារសង្គមសម្រាប់មនុស្សវ័យចាស់	២០,៦	០	០	០	០	ថវិកាដៃគូ	ក្រសួងស.អ.យ.(វិទ្យាស្ថានជាតិសង្គមកិច្ច)
៤៤_ ពិភាក្សាពិគ្រោះយោបល់ជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សាលទ្ធភាពនិងជំរុញការផ្តល់សេវាហិរញ្ញវត្ថុសម្រាប់មនុស្សវ័យចាស់	- ចំនួនកិច្ចពិភាក្សាពិគ្រោះយោបល់(ចំនួន១៥ដង)	១០	២០	២០	២០	២០	ថវិកាធនាគារជាតិនៃកម្ពុជានិងថវិកាដៃគូ	ធនាគារជាតិនៃកម្ពុជានិងស្ថាប័នពាក់ព័ន្ធ

ទិសដៅ១.២ : ពង្រីកដែនគ្របដណ្តប់នៃគម្រោងកិច្ចគាំពារសង្គម និងសុខុមាលភាពសង្គមដែលមានលក្ខណៈទូលំទូលាយ

យុទ្ធសាស្ត្រ១.២.១ : សិក្សាអំពីលទ្ធភាពក្នុងការដាក់ឱ្យដំណើរការកម្មវិធីគាំពារមនុស្សចាស់និងជនចាស់ជរាដែលជាសមាជិកនៃគ្រួសារដែលកាន់កាប់បណ្ណសមធម៌ ស្របតាមក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម

សកម្មភាព	ចំណុចដៅ/សូចនាករ	ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)					ប្រភពធនធាន	ស្ថាប័នទទួលខុសត្រូវ
		២០២១	២០២២	២០២៣	២០២៤	២០២៥		
៤៥_ ពង្រឹងនិងពង្រីកការអនុវត្តរបបសន្តិសុខសង្គមសម្រាប់ការថែទាំសុខភាព: - រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព	- ប្រព័ន្ធគ្រប់គ្រងទិន្នន័យសហគ្រាស គ្រឹះស្ថាន និងកម្មករ និយោជិតផ្នែកថែទាំសុខភាព ត្រូវបានធ្វើបច្ចុប្បន្នកម្មជាប្រចាំ - អត្រាភាគទានផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវបានកំណត់ឡើងវិញត្រឹមឆ្នាំ២០២០	៤២០ ២៩៥,៩	៤២០ ២៩៥,៥	៤២០ ២៩៥,៥	០	០	ថវិកាជាតិ	ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(បេឡាជាតិរបបសន្តិសុខសង្គម)
៤៦_ សិក្សានិងដាក់ឱ្យដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរាដែលមានបណ្ណសមធម៌ឬបណ្ណអាទិភាពក្រោមក្របខ័ណ្ឌកញ្ចប់គ្រួសារ	- ចំនួនរបាយការណ៍សិក្សាកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរាដែលមានបណ្ណសមធម៌ឬបណ្ណអាទិភាពក្រោមកម្មវិធីកញ្ចប់គ្រួសារត្រូវបានសិក្សា - ចំនួនកិច្ចប្រជុំពិគ្រោះយោបល់	៤០០	២០	២០	០	០	ថវិកាជាតិនិងថវិកាដៃគូ	ក្រសួងស.អ.យ. សហការជាមួយក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម)

៤៧_ រៀបចំក្របខ័ណ្ឌគតិយុត្តសម្រាប់ដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា	- ចំនួនឯកសារគតិយុត្តត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត - ចំនួនកិច្ចប្រជុំពិគ្រោះយោបល់	០	២០	២០	០	០	ថវិកាជាតិ	ក្រសួងស.អ.យ. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិគាំពារសង្គម)
៤៨_ ពិនិត្យនិងតាមដានការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា	- រាជធានី ខេត្តចំនួន៥ ត្រូវចុះពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនមនុស្សវ័យចាស់ត្រូវបានអនុវត្ត - ចំនួនបេសកកម្ម(២ក្នុងមួយឆ្នាំ) និងចំនួនសិក្ខាសាលា	០	០	១៦	២៤	២៤	ថវិកាជាតិ	ក្រសួងស.អ.យ. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិគាំពារសង្គម)
៤៩_ សិក្សានិងរៀបចំអត្តសញ្ញាណជនចាស់ជរាគ្មានទីពឹង ដើម្បីទទួលអត្ថប្រយោជន៍គាំពារសង្គម	- ចំនួនសិក្សា(របាយការណ៍) និងសិក្ខាសាលាពិគ្រោះយោបល់	០	០	៤០	៤៥	៥០	ថវិកាជាតិ	ក្រសួងផែនការ ក្រសួងស.អ.យ. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិគាំពារសង្គម)
៥០_ សិក្សាស្រាវជ្រាវស្តីពីស្ថានភាពហិរញ្ញវត្ថុនិងតម្រូវការមនុស្សវ័យចាស់ពាក់ព័ន្ធនឹងប្រាក់សោធនសង្គម	- ចំនួនរបាយការណ៍នៃការសិក្សាស្រាវជ្រាវស្តីពីស្ថានភាពហិរញ្ញវត្ថុនិងតម្រូវការមនុស្សវ័យចាស់ពាក់ព័ន្ធសោធនសង្គម	០	៣៦,៤៧	០	០	០	ថវិកាដៃគូ	ក្រសួងស.អ.យ.

យុទ្ធសាស្ត្រ១.២.២ : ពិនិត្យលទ្ធភាពក្នុងការជាក់ឱ្យអនុវត្តនូវកម្រាលគាំពារសង្គមជាជំហានៗ ដើម្បីធានាថា មនុស្សចាស់ដែលគ្មានសិទ្ធិទទួលបានប្រាក់សោធននិវត្តន៍ឬទទួលបានក្នុងបរិមាណមិនគ្រប់គ្រាន់ ហើយដែលគ្មានសមាជិកគ្រួសារមើលថែ ទទួលបាននូវប្រាក់ចំណូលសមរម្យ ដើម្បីកុំឱ្យពួកគាត់ធ្លាក់ចូលទៅក្នុងភាពក្រីក្រ								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
៥១. រៀបចំកម្មវិធីសំណេះសំណាលនិងការជួបជុំផ្សេងៗ ជាមួយមន្ត្រីចូលនិវត្តន៍ ដោយមានការឧបត្ថម្ភថវិកានិងសម្ភារៈមួយចំនួន	- ១លើកក្នុង១ឆ្នាំនៅក្រសួងពាណិជ្ជកម្ម - ទទួលបានការយល់ដឹងពីបទពិសោធការងារនិងសុខទុក្ខរបស់មន្ត្រីចូលនិវត្តន៍	០	០	២០	២០	២០	ថវិកាជាតិ	ក្រសួងពាណិជ្ជកម្ម
៥២. សិក្សាអំពីលទ្ធភាពក្នុងការរៀបចំប្រព័ន្ធសោធនពហុកម្រិតដែលមានបរិយាបន្នសម្រាប់កម្ពុជា	- ចំនួនរបាយការណ៍សិក្សានិងចំនួនកិច្ចប្រជុំពិគ្រោះយោបល់	៧០	៧០	០	០	០	ថវិកាដៃគូ	ក្រសួងស.អ.យ. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម)

យុទ្ធសាស្ត្រ១.២.៣ : បង្កើនការយល់ដឹងនិងជំរុញកូនចៅជាមនុស្សពេញវ័យដែលមានលទ្ធភាពផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ឪពុកម្តាយឬជីដូនជីតាចាស់ជរានិងសាច់ញាតិជិតស្និទ្ធរបស់ខ្លួន ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាកូនចៅ								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
៥៣. សិក្សាស្រាវជ្រាវអំពីបញ្ហាប្រឈមនិងតម្រូវការរបស់មនុស្សវ័យចាស់(ជាពិសេសមនុស្សវ័យចាស់ជាស្ត្រី)	- ចំនួនរបាយការណ៍សិក្សាស្រាវជ្រាវអំពីបញ្ហាប្រឈមនិងតម្រូវការរបស់មនុស្សវ័យចាស់(ជាពិសេសមនុស្សវ័យចាស់ជាស្ត្រី)	០	០	៤០	៤០	៤០	ថវិកាជាតិនិងថវិកាដៃគូ	ក្រសួងស.អ.យ.
៥៤. រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីបញ្ហាប្រឈមនិងតម្រូវការរបស់មនុស្សវ័យចាស់(ជាពិសេសមនុស្ស	- ចំនួន១០លើក - អ្នកចូលរួម៣០០០នាក់	០	០	១០០	១០០	១០០	ថវិកាជាតិនិងថវិកាដៃគូ	ក្រសួងស.អ.យ.

វ័យចាស់ជាស្ត្រី)								
៥៥_ បង្កើនការយល់ដឹងដល់សិស្ស និស្សិតអំពីកាតព្វកិច្ចរបស់ពួកគេ ចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ ឪពុកម្តាយ ជីដូនជីតាចាស់ជរា	- ចំនួន៣លើក - អ្នកចូលរួម៣០០នាក់	០	០	១០	១០	១០	ថវិកាជាតិ	ក្រសួងស.អ.យ. សហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា
៥៦_ ប្រមូលផ្តុំយុវជននិងសហគមន៍ រៀបចំព្រឹត្តិការណ៍បែបប្រពៃណីនិង ជាលក្ខណៈជាតិ(ដូចជាពិធីងូតទឹក ជូនមនុស្សវ័យចាស់ ទិវាបរិស្ថាន)	- ការបង្កើនការយល់ដឹងនិងការ ចូលរួមពីយុវជននិងសហគមន៍ ទៅលើបញ្ហាមនុស្សវ័យចាស់ និងការចូលរួមគាំទ្រឱ្យមនុស្ស វ័យចាស់ ដើម្បីបំពេញនូវ សក្តានុពល	៣៥	២០	៣៥	៣៥	៣៥	ថវិកាជាតិ	ក្រសួងស.អ.យ.
៥៧_ រៀបចំកិច្ចប្រជុំពិភាក្សាអំពីបញ្ហា ប្រឈមនិងតម្រូវការរបស់មនុស្សវ័យ ចាស់(ជាពិសេសមនុស្សវ័យចាស់ជា ស្ត្រី)	- ចំនួន៦លើក - អ្នកចូលរួម១២០០នាក់	០	០	៤០	៤០	៤០	ថវិកាជាតិ	ក្រសួងស.អ.យ. សហការជាមួយ ក្រសួងព័ត៌មាន
៥៨_ រៀបចំដំណើរការកម្សាន្តដិះកង់ សម្រាប់ការរៃអង្គាសប្រាក់ និងលើក កម្ពស់ការចូលរួមរបស់យុវជននិង សាធារណជន ក្នុងការគាំទ្រដល់ មនុស្សវ័យចាស់	- យ៉ាងហោចណាស់មនុស្ស ១០០នាក់បានចូលរួមក្នុង ព្រឹត្តិការណ៍នេះ ហើយបាន បង្កើតមូលនិធិដើម្បីគាំទ្រដល់ មនុស្សវ័យចាស់និងសមាគម របស់ពួកគាត់	០	០	៥០	៥០	៥០	ថវិកាជាតិ	ក្រសួងស.អ.យ. សហការជាមួយ ក្រសួងទេសចរណ៍ និងក្រសួងអប់រំ យុវ ជន និងកីឡា
៥៩_ ផ្សព្វផ្សាយឱ្យមានការយល់ដឹង ដល់យុវជនស្តីពីកាតព្វកិច្ចគាំទ្រផ្នែក ហិរញ្ញវត្ថុដល់មនុស្សវ័យចាស់	- ទទួលបានការយកចិត្តទុកដាក់ ថែទាំសុខភាពពីកូនចៅជំនាន់ ក្រោយ - ចំនួនអ្នកចូលរួម១០០នាក់ - ចំនួនការផ្សព្វផ្សាយ២លើក	០	១០	១០	១៥	១៥	ថវិកាជាតិ	ក្រសួងព័ត៌មាន
៦០_ បង្កើនការយល់ដឹងដល់សិស្ស និស្សិតអំពីកាតព្វកិច្ចរបស់ពួកគេ ចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុដល់	- ចំនួន៦លើក - អ្នកចូលរួម១២០០នាក់	០	០	៤០	៤០	៤០	ថវិកាជាតិ	ក្រសួង ស.អ.យ. សហការជាមួយ ក្រសួងអប់រំ យុវជន

ឪពុកម្តាយ ជីដូនជីតាចាស់ជរា								និងកីឡា

អាទិភាពទី២ : សុខភាពនិងសុខុមាលភាព

ទិសដៅ២.១ : ជំរុញលើកទឹកចិត្តឱ្យជំរើរឈានចូលវ័យចាស់ប្រកបដោយសុខភាពល្អ និងពង្រីកការថែទាំសុខភាពតាមលក្ខណៈការការពារជាមុន

យុទ្ធសាស្ត្រ២.១.១ : រៀបចំឱ្យមានជំរើរជីវិតមួយប្រកបដោយសុខភាពល្អពេលវ័យចាស់ និងមានការការពារ ទប់ស្កាត់ជំងឺ តាមរយៈការជាក់ឱ្យជំរើរការនូវការផ្តល់ព័ត៌មានដែលមានលក្ខណៈជាការអប់រំសម្រាប់មនុស្សចាស់ អ្នកមើលថែទាំ និងអ្នកផ្តល់សេវាសុខភាព រួមទាំងព័ត៌មានអំពីសារៈសំខាន់នៃសកម្មភាពផ្នែករាងកាយ អនាម័យល្អ និងរបបអាហារមានតុល្យភាព

សកម្មភាព	ចំណុចដៅ/សូចនាករ	ថវិការប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)					ប្រភពធនធាន	ស្ថាប័នទទួលខុសត្រូវ
		២០២១	២០២២	២០២៣	២០២៤	២០២៥		
៦១- សិក្សាស្រាវជ្រាវអំពីវិធានការបង្ការ ការពារ និងទប់ស្កាត់ជំងឺនៅពេលឈានចូលវ័យចាស់	- របាយការណ៍សិក្សាស្រាវជ្រាវអំពីវិធានការបង្ការ ការពារ និងទប់ស្កាត់ជំងឺ នៅពេលឈានចូលវ័យចាស់	០	០	៨០	០	០	ថវិកាជាតិ	ក្រសួងសុខាភិបាល សហការជាមួយក្រសួងស.អ.យ.
៦២- រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការសិក្សាស្រាវជ្រាវអំពីវិធានការបង្ការ ការពារ និងទប់ស្កាត់ជំងឺ នៅពេលឈានចូលវ័យចាស់	- ចំនួន លើក - អ្នកចូលរួម នាក់	០	០	៣០	៣០	៣០	ថវិកាជាតិ	ក្រសួងស.អ.យ.
៦៣- ជំរុញឱ្យមានការបញ្ចូលបញ្ហាទាក់ទងនឹងមនុស្សវ័យចាស់ ទៅក្នុងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ	- ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ៥% មានបញ្ចូលបញ្ហាយ៉ាងហោច១ទាក់ទងនឹងមនុស្សវ័យចាស់	០	០	៣០	៣០	៣០	ថវិកាជាតិ	ក្រសួងស.អ.យ. សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ
៦៤- អប់រំណែនាំមនុស្សពេញវ័យឱ្យយល់ដឹងអំពីការត្រៀមខ្លួនក្លាយជាមនុស្សវ័យចាស់ តាមរយៈការអប់រំឱ្យមានការយល់ដឹងពីសុខភាពផ្លូវកាយ	- ចំនួនកម្មករ និយោជិតបានចូលរួម - ចំនួនមន្ត្រីរាជការស៊ីវិលបានចូលរួម	០	០	៥០	៥០	៥០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល

អនាម័យ និងរបបអាហារ	- កងកម្លាំងប្រដាប់អាវុធបានចូលរួម - ចំនួនប្រជាពលរដ្ឋបានចូលរួម							
៦៥_ បណ្តុះបណ្តាលគ្រូបង្គោលអំពីការត្រៀមខ្លួនរបស់មនុស្សពេញវ័យមុនក្លាយជាមនុស្សវ័យចាស់ តាមរយៈការអប់រំឱ្យយល់ដឹងអំពីសុខភាពផ្លូវកាយ អនាម័យ និងរបបអាហារ	- ឯកសារបណ្តុះបណ្តាលទាក់ទងនឹងការត្រៀមខ្លួនក្លាយជាមនុស្សវ័យចាស់ត្រូវបានតាក់តែងក្នុងឆ្នាំ២០១៨ ចំនួនគ្រូបង្គោល(TOT)៖ + កម្មករ និយោជិតចំនួន១០០នាក់ + មន្ត្រីរាជការស៊ីវិលចំនួន១០០នាក់ + កងកម្លាំងប្រដាប់អាវុធចំនួន ១០០នាក់	០	០	៦៥	៦៥	៦៥	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល
៦៦_ ផ្សព្វផ្សាយអំពីបញ្ហាជំងឺនានាដែលមនុស្សវ័យចាស់ប្រឈមនិងវិធានការបង្ការនៅពេលឈានចូលវ័យចាស់	- ឯកសារ/ស្ប៉តផ្សព្វផ្សាយអំពីសុខភាពមនុស្សវ័យចាស់ ត្រូវបានបង្កើត - ឯកសារ/ស្ប៉តត្រូវបានផ្សព្វផ្សាយតាមវិទ្យុនិងទូរទស្សន៍ ចំនួន៤៦ដង - ឯកសារ/ស្ប៉តត្រូវបានផ្សព្វផ្សាយតាមបណ្តាញព័ត៌មានសង្គម ប៉ាណូផ្សព្វផ្សាយព្រឹត្តិបត្រ	០	០	៣០	៣០	៣០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល
៦៧_ ពង្រឹងការសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការលើការងារសុខភាពនិងមនុស្សវ័យចាស់	- ការប្រជុំទៀងទាត់ចំនួន២ដងក្នុង១ឆ្នាំ រវាងក្រសួងស.អ.យ. ក្រសួងសុខាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារលើការងារសុខភាពនិងមនុស្សវ័យចាស់ -	០	០	១០	១០	១០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល

៦៨_ កសាងភាពជាដៃគូជាមួយបណ្តាញសកល និងបណ្តាញក្នុងតំបន់ដែលធ្វើការលើបញ្ហាមនុស្សវ័យចាស់និងសុខភាព	- បណ្តាញត្រូវបានភ្ជាប់និងមានទំនាក់ទំនង	០	០	១២៥	១២៥	១២៥	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល
៦៩_ ផ្សព្វផ្សាយបញ្ជាបអំពីបញ្ហាជំងឺនានាដែលមនុស្សវ័យចាស់ប្រឈម និងវិធានការបង្ការនៅពេលឈានចូលវ័យចាស់	- កាត់បន្ថយហានិភ័យជំងឺ - អាយុកាលសង្ឃឹមរស់របស់មនុស្សវ័យចាស់កើនឡើង - និពន្ធ/ថត ឯកសារ/ស្ព័ត និងផ្សព្វផ្សាយប្រព័ន្ធតាមវិទ្យុ ទូរទស្សន៍ គេហទំព័រ ប៉ាណូ និងទស្សនាវដ្តី	០	៤៦	៤៦	៥០	៥០	ថវិកាជាតិ និងថវិកាដៃគូ	ក្រសួងព័ត៌មាន
៧០_ សិក្ខាសាលាអប់រំផ្សព្វផ្សាយស្តីពីវិធានការបង្ការជំងឺឆ្លងនិងមិនឆ្លង និងការស្វែងរកសេវាគាំទ្រផ្លូវចិត្ត	- បុគ្គលិកអប់រំនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ(ចំនួន១០០ នាក់)បានចូលរួម	១៥	២០	២០	២០	២០	ថវិកាជាតិ	ក្រសួងអប់រំ យុវជន និងកីឡា

យុទ្ធសាស្ត្រ២.១.២ : រៀបចំឱ្យមានសេវាប្រឹក្សាយោបល់សម្រាប់មនុស្សចាស់ នៅមណ្ឌលសុខភាព

សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
៧១_ បង្កើតផ្នែកពិគ្រោះយោបល់មនុស្សវ័យចាស់ នៅមណ្ឌលសុខភាព	- ចំនួនមនុស្សបានពិគ្រោះយោបល់សុខភាព(បែងចែកតាមភេទ)	០	០	១០	១០	១០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល
៧២_ បណ្តុះបណ្តាលគ្រូពេទ្យជំនាញពិគ្រោះយោបល់ផ្នែកសុខភាពមនុស្សវ័យចាស់	- ចំនួនគ្រូពេទ្យជំនាញដែលបានបណ្តុះបណ្តាល	០	០	៥០	៥០	៥០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល

យុទ្ធសាស្ត្រ២.១.៣ : បង្កលក្ខណៈឱ្យមនុស្សចាស់អាចទទួលបានសេវាត្រួតពិនិត្យសុខភាពជាប្រចាំ សម្រាប់ការពិនិត្យ តាមដាន និងព្យាបាល និងអាចមានលទ្ធភាពទទួលបានថ្នាំបង្ការសម្រាប់ការការពារទប់ស្កាត់ជំងឺ និងការលើកកម្ពស់សុខភាពនៅពេលវ័យចាស់								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
៧៣_ រៀបចំទស្សនកិច្ចសិក្សាសម្រាប់មន្ត្រីពាក់ព័ន្ធនៅប្រទេសជិតខាងដើម្បីឈ្វេងយល់អំពីគំរូល្អៗក្នុងការផ្តល់សេវាសុខភាពដល់មនុស្សវ័យចាស់	- ចំនួនទស្សនកិច្ចសិក្សាសម្រាប់មន្ត្រីសុខាភិបាលចំនួន៤ដង ទៅប្រទេសជិតខាង	០	០	៤០	៤០	៤០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល
៧៤_ តាក់តែងនិងដាក់ឱ្យអនុវត្តសេចក្តីណែនាំទាក់ទងនឹងការទទួលបានសេវាសុខភាពដោយមនុស្សវ័យចាស់ (Accessibility Guideline)	- សេចក្តីណែនាំទាក់ទងនឹងការទទួលបានសេវាសុខភាពរបស់មនុស្សវ័យចាស់ ត្រូវបានអនុម័ត និងដាក់ឱ្យប្រើប្រាស់	០	០	២០	២០	០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល
៧៥_ ការសិក្សាអំពីលទ្ធភាពក្នុងការថែទាំសុខភាពឥតគិតថ្លៃដល់មនុស្សវ័យចាស់	- របាយការណ៍សិក្សាស្រាវជ្រាវស្តីពីលទ្ធភាពក្នុងពង្រីកសេវាថែទាំសុខភាពឥតគិតថ្លៃដល់មនុស្សវ័យចាស់	០	០	០	៧០	០	ថវិកាជាតិ និងថវិកាដៃគូ	ក្រសួងស.អ.យ.
៧៦_ ផ្សព្វផ្សាយអំពីលទ្ធភាពក្នុងការថែទាំសុខភាពឥតគិតថ្លៃដល់មនុស្សវ័យចាស់	- ចំនួន១ដង - ចំនួនអ្នកចូលរួម១០០នាក់	០	០	១០	១០	១០	ថវិកាជាតិ និងថវិកាដៃគូ	ក្រសួងស.អ.យ.
៧៧_ ការជ្រើសរើសអ្នកទទួលបានការថែទាំនិងអ្នកផ្តល់ការថែទាំសម្រាប់មនុស្សវ័យចាស់	- ចំនួនអ្នកផ្តល់ការថែទាំនិងអ្នកទទួលបានការថែទាំដែលត្រូវបានជ្រើសរើស(រួមមានមនុស្សវ័យចាស់ ស្ត្រី និងជនមានពិការភាព)	០	៤,៣១	០	០	០	ថវិកាដៃគូ	ក្រសួងស.អ.យ.
៧៨_ រៀបចំការអប់រំសុខភាពបឋមសម្រាប់មនុស្សវ័យចាស់នៅតាមសហគមន៍	- ចំនួនអ្នកចូលរួម(រួមមានទាំងមនុស្សវ័យចាស់ ស្ត្រី និងជនមានពិការភាព) ដែលទទួល	០	១១,៧៥	១១,៧៥	១១,៧៥	០	ថវិកាដៃគូ	ក្រសួងស.អ.យ.

	បានសារអប់រំសុខភាពនិង ការពិនិត្យសុខភាពបឋម							

យុទ្ធសាស្ត្រ២.១.៤ : បង្កើតប្រព័ន្ធតាមដាននៅទូទាំងប្រទេស ដើម្បីពិនិត្យតាមដានមើលមនុស្សចាស់ជរាដែលនៅឯកោនិងមនុស្សចាស់ដែលងាយរងគ្រោះ								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
៧៩- រៀបចំធ្វើអង្កេតអំពីមនុស្សវ័យចាស់នៅកម្ពុជា	- អង្កេតនឹងត្រូវធ្វើនៅឆ្នាំ ២០២៣ របាយការណ៍វិភាគលម្អិតនៅឆ្នាំ២០២៤	០	០	៦៤	១,៦០	០	ថវិកាជាតិ	ក្រសួងផែនការ វិទ្យាស្ថានជាតិស្ថិតិ
៨០- ស្រង់ទិន្នន័យមនុស្សវ័យចាស់ដែលរស់នៅឯកោនិងងាយរងគ្រោះ	- ចំនួនមនុស្សវ័យចាស់ដែលរស់នៅឯកោនិងងាយរងគ្រោះ ៣៥៨ ៧៨២នាក់	០	០	៣២	៣២	៣២	ថវិកាជាតិ	ក្រសួងស.អ.យ.
៨១- បង្កើតក្រុមស្ម័គ្រចិត្តភូមិដោយមានបច្ចេកវិទ្យាគាំទ្រងាយស្រួលតាមដានស្ថានភាពមនុស្សវ័យចាស់	- ចំនួនក្រុមស្ម័គ្រចិត្តភូមិបានបង្កើតនិងជំណើរការ	០	២០	២០	២០	២០	ថវិកាជាតិ	ក្រសួងស.អ.យ. សហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
៨២- បណ្តុះបណ្តាលនិងសហការជាមួយសមាគមមនុស្សចាស់នៅតាមឃុំ(OPAs) ក៏ដូចជាមន្ត្រីសង្គមកិច្ច (Social Workers) ដើម្បីផ្តល់ការណែនាំដល់មនុស្សវ័យចាស់ អំពីបញ្ហាសុខភាព និងជាយន្តការតាមដានមើលករណីមនុស្សវ័យចាស់នៅឯកោនិងងាយរងគ្រោះ (Case Management)	- សមាគមមនុស្សចាស់នៅតាមភូមិចំនួន១២០ ទទួលបានការបណ្តុះបណ្តាល	០	០	៥០	៥០	៥០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល

ទិសដៅ២.២ : បង្កើតប្រព័ន្ធសុខាភិបាលមួយដែលមានលក្ខណៈឆ្លើយតប ដែលអាចទទួលបាន និងធានាបាននូវសេវាព្យាបាលប្រកបដោយគុណភាព

យុទ្ធសាស្ត្រ២.២.១ : ផ្តល់ឱ្យមូលដ្ឋានសុខាភិបាលដែលផ្តល់សេវាព្យាបាលសុខភាព នូវបុគ្គលិកគ្រប់គ្រាន់ ប្រកបដោយវិជ្ជាជីវៈ មានក្រមសីលធម៌ និងនៅប្រចាំការ ដើម្បីផ្តល់សេវាសុខភាពមូលដ្ឋានដល់មនុស្សចាស់ រួមទាំងការបញ្ជូនទៅឱ្យសេវាសុខភាពឯកទេសនិងការតាមដានបន្តផងដែរ

សកម្មភាព	ចំណុចដៅ/សូចនាករ	ថវិការ៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)					ប្រភពធនធាន	ស្ថាប័នទទួលខុសត្រូវ
		២០២១	២០២២	២០២៣	២០២៤	២០២៥		
៨៣_ បង្កើតយន្តការការតាមដានការត្រួតពិនិត្យ និងការវាយតម្លៃចំពោះការផ្តល់សេវាសុខភាពមូលដ្ឋានដល់មនុស្សវ័យចាស់ ដើម្បីធានាថាការផ្តល់ សេវានោះប្រកបដោយប្រសិទ្ធភាពខ្ពស់	- យន្តការការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃត្រូវបានបង្កើត	០	០	១០	០	០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល
៨៤_ វាយតម្លៃលើសមត្ថភាពដែលមានស្រាប់និងត្រូវការបន្ថែម(ទាំងធនធានមនុស្ស ថវិកា សម្ភារៈ) នៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យថ្នាក់ខេត្ត និងថ្នាក់ជាតិ ដើម្បីធានានូវការផ្តល់សេវាដល់មនុស្សចាស់ប្រកបដោយប្រសិទ្ធភាព	- ការសិក្សាវាយតម្លៃលើសមត្ថភាពដែលមានស្រាប់ត្រូវបានចាប់ផ្តើមនិងបញ្ចប់នៅឆ្នាំ ២០២២	០	០	០	០	០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល
៨៥_ ចុះអភិបាលលើសេវាថែទាំមនុស្សវ័យចាស់ នៅក្នុងកញ្ចប់សេវា MPA នៅតាមមណ្ឌលសុខភាព រួមទាំងឱសថដែលចាំបាច់សម្រាប់មនុស្សវ័យចាស់	- ចំនួនដងនៃការអភិបាលទៅលើមណ្ឌលសុខភាពដែលបានអនុវត្តការថែទាំសុខភាពមនុស្សវ័យចាស់ តាមគោលការណ៍MPA	០	០	៣០	៣០	៣០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល
៨៦_ បង្កើនបន្ថែមនូវសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ នៅតាមមន្ទីរពេទ្យខេត្តនិងមន្ទីរពេទ្យបង្អែក	- ចំនួនមន្ទីរពេទ្យខេត្តនិងមន្ទីរពេទ្យបង្អែកដែលបានបង្កើតសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ	០	០	៥	៥	៥	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល

យុទ្ធសាស្ត្រ២.២.២: ត្រៀមលក្ខណៈឱ្យមន្ទីរពេទ្យថ្នាក់ជាតិអាចផ្តល់នូវសេវាសុខភាពពេញលេញសម្រាប់មនុស្សចាស់ ក្នុងនោះ រួមទាំងការត្រួតពិនិត្យ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលផ្សេងៗ								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
៨៧_ បង្កើតយន្តការការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ ចំពោះការផ្តល់សេវាថ្នាក់ជាតិលើមនុស្ស វ័យចាស់ ដើម្បីធានាថាការផ្តល់សេវា នោះប្រកបដោយប្រសិទ្ធភាពខ្ពស់	- ប្រព័ន្ធការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃត្រូវបានបង្កើត	២០	២០	២០	២០	២០	ថវិកាជាតិ	ទីស្តីការគណៈរដ្ឋមន្ត្រី
៨៨_ បង្កើតយន្តការការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ ចំពោះការផ្តល់សេវាសុខភាពថ្នាក់ជាតិដល់មនុស្សវ័យចាស់ ដើម្បីធានាថាការផ្តល់សេវានោះប្រកបដោយប្រសិទ្ធភាពខ្ពស់	- ប្រព័ន្ធការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃត្រូវបានបង្កើត	០	០	៥	៥	៥	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល
៨៩_ បង្កើតសេវាសុខភាពដល់មនុស្សវ័យចាស់នៅតាមមន្ទីរពេទ្យជាតិ	- ផ្នែកផ្តល់សេវាសុខភាពមនុស្សវ័យចាស់ ត្រូវបង្កើត	០	០	៥	០	០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល
៩០_ ផ្តល់ឧបករណ៍ជំនួយដែលចាំបាច់ ដូចជាឧបករណ៍ជំនួយការស្តាប់ ការមើល ឈើច្រត់ ដល់មនុស្សវ័យចាស់ដែលងាយរងគ្រោះ	- ចំនួនមនុស្សវ័យចាស់ងាយរងគ្រោះ ដែលទទួលឧបករណ៍ជំនួយ	០	០	៣០០	៣០០	៣០០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល

យុទ្ធសាស្ត្រ២.២.៣ : ជាក់ឱ្យមានអ្នកវិជ្ជាជីវៈសុខាភិបាល ដែលបានទទួលការបណ្តុះបណ្តាលអំពីសុខភាពមនុស្សចាស់ នៅគ្រប់មណ្ឌលសុខភាពទាំងអស់								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
៩១_ រៀបចំកម្មវិធីសិក្សាសម្រាប់បណ្តុះបណ្តាលជំនាញព្យាបាលមនុស្សវ័យចាស់ សម្រាប់បុគ្គលិក	- ឯកសារបណ្តុះបណ្តាលជំនាញព្យាបាលមនុស្សវ័យចាស់ សម្រាប់បុគ្គលិកសុខាភិបាល	០	០	២០	០	០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល

សុខាភិបាលនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក មន្ទីរពេទ្យថ្នាក់ខេត្តនិងថ្នាក់ជាតិ	ត្រូវបានតាក់តែងនៅឆ្នាំ ២០២៤							
៩២- បណ្តុះបណ្តាលជំនាញព្យាបាលដល់បុគ្គលិកសុខាភិបាល នៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក មន្ទីរពេទ្យថ្នាក់ខេត្ត ថ្នាក់ជាតិ	- ចំនួនបុគ្គលិកសុខាភិបាលទទួលបានការបណ្តុះបណ្តាល	០	០	៥០	៥០	០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល

យុទ្ធសាស្ត្រ២.២.៤ : កសាងសមត្ថភាពឱ្យបានគ្រប់គ្រាន់នៅតាមមន្ទីរពេទ្យនានា ក្នុងការថែទាំអ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ ដើម្បីអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មនុស្សចាស់ក្នុងការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ

សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
៩៣- រៀបចំវគ្គបណ្តុះបណ្តាលអ្នកជំនាញថែទាំមនុស្សវ័យចាស់	- ចំនួនវគ្គលើក - ចំនួនអ្នកចូលរួម៣០០នាក់	០	០	១២០	១២០	១២០	ថវិកាជាតិ	ក្រសួងស.អ.យ.

យុទ្ធសាស្ត្រ២.២.៥ : ពង្រីកវិសាលភាពគ្របដណ្តប់សេវាថែទាំសុខភាពប្រកបដោយគុណភាព ដោយឥតគិតថ្លៃ និងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់មនុស្សចាស់ក្រីក្រដែលមិនមានលទ្ធភាពបង់ថ្លៃសេវាវេជ្ជសាស្ត្រមួយចំនួន

សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
៩៤- រៀបចំទិវាសុខភាពពិភពលោក	- ចំនួនអ្នកចូលរួមនិងចំនួនមនុស្សវ័យចាស់ដែលទទួលបានសេវាសុខភាពនៅក្នុងឱកាសនៃទិវានេះ(មនុស្សវ័យចាស់ ស្ត្រី និងជនមានពិការភាព)	០	៣៧,៤៣	១២,៤៨	២៤,៩៥	២៤,៩៥	ថវិកាដៃគូ	ក្រសួងស.អ.យ.

យុទ្ធសាស្ត្រ២.២.៦ : ជានាថា មន្ទីរពេទ្យរដ្ឋទាំងអស់មានសេវាវេជ្ជសាស្ត្រសម្រាប់មនុស្សចាស់ ប្រកបដោយគុណភាព								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		

យុទ្ធសាស្ត្រ២.២.៧ : ជានាឱ្យមានឱសថសំខាន់ៗដែលត្រូវការជាទូទៅសម្រាប់ការព្យាបាលជំងឺដែលប៉ះពាល់ដល់មនុស្សចាស់								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
៩៥- ផ្តល់នូវឱសថឱ្យបានគ្រប់គ្រាន់ និងមានគុណភាពសម្រាប់ការព្យាបាលជំងឺមនុស្សវ័យចាស់(ដាក់បញ្ចូលទៅក្នុងបញ្ជីឱសថសារវន្តរបស់ក្រសួងសុខាភិបាល)	- ចំនួនកន្លែងផ្តល់សេវាសុខភាពដែលមិនបានការដាច់ស្តុកឱសថ	០	០	០	០	០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល

ទិសដៅ២.៣ : ឆ្លើយតបនឹងតម្រូវការរបស់មនុស្សចាស់ សម្រាប់ការថែទាំរយៈពេលវែង

យុទ្ធសាស្ត្រ២.៣.១ : ពិចារណារៀបចំឱ្យមានសេវាថែទាំនិងការព្យាបាលតាមផ្ទះ ចំពោះមនុស្សចាស់ដែលត្រូវការការថែទាំរយៈពេលវែង ដោយសារពិការភាព ជំងឺរ៉ាំរ៉ៃ ឬជំងឺដល់អាយុជីវិត								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
៩៦- ជួយសម្របសម្រួលក្នុងការព្យាបាលដល់មន្ត្រីដែលមានជំងឺឬគ្រោះថ្នាក់	- មន្ត្រីដែលទទួលការសម្របសម្រួលក្នុងការព្យាបាលជំងឺ ចំនួន៣០០នាក់	៣០	៣០	៣០	៣០	៣០	ថវិកាមូលនិធិ	ក្រសួងបរិស្ថាន
៩៧- រៀបចំគោលការណ៍ណែនាំ និងបទដ្ឋានស្តីពីការថែទាំមនុស្សវ័យចាស់នៅតាមមណ្ឌល	- គោលការណ៍ណែនាំត្រូវបានរៀបចំ	០	០	៥០	៥០	០	ថវិកាជាតិ	ក្រសួងស.អ.យ.
៩៨- ផ្សព្វផ្សាយគោលការណ៍ណែនាំ និងបទដ្ឋានស្តីពីការថែទាំមនុស្សវ័យចាស់នៅតាមមណ្ឌល	- ចំនួន២៥លើក - ចំនួនអ្នកចូលរួម៣០០០នាក់	០	០	០	៣៣០	០	ថវិកាជាតិ	ក្រសួងស.អ.យ.

៩៩- រៀបចំកិច្ចប្រជុំស្តីពីការរៀបចំគោលការណ៍ណែនាំស្តីពីការថែទាំមនុស្សវ័យចាស់រយៈពេលវែង	- ចំនួន៦លើក - ចំនួនអ្នកចូលរួម៦០០នាក់	០	០	២០	២០	២០	ថវិកាជាតិ	ក្រសួងស.អ.យ.
១០០- សិក្សាលទ្ធភាពក្នុងការដាក់ឱ្យដំណើរការកម្មវិធីថែទាំឬសេវាថែទាំមនុស្សវ័យចាស់នៅតាមផ្ទះ	- ចំនួនរបាយការណ៍សិក្សាលទ្ធភាពក្នុងការដាក់ឱ្យដំណើរការកម្មវិធីថែទាំឬសេវាថែទាំមនុស្សវ័យចាស់នៅតាមផ្ទះ	០	០	០	៧០	០	ថវិកាជាតិ	ក្រសួង ស.អ.យ.
១០១- រៀបចំទស្សនកិច្ចសិក្សាសម្រាប់មន្ត្រីពាក់ព័ន្ធនៅប្រទេសជិតខាង ដើម្បីឈ្វេងយល់អំពីគំរូល្អៗក្នុងការផ្តល់សេវាសុខភាពដល់មនុស្សវ័យចាស់	- ចំនួនទស្សនកិច្ចសិក្សាត្រូវបានប្រព្រឹត្តទៅនៅក្នុងឆ្នាំ២០២៣ ឆ្នាំ២០២៤ ឆ្នាំ២០២៥	០	០	៦០	៦០	៦០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល
១០២- បង្កើតអនុគណៈកម្មការសម្រាប់ផ្នែកសុខភាពនិងការថែទាំតាមផ្ទះ	- ចំនួនអនុគណៈកម្មការដែលបានជ្រើសរើសក្នុង៤០ភូមិ (រួមមានទាំងមនុស្សវ័យចាស់ ស្ត្រី និងជនមានពិការភាព)	០	១១,៦	០	០	០	ថវិកាដៃគូ	ក្រសួងស.អ.យ.

យុទ្ធសាស្ត្រ២.៣.២ : ផ្តល់ការបណ្តុះបណ្តាលនិងការលើកទឹកចិត្តដល់សមាជិកគ្រួសារដែលត្រូវការមើលថែអ្នកជំងឺវ័យចាស់ទាំងឱ្យាយណាដែលត្រូវការការថែទាំរយៈពេលវែង

សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
១០៣- ផ្តល់ការបណ្តុះបណ្តាលដល់សមាជិកគ្រួសារ/អ្នកថែទាំក្នុងគ្រួសារដែលត្រូវមើលថែអ្នកជំងឺវ័យចាស់អំពីរបៀបថែទាំមនុស្សវ័យចាស់	- ចំនួនសមាជិកគ្រួសារដែលមានអ្នកជំងឺជាមនុស្សចាស់នៅតាមតំបន់មួយចំនួន ត្រូវបានបណ្តុះបណ្តាល	០	០	៤០	៤០	៤០	ថវិកាជាតិ	ក្រសួងស.អ.យ.
១០៤- រៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងលើកទឹកចិត្តដល់សមាជិកគ្រួសារក្នុងការថែទាំមនុស្សវ័យចាស់នៅក្នុងគ្រួសារ	- ចំនួន៩លើក - ចំនួនអ្នកចូលរួម៤៥០នាក់	០	០	៥០	៥០	៥០	ថវិកាជាតិ	ក្រសួងស.អ.យ.

យុទ្ធសាស្ត្រ២.៣.៣ : ពិចារណារៀបចំបង្កើតមជ្ឈមណ្ឌលថែទាំសម្រាប់មនុស្សចាស់ទាំងឡាយណាដែលត្រូវការការថែទាំរយៈពេលយូរ								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
១០៥- បង្កើតលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការគ្រប់គ្រងមជ្ឈមណ្ឌលថែទាំមនុស្សវ័យចាស់	- ចំនួនលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការគ្រប់គ្រងមជ្ឈមណ្ឌលថែទាំមនុស្សវ័យចាស់ត្រូវបានបង្កើតនិងអនុម័ត	០	០	២០	២០	២០	ថវិកាជាតិ	ក្រសួងស.អ.យ.
១០៦- ចុះតាមដាននិងត្រួតពិនិត្យមជ្ឈមណ្ឌលថែទាំមនុស្សវ័យចាស់របស់វិស័យឯកជន និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស	- ធ្វើអធិការកិច្ចមជ្ឈមណ្ឌលថែទាំមនុស្សវ័យចាស់របស់វិស័យឯកជន និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេសចំនួន៨ដង	០	០	២៤	២៤	២៤	ថវិកាជាតិ	ក្រសួងស.អ.យ.
១០៧- សិក្សាស្រាវជ្រាវអំពីលទ្ធភាពក្នុងការបង្កើតមជ្ឈមណ្ឌលថែទាំមនុស្សវ័យចាស់	- របាយការណ៍ស្រាវជ្រាវស្តីពីលទ្ធភាពក្នុងការបង្កើតមជ្ឈមណ្ឌលថែទាំមនុស្សវ័យចាស់ចំនួន១ច្បាប់	០	០	០	៧០	៧០	ថវិកាជាតិ និងថវិកាដៃគូ	ក្រសួងស.អ.យ.

យុទ្ធសាស្ត្រ២.៣.៤ : កែលម្អលទ្ធភាពទទួលបានការប្រើប្រាស់សេវាតាមមូលដ្ឋានសុខាភិបាល សម្រាប់ការពិនិត្យនិងការព្យាបាលជំងឺរ៉ាំរ៉ៃនានា ដូចជាជំងឺលើសសម្ពាធឈាម ជំងឺទឹកនោមផ្អែម ជំងឺសរសៃឈាមក្នុងខួរក្បាល ជំងឺមហារីក ជំងឺរលេងរង្វាន់ និងជំងឺបាត់បង់ការចងចាំ								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		

ទិសដៅ២.៤ : បន្តរៀបចំឱ្យបុគ្គលិកសុខាភិបាល មានចំនួនគ្រប់គ្រាន់និងទទួលបានការបណ្តុះបណ្តាល

យុទ្ធសាស្ត្រ២.៤.១ : វាយតម្លៃអំពីតម្រូវការអ្នកប្រកបវិជ្ជាជីវៈផ្នែកការថែទាំសុខភាពនិងសង្គមកិច្ច និងរៀបចំកម្មវិធីអប់រំឬបណ្តុះបណ្តាលបន្ថែមសម្រាប់បុគ្គលិកទាំងនេះ ទៅតាមសេចក្តីត្រូវការនាពេលបច្ចុប្បន្ន								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
១០៨- សិក្សាស្រាវជ្រាវអំពីតម្រូវការជំនាញថែទាំសុខភាពមនុស្សវ័យចាស់	- របាយការណ៍សិក្សាស្រាវជ្រាវអំពីតម្រូវការជំនាញថែទាំសុខ	០	០	៧០	០	០	ថវិកាជាតិ	ក្រសួងស.អ.យ.

	ភាពមនុស្សវ័យចាស់							
១០៩_ រៀបចំកិច្ចប្រជុំស្តីពីកម្មវិធីអប់រំបណ្តុះបណ្តាលជំនាញថែទាំសុខភាពមនុស្សវ័យចាស់	- ចំនួន៦លើក - ចំនួនអ្នកចូលរួម៦០០នាក់	០	០	២០	២០	២០	ថវិកាជាតិ	ក្រសួងស.អ.យ.
១១០_ ផ្តល់ការអប់រំនិងបណ្តុះបណ្តាលដល់កម្លាំងសេវាសង្គមកិច្ចអំពីសុខុមាលភាពនិងការថែទាំមនុស្សវ័យចាស់	- ចំនួន៦លើក - ចំនួនអ្នកចូលរួម៧៥០នាក់	០	០	២៥	២៥	២៥	ថវិកាជាតិ	ក្រសួងស.អ.យ.

យុទ្ធសាស្ត្រ២.៤.២ : លើកកម្ពស់ការអប់រំនិងការបណ្តុះបណ្តាលផ្នែកការថែទាំសុខភាពនិងការថែទាំមនុស្សចាស់ សម្រាប់អ្នកប្រកបវិជ្ជាជីវៈផ្នែកការថែទាំសុខភាពនិងសង្គមកិច្ច អ្នកស្ម័គ្រចិត្ត និងអ្នកថែទាំ								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
១១១_ រៀបចំសិក្ខាសាលាផ្សព្វផ្សាយជំនាញថែទាំមនុស្សវ័យចាស់	- ចំនួន៦លើក - ចំនួនអ្នកចូលរួម៣០០នាក់	០	០	៣០	៣០	៣០	ថវិកាជាតិនិងថវិកាដៃគូ	ក្រសួងស.អ.យ.
១១២_ រៀបចំនិងដាក់ឱ្យដំណើរការកម្មវិធីអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេកទេសថែទាំមនុស្សវ័យចាស់សម្រាប់អ្នកថែទាំ កម្លាំងសេវាសង្គមនិងអ្នកស្ម័គ្រចិត្ត	- ចំនួន៦លើក - ចំនួនអ្នកចូលរួម២០០នាក់	០	០	១៥	១៥	១៥	ថវិកាជាតិ	ក្រសួងស.អ.យ.
១១៣_ បន្តកសាងសមត្ថភាពអ្នកថែទាំកម្លាំងសេវាសង្គម និងអ្នកស្ម័គ្រចិត្ត តាមរយៈការបន្តការបណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេកទេសថែទាំមនុស្សវ័យចាស់	- ចំនួន៦លើក - ចំនួនអ្នកចូលរួម៣០០នាក់	០	០	៥០	៥០	៥០	ថវិកាជាតិ	ក្រសួងស.អ.យ.
១១៤_ ការបណ្តុះបណ្តាលដល់អនុគណៈកម្មការនិងអ្នកផ្តល់ការថែទាំស្តីពីការថែទាំសុខភាពនិងការថែទាំតាមផ្ទះ	- ចំនួនវគ្គបណ្តុះបណ្តាល - ចំនួនអ្នកចូលរួម(រួមមានទាំងមនុស្សវ័យចាស់ ស្ត្រី និងជនមានពិការភាព)	០	៥៩,៤៨	២៩,៧៤	០	០	ថវិកាដៃគូ	ក្រសួងស.អ.យ.

១១៥_ ការផ្តល់ឧបករណ៍សុខភាពសម្រាប់សមាគមមនុស្សចាស់/ក្រុមអន្តរជំនាន់	- សមាគមចំនួន៤០ភូមិទទួលបានឧបករណ៍សុខភាព	០	១១,៩២	២៣,៨៥	០	០	ថវិកាដៃគូ	ក្រសួងស.អ.យ.

យុទ្ធសាស្ត្រ២.៤.៥ : ដាក់ឱ្យមានមុខវិជ្ជាសិក្សាស្តីពីការថែទាំសុខភាពមនុស្សចាស់ នៅគ្រប់កម្មវិធីសិក្សាវិជ្ជាជីវៈសុខាភិបាល								
សកម្មភាព	**ចំណុចដៅ/សូចនាករ**	**ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)**					**ប្រភពធនធាន**	**ស្ថាប័នទទួលខុសត្រូវ**
		២០២១	**២០២២**	**២០២៣**	**២០២៤**	**២០២៥**		
១១៦_ បញ្ចាបជំនាញថែទាំមនុស្សវ័យចាស់ទៅក្នុងកម្មវិធីសិក្សានៅតាមសាលានិងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល	- ជំនាញថែទាំមនុស្សវ័យចាស់យ៉ាងហោចណាស់២ ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សា	០	០	១០	១០	១០	ថវិកាជាតិ	ក្រសួងស.អ.យ.
១១៧_ សហការជាមួយសាកលវិទ្យាល័យឯកជន ដើម្បីបង្កើតកម្មវិធីសិក្សាពីជំនាញសុខភាពមនុស្សវ័យចាស់	- គ្រឹះស្ថានឧត្តមសិក្សាឯកជនយ៉ាងហោចណាស់៥ បានដាក់បញ្ចូលកម្មសិក្សាពីជំនាញថែទាំសុខភាពមនុស្សវ័យចាស់	០	០	១០	១០	១០	ថវិកាជាតិ	ក្រសួងស.អ.យ.
១១៨_ បង្កើតលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសាលានិងសាកលវិទ្យាល័យដែលបណ្តុះបណ្តាលជំនាញថែទាំមនុស្សវ័យចាស់	- ចំនួនលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសាលានិងសាកលវិទ្យាល័យដែលបណ្តុះបណ្តាលជំនាញថែទាំមនុស្សវ័យចាស់ត្រូវបានបង្កើតនិងអនុម័ត	០	០	២០	២០	២០	ថវិកាជាតិ	ក្រសួងស.អ.យ.

អាទិភាពទី៣ : រៀបរបបការរស់នៅ

ទិសដៅ៣.១ : លើកទឹកចិត្តឱ្យមានដំណើរឈានចូលវ័យចាស់នៅនឹងកន្លែងដែលមនុស្សចាស់កំពុងរស់នៅ

យុទ្ធសាស្ត្រ៣.១.១ : ផ្តល់ការបណ្តុះបណ្តាលមូលដ្ឋានដល់អ្នកថែទាំតាមផ្ទះ ក្នុងការថែទាំមនុស្សចាស់ ចំណេះដឹង និងព័ត៌មានអំពីសេវាមានសារប្រយោជន៍ និងការចាត់ចែងក្នុងស្ថានភាពមានអាសន្ន

សកម្មភាព	ចំណុចដៅ/សូចនាករ	ថវិកាប៉ាន់ស្មានអនុវត្តប្រចាំឆ្នាំ(ឯកតាគិតជាលានរៀល)					ប្រភពធនធាន	ស្ថាប័នទទួលខុសត្រូវ
		២០២១	២០២២	២០២៣	២០២៤	២០២៥		
១១៩- អប់រំសុខភាពបឋមនៅថ្នាក់សហគមន៍ ការចុះសួរសុខទុក្ខតាមផ្ទះ និងការអប់រំសុខភាពផ្លូវចិត្តជាមូលដ្ឋាន និងការអន្តរាគមន៍	- មនុស្សវ័យចាស់ប្រមាណ៦០% ក្នុង៨១សមាគម បានរាយការណ៍អំពីស្ថានភាពប្រសើរឡើងនៃសុខភាពរបស់ពួកគាត់ និងបានយល់ដឹងអំពីការថែទាំសុខភាពពេលចូលវ័យចាស់	០	០	២០	២០	២០	ថវិកាជាតិ ឬដៃគូ	ក្រសួងសុខាភិបាល
១២០- រៀបចំកម្មវិធីបណ្តុះបណ្តាល និងបណ្តុះបណ្តាលជំនាញថែទាំផ្ទះ ចុងភៅ និងថែទាំកុមារ(Home and Family Care) ដល់ពលករចំណាក ស្រុកកម្មករកម្មការិនី ឬអ្នកជំនាញទេសចរណ៍វ័យចាស់ក្មេង ក្នុងជំនាញគេហកិច្ចដែលប្តូរជំនាញ (Skill Transformation)	- ឯកសារបណ្តុះបណ្តាលជំនាញទេសចរណ៍និងអនុវត្ត ២៥ រាជធានី ខេត្ត	១៩៥	១៥៣	១៨០	១៥៣	២៣១	ថវិកាជាតិ ឯកជន ដៃគូអភិវឌ្ឍ	ក្រសួងទេសចរណ៍
១២១- រៀបចំកម្មវិធីបណ្តុះបណ្តាល និងបណ្តុះបណ្តាលជំនាញថែទាំមនុស្សវ័យចាស់ដល់អ្នកជំនាញម៉ាស្សាដែលមានវ័យចំណាស់ ឬឈប់បម្រើការក្នុងជំនាញម៉ាស្សា ស្ប៉ា(ត្រៀមជាស្រេចនៅពេលមានមណ្ឌលចាស់ជរានៅថ្ងៃអនាគត)	- ឯកសារបណ្តុះបណ្តាលជំនាញទេសចរណ៍ និងអនុវត្ត ២៥ រាជធានី ខេត្ត	២៣៥	១៨២	១៩៧	១៦៣	១៩៨	ថវិកាជាតិ ឯកជន ដៃគូអភិវឌ្ឍ	ក្រសួងទេសចរណ៍
១២២- អប់រំផ្សព្វផ្សាយអំពីសុខភាពមនុស្សវ័យចាស់	- ប្រជាជនក្នុងសហគមន៍	៦០	៦០	៨០	៦០	៦០	សប្បុរសជន	កាកបាទក្រហមកម្ពុជា

១២៣_ បណ្តុះបណ្តាលអ្នកស្ម័គ្រចិត្ត	- អ្នកស្ម័គ្រចិត្ត កក្រក	២៨	២៨	២៨	២៨	២៨	សប្បុរសជន	កាកបាទក្រហមកម្ពុជា
